ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយជាតិ

## ស្តីពី

# ប្រសិទ្ធភាពថាមពល

## ២០២២ - ២០៣០

រៀបចំដោយ៖ គណៈកម្មាធិការជាតិប្រសិទ្ធភាពថាមពល

២០២២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយជាតិ

## ស្តីពី

# ប្រសិទ្ធភាពថាមពល

## ២០២២ - ២០៣០

រៀបចំដោយ៖ គណៈកម្មាធិការជាតិប្រសិទ្ធភាពថាមពល

២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ...៧៨...សសរ....

# សេចក្តីសម្រេច
# ស្តីពី
# ការដាក់ឱ្យប្រើប្រាស់នូវគោលនយោបាយជាតិ ស្តីពី ប្រសិទ្ធភាពថាមពល ២០២២-២០៣០

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៩/១០២៤ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់នូវ "**គោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០**" ដែលជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៤ រោច ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# បុព្វកថា

ក្នុងរយៈពេលពីរទសវត្សចុងក្រោយនេះ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តដោយជោគជ័យនូវយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព។ យុទ្ធសាស្ត្រនេះបានក្លាយជាឧបករណ៍គោលនយោបាយដែលជួយកែប្រែប្រទេសកម្ពុជាពីប្រទេសឱនភិវឌ្ឍន៍ ទៅជាប្រទេសដែលមានសេដ្ឋកិច្ចលូតលាស់លឿនបំផុតមួយក្នុងពិភពលោក ជួយប្រជាពលរដ្ឋកម្ពុជារាប់លាននាក់ឱ្យងើបផុតពីភាពក្រីក្រ និងជួយកែលម្អសូចនាករអភិវឌ្ឍន៍សង្គមជាច្រើនទៀត។ កិច្ចខិតខំប្រឹងប្រែងប្រកបដោយមហិច្ឆតារបស់រាជរដ្ឋាភិបាលខាងលើនេះ បាននិងកំពុងដឹកនាំប្រទេសនិងប្រជាជនកម្ពុជា ពីប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប។ ការរីកចម្រើនលូតលាស់យ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ចជាតិនេះ បានធ្វើឱ្យតម្រូវការថាមពល ជាពិសេសថាមពលអគ្គិសនី បានកើនឡើងក្នុងកម្រិតមួយខ្ពស់ដែលមិនធ្លាប់មានពីមុនមក ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ជាក់ស្តែង ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៩ ការប្រើប្រាស់ថាមពលអគ្គិសនីក្នុងមនុស្សម្នាក់នៅកម្ពុជា បានកើនឡើងជាមធ្យម ១៨% ក្នុងមួយឆ្នាំ ខណៈដែលតម្រូវការថាមពលអគ្គិសនីសរុបទូទាំងប្រទេសប្រចាំឆ្នាំ នៅឆ្នាំ២០១៩ បានកើនឡើងជាង ៤ ដង នៃតម្រូវការនៅឆ្នាំ២០១០។ ដោយសារវិស័យថាមពល គឺជាសសរស្តម្ភ និងជាស្នូលដ៏សំខាន់នៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដូច្នេះការបន្តអភិវឌ្ឍវិស័យថាមពលឱ្យមានតុល្យភាព និរន្តរភាព និងប្រសិទ្ធភាព គឺជាកូនសោគន្លឹះមួយដ៏សំខាន់ក្នុងការបន្តជំរុញវឌ្ឍនភាពសេដ្ឋកិច្ចកម្ពុជា។

នៅក្នុងបរិបទនេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមប្រកាសដាក់ឱ្យអនុវត្តនូវ «គោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០» ដែលនឹងកំណត់តួនាទីប្រសិទ្ធភាពថាមពល ជាអភិក្រមគន្លឹះមួយក្នុងការអភិវឌ្ឍវិស័យថាមពលនៅកម្ពុជា។ ផលប្រយោជន៍ដែលទទួលបានពីប្រសិទ្ធភាពថាមពលមានច្រើន និងមានលក្ខណៈជាពហុវិស័យ។ តាមរយៈការប្រើប្រាស់ថាមពលតិចជាងមុន ប៉ុន្តែរក្សាបានទិន្នផលដូចមុន ឬប្រសើរជាងមុន ប្រសិទ្ធភាពថាមពលនឹងជួយសន្សំសំចៃការប្រើប្រាស់ថាមពល កាត់បន្ថយការចំណាយលើការប្រើប្រាស់ថាមពលរបស់អ្នកប្រើប្រាស់ថាមពលទាំងអស់ ដែលបើកឱកាសឱ្យប្រជាពលរដ្ឋដែលប្រើប្រាស់ថាមពល អាចសន្សំបាននូវធនធានហិរញ្ញវត្ថុរបស់ខ្លួនយកទៅចំណាយលើសកម្មភាពសេដ្ឋកិច្ចផ្សេងទៀត និងបើកឱកាសឱ្យអ្នកធ្វើធុរកិច្ច និងឧស្សាហកម្មនានាដែលប្រើប្រាស់អគ្គិសនីអាចបង្កើនការប្រកួតប្រជែង។ ប្រសិទ្ធភាពថាមពលក៏នឹងជួយគាំទ្រដល់មហិច្ឆតារបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកាត់បន្ថយការពឹងផ្អែករបស់កម្ពុជាលើការនាំចូលថាមពល និងជួយកាត់បន្ថយតម្រូវការវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធថាមពលថ្មីទៀតផងដែរ ហើយជាលទ្ធផលនឹងនាំឱ្យថ្លៃថាមពលដែលផ្តល់ឱ្យអ្នកប្រើប្រាស់ថយចុះ។

ជាមួយគ្នានេះ ខ្ញុំចង់រំលេចឱ្យឃើញអំពីអត្ថប្រយោជន៍ដ៏សំខាន់មួយទៀតនៃប្រសិទ្ធភាពថាមពលដែលពាក់ព័ន្ធជាមួយនឹងការប្រែប្រួលអាកាសធាតុនិងបញ្ហាបរិស្ថាន។ នៅពេលដែលប្រសិទ្ធភាពថាមពលបានបន្ថយតម្រូវការថាមពល ពេលនោះការប្រើប្រាស់ឥន្ធនៈហ្វូស៊ីលក៏ថយចុះដែរ ការណ៍នេះមិនត្រឹមតែនាំឱ្យ

ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ថយចុះដែលជួយគាំទ្រដល់ប្រទេសកម្ពុជា ក្នុងការបំពេញការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងក្របខណ្ឌកិច្ចព្រមព្រៀងទីក្រុងប៉ារីសប៉ុណ្ណោះទេ ប៉ុន្តែក៏បានជួយកាត់បន្ថយការបំពុលបរិស្ថានផ្សេងៗទៀតផងដែរ។

តាមរយៈគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០ នេះ រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាយ៉ាងមុតមាំថា នឹងកែប្រែការប្រើប្រាស់ថាមពលនៅគ្រប់វិស័យទាំងអស់នៅកម្ពុជា ឱ្យក្លាយទៅជាការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីជួយជំរុញសេដ្ឋកិច្ចជាតិឱ្យរឹងមាំ រស់រវើក ប្រកួតប្រជែង និងចូលរួមការអភិវឌ្ឍប្រកបដោយចីរភាព។ ដើម្បីសម្រេចគោលបំណងនេះបាន ទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធនិងសង្គមជាតិទាំងមូល ដូច្នេះក្នុងនាមប្រមុខរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមអំពាវនាវដល់គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងប្រជាពលរដ្ឋកម្ពុជាទាំងអស់ចូលរួមឱ្យបានសកម្ម គាំទ្រកិច្ចខិតខំប្រឹងប្រែងរួមគ្នាខាងលើនេះដើម្បីប្រែក្លាយប្រទេសកម្ពុជាឱ្យទៅជាសង្គមដែលមានប្រសិទ្ធភាពថាមពល។

ជាចុងក្រោយ ខ្ញុំសូមសម្តែងនូវអំណរសាទរ និងការវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងរ៉ែនិងថាមពល ក្នុងការដឹកនាំនិងរៀបចំរហូតដល់សម្រេចបាននូវគោលនយោបាយដ៏មានតម្លៃ និងមានសារៈសំខាន់នេះ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា គោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០ នេះ នឹងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការសម្រេចឱ្យបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីប្រែក្លាយប្រទេសកម្ពុជាឱ្យទៅជាប្រទេសមានចំណូលខ្ពស់ ប្រកបដោយចីរភាពនិងបរិយាបន្នភាពនៅឆ្នាំ២០៥០។

ថ្ងៃអង្គារ ១៤ រោច ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# អារម្ភកថា

ក្នុងបរិបទបច្ចុប្បន្ន នៅពេលដែលសេដ្ឋកិច្ចកម្ពុជាកំពុងតែរីកចម្រើន និងអភិវឌ្ឍ វិស័យថាមពលនៅកម្ពុជាមិនត្រឹមតែមានភារកិច្ចត្រូវបង្កើននូវការអភិវឌ្ឍទប់ទល់ជាមួយនឹងកំណើនតម្រូវការថាមពល ដោយត្រូវធ្វើយ៉ាងណាឱ្យការផ្គត់ផ្គង់ថាមពលមានគ្រប់គ្រាន់ អាចទុកចិត្តបាន និងមានថ្លៃកាន់តែសមរម្យប៉ុណ្ណោះទេ ប៉ុន្តែជាមួយគ្នានោះ ក៏ត្រូវពិចារណាធ្វើការអភិវឌ្ឍ និងប្រើប្រាស់ថាមពល តាមជម្រើសណាដែលកាន់តែមានចីរភាពផងដែរ។ ឈរលើមូលដ្ឋាននេះ ក្រសួងរ៉ែ និងថាមពល បាននិងកំពុងសិក្សារកកាលានុវត្តភាព បង្កើនការប្រើប្រាស់បច្ចេកវិទ្យាថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពល ឱ្យបានជាអតិបរមា នៅក្នុងការអភិវឌ្ឍវិស័យថាមពលនៅកម្ពុជាបន្តទៀត ដើម្បីផ្លាស់ប្តូរប្រទេសកម្ពុជាឆ្ពោះទៅរកការប្រើប្រាស់ថាមពលកាន់តែស្អាត និងកាន់តែមានប្រសិទ្ធភាព ព្រមទាំងរក្សាបាននូវកម្រិតសន្តិសុខថាមពល។ កាលានុវត្តភាពទាំងនេះកំពុងត្រូវបានសិក្សា និងវិភាគយ៉ាងហ្មត់ចត់ នៅក្នុងការរៀបចំផែនការមេអភិវឌ្ឍន៍វិស័យថាមពលនៅកម្ពុជា ២០២១-២០៤០ ដែលក្នុងនោះ ប្រសិទ្ធភាពថាមពល គឺជាសសរស្តម្ភស្នូលមួយនៃគោលនយោបាយអភិវឌ្ឍន៍ថាមពលនៅកម្ពុជា ទាំងក្នុងបរិបទសន្តិសុខថាមពល និងក្នុងបរិបទចីរភាពថាមពល។

ទស្សនាទាននៃប្រសិទ្ធភាពថាមពលនេះ មិនមែនជាការសន្សំសំចៃថាមពលដោយកាត់បន្ថយសកម្មភាពសេដ្ឋកិច្ច ផលិតភាព ផាសុកភាព និងសុខុមាលភាពរបស់អ្នកប្រើប្រាស់ថាមពលឡើយ។ គោលបំណងនៃប្រសិទ្ធភាពថាមពល គឺដើម្បីផ្តល់នូវទិន្នផលដូចមុន ឬប្រសើរជាងមុន ដោយការប្រើប្រាស់ថាមពលតិចជាងមុន។ ជាការពិត ប្រសិទ្ធភាពថាមពលអាចដើរតួនាទីក្នុងការចូលរួមសម្រេចគោលដៅរបស់វិស័យថាមពលកម្ពុជា ទាំងការផ្តល់ថាមពលឱ្យបានគ្រប់គ្រាន់ ប្រកបដោយសុវត្ថិភាព ស្ថេរភាព និងមានតម្លៃសមរម្យផង និងទាំងការអភិវឌ្ឍប្រកបដោយចីរភាពផង។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាមានភាពចាំបាច់ដាក់ចេញនូវក្របខណ្ឌគោលនយោបាយ ដើម្បីជំរុញ គាំទ្រ និងពន្លឿនការអនុវត្តប្រសិទ្ធភាពថាមពលនៅក្នុងប្រទេសរបស់យើង។

**គោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០** ត្រូវបានរៀបចំឡើងដោយផ្អែកលើការធ្វើវិវេចនាឧត្តមានុវត្តន៍អន្តរជាតិយ៉ាងហ្មត់ចត់ និងដោយការគិតគូរពីកាលៈទេសៈជាក់ស្តែងរបស់ប្រទេសយើង ទាំងការប្រើប្រាស់ថាមពលកន្លងមក និងទិសដៅទៅអនាគត ទាំងលទ្ធភាពទទួលបានបច្ចេកវិទ្យាប្រសិទ្ធភាពថាមពលដែលមានថ្លៃសមរម្យ និងទាំងសេចក្តីត្រូវការថវិកាក្នុងការវិនិយោគ។

**គោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០** កំណត់ចក្ខុវិស័យរបស់ខ្លួន "កែប្រែការប្រើប្រាស់ថាមពលនៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ដើម្បីលើកកម្ពស់សេដ្ឋកិច្ចជាតិឱ្យរឹងមាំ រស់រវើក ប្រកួតប្រជែង និងការអភិវឌ្ឍប្រកបដោយចីរភាព" ដែលអំណោយផលដល់កំណើនសេដ្ឋកិច្ច និងបរិយាបន្នសង្គម ធានាបាននូវភាពប្រកួតប្រជែងនៃធុរកិច្ច និងលើកកម្ពស់សុខុមាលភាពនៃការរស់នៅរបស់ប្រជាជន ទន្ទឹមនឹងនេះក៏ធានា និងរក្សាបាននូវការអភិរក្សធនធានធម្មជាតិដ៏មានតម្លៃរបស់ប្រទេសផងដែរ។

គោលនយោបាយនេះក៏កំណត់នូវគោលដៅប្រកបដោយមហិច្ឆតាមួយផងដែរ ក្នុងការកាត់បន្ថយការប្រើប្រាស់ថាមពលតាមរយៈវិធានការប្រសិទ្ធភាពថាមពលយ៉ាងតិចឱ្យបាន១៩% ត្រឹមឆ្នាំ២០៣០ ដោយធៀបនឹងសេណារីយ៉ូគ្មានវិធានការគោលនយោបាយប្រសិទ្ធភាពថាមពល ឬសេណារីយ៉ូធុរកិច្ចធម្មតា។ គោលដៅនេះត្រូវបានបែងចែកសម្រាប់អនុវត្តនៅក្នុងវិស័យប្រើប្រាស់ថាមពលសំខាន់ៗមានជាអាទិ៍៖ ឧស្សាហកម្ម អគារពាណិជ្ជកម្ម និងអគារផ្សេងទៀត អគារលំនៅឋាន សេវាសាធារណៈ និងដឹកជញ្ជូន។

ការដាក់ចេញ**គោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០** នឹងជួយគាំទ្រដល់ការងើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជាដែលរងផលប៉ះពាល់ដោយជំងឺឆ្លងកូវីដ-១៩ ពីព្រោះថាការងារប្រសិទ្ធភាពថាមពលអាចនាំមកនូវកាលានុវត្តភាពធុរកិច្ចថ្មីៗ ការជំរុញការងារច្នៃប្រតិដ្ឋនៅក្នុងវិស័យជាក់លាក់មួយចំនួន (ក្នុងទម្រង់ជាបច្ចេកវិទ្យា សេវាកម្ម និងការរចនាថ្មី) ហើយជាលទ្ធផល នឹងបង្កើតឱ្យមានការងារថ្មី ដែលភាគច្រើននៃការងារទាំងនោះស្ថិតក្នុងវិស័យបច្ចេកវិទ្យាទំនើបៗ។ ប្រសិទ្ធភាពថាមពលក៏នឹងជួយឱ្យអ្នកប្រើប្រាស់ថាមពលយល់ដឹងអំពីការសន្សំសំចៃថាមពល ដែលនឹងរួមចំណែកជួយកាត់បន្ថយថ្លៃចំណាយលើការប្រើប្រាស់ថាមពលរបស់ពួកគេ។ មិនតែប៉ុណ្ណោះ ការបន្ថយថ្លៃថាមពល ដែលអាចសម្រេចបានក្នុងរយៈពេលវែង តាមរយៈការអនុវត្តប្រសិទ្ធភាពថាមពលកាន់តែទូលំទូលាយ ក៏នឹងជួយសម្រួល និងពន្លឿនអត្រាទទួលបានសេវាថាមពលទំនើបជូនដល់ប្រជាពលរដ្ឋដែលមិនទាន់បានទទួលសេវាថាមពលនេះបានថែមទៀតផង។

គោលនយោបាយនេះ គ្រាន់តែជាការចាប់ផ្តើមនៃដំណើរដ៏វែងដើម្បីប្រែក្លាយប្រទេសយើងឱ្យទៅជាប្រទេសមួយដែលមានការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាពកាន់តែខ្ពស់ ពីព្រោះបន្ទាប់ពីសម្រេចបានគោលនយោបាយនេះ យើងនៅមានគោលនយោបាយ បទប្បញ្ញត្តិ និងគោលការណ៍ណែនាំផ្សេងៗជាច្រើនទៀត ដែលត្រូវរៀបចំដើម្បីបង្កើតនូវបរិយាកាសអំណោយផលបន្ថែមទៀត សម្រាប់ការវិនិយោគបង្កើនប្រសិទ្ធភាពថាមពលក្នុងវិស័យប្រើប្រាស់ថាមពល។ ការយល់ដឹង ការបង្កើនសមត្ថភាពធនធានមនុស្ស ការបែងចែកតួនាទី និងភារកិច្ច និងការតាមដានវឌ្ឍនភាព ក៏ជាកត្តាគន្លឹះកំណត់ភាពជោគជ័យនៃការអនុវត្តគោលនយោបាយនេះផងដែរ។ ហេតុដូច្នេះហើយទើបក្នុងគោលនយោបាយនេះ បានចែងយ៉ាងលម្អិតអំពីការកំណត់តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ស្ថាប័នរាជរដ្ឋាភិបាលពាក់ព័ន្ធក្នុងការអនុវត្តគោលនយោបាយនេះ និងចែងអំពីតម្រូវការចាំបាច់នានាក្នុងការបង្កើនការយល់ដឹង ការអភិវឌ្ឍចំណេះដឹង និងសមត្ថភាពនៃធនធានមនុស្សរបស់យើង ដែលជាឧបករណ៍សម្រាប់ទ្រទ្រង់ការផ្លាស់ប្តូរឈានឆ្ពោះទៅរកការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាពកាន់តែខ្ពស់ នៅក្នុងប្រទេសយើង។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណនិងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់មន្ត្រីក្រសួងរ៉ែ និងថាមពល ដែលបានចូលរួមរៀបចំគោលនយោបាយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមានគុណភាពខ្ពស់មួយនេះ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់

ដែលបានរួមចំណែកផ្តល់នូវធាតុចូលដ៏មានសារៈសំខាន់ដើម្បីកែលម្អ និងធ្វើឱ្យឯកសារនេះកាន់តែមានភាពល្អប្រសើរ ពេញលេញ និងគ្រប់ជ្រុងជ្រោយ។ ខ្ញុំសង្ឃឹម និងជឿជាក់ថា ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់នឹងពង្រឹងកិច្ចសហការបន្តទៀត ដើម្បីអនុវត្តគោលនយោបាយនេះឱ្យបានជោគជ័យ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរដល់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានផ្តល់ជំនួយបច្ចេកទេសសម្រាប់ការរៀបចំគោលនយោបាយនេះ ក៏ដូចជាសម្រាប់ការបន្តគាំទ្រការអភិវឌ្ឍវិស័យថាមពលនៅព្រះរាជាណាចក្រកម្ពុជា។ ជាចុងក្រោយ ខ្ញុំបាទសូមគោរពសម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបានប្រគល់ភារកិច្ចដ៏សំខាន់នេះ ឱ្យក្រសួងរ៉ែ និងថាមពល ជាស្ថាប័នដឹកនាំក្នុងការរៀបចំ **គោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល២០២២-២០៣០** ដ៏មានតម្លៃមួយនេះ សម្រាប់ប្រទេសជាតិយើង។

ថ្ងៃ ពុធ ២ រោច ខែ អស្សុជ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ តុលា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**ស៊ុយ សែម**

# អក្សរកាត់

| អក្សរកាត់ខ្មែរ | ពាក្យគន្លឹះជាភាសាខ្មែរ |
|---|---|
| ក.ដ.ន.ស. | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ក.ជ.អ.ច. | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| ក.ប.ស. | ក្រសួងបរិស្ថាន |
| ក.រ.ថ. | ក្រសួងរ៉ែ និងថាមពល |
| ក.ស.ដ. | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| ក.ស.ហ.វ. | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| ក.អ.ក. | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| ក.ឧ.វ.ប.ន. | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| គ.ជ.ប្រ.ថ. | គោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល |
| គ.ស.ហ. | គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ប.គ.ប.ថ.អ. | បទដ្ឋានគុណផលការប្រើប្រាស់ថាមពលអប្បបរមា |
| ប.គ.ប.ថ. | បទដ្ឋានគុណផលការប្រើប្រាស់ថាមពល |
| ប.ប.ថ. | ប្រពលភាពប្រើប្រាស់ថាមពល |
| ផ.យ.ថ. | ផែនការយុទ្ធសាស្ត្រថវិកា |
| ផ.ស.ប.ថ.វ. | ផែនការសកម្មភាពប្រសិទ្ធភាពថាមពលតាមវិស័យ |
| យ.អ. | យានយន្តអគ្គិសនី |
| វ.ថ.អ. | វិធានថាមពលសម្រាប់អគារ និងសំណង់ |
| អ.ក. | អគ្គិសនីកម្ពុជា |
| អាស៊ាន | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| អ.ឧ. | អគ្គនាយកដ្ឋានឧស្សាហកម្ម |

# មាតិកា


បុព្វកថា.......................................................................................................................... i

អារម្ភកថា ....................................................................................................................... iii

អក្សរកាត់ ....................................................................................................................... vii

មាតិកា.......................................................................................................................... viii

ខ្លឹមសារសង្ខេប ................................................................................................................ ix

១- សេចក្តីផ្តើម ................................................................................................................... ១

២- ស្ថានភាពនៃការប្រើប្រាស់ថាមពល និងប្រសិទ្ធភាពថាមពល នៅកម្ពុជា ........................................... ៦

៣- ចក្ខុវិស័យ ................................................................................................................... ១០

៤- គោលបំណង និងគោលដៅ.............................................................................................. ១០

៥- ក្របខណ្ឌយុទ្ធសាស្ត្រ ....................................................................................................... ១១

៦- វិធានការគោលនយោបាយ .............................................................................................. ១៥

៧- យន្តការសម្រាប់ដឹកនាំ សម្របសម្រួល និងអនុវត្ត ................................................................. ២៩

៨- ការបង្កើតប្រព័ន្ធតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ................................ ៤៧

៩- សេចក្តីសន្និដ្ឋាន ............................................................................................................ ៥៣

ឧបសម្ព័ន្ធ ១- សទ្ធានុក្រមគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល....................................... ៥៥

២០២២-២០៣០ ............................................................................................................. ៥៥

ឧបសម្ព័ន្ធ ២- វិធានការគោលនយោបាយ និងផែនការសកម្មភាព .................................................... ៦២

ឧបសម្ព័ន្ធ ៣- សូចនាករសម្រាប់តាមដានការអនុវត្តគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល
២០២២-២០៣០ ............................................................................................................. ៧៣

# ខ្លឹមសារសង្ខេប

ដើម្បីចូលរួមចំណែកសម្រេចបាននូវគោលដៅរបស់កម្ពុជា ក្នុងការប្រែក្លាយទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងមានចំណូលខ្ពស់នៅឆ្នាំ២០៥០ រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំ **"គោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០"** នេះឡើង ក្នុងចក្ខុវិស័យ "កែប្រែការប្រើប្រាស់ថាមពលនៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ដើម្បីជួយលើកកម្ពស់សេដ្ឋកិច្ចជាតិឱ្យរឹងមាំ រស់រវើក ប្រកួតប្រជែង និងការអភិវឌ្ឍប្រកបដោយចីរភាព"។ គោលនយោបាយនេះ បង្កើតឡើងជាក្របខណ្ឌរួម និង ជាឯកសារយោងសម្រាប់ការអភិវឌ្ឍប្រសិទ្ធភាពថាមពលនៅកម្ពុជា ដែលមានគោលដៅចំនួន ៦ គឺៈ (ទី១) បង្កើតមូលដ្ឋានគោលនយោបាយ ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិ សម្រាប់ចាត់វិធានការគោលនយោបាយ និង ដាក់កម្មវិធីប្រសិទ្ធភាពថាមពលជាក់លាក់តាមវិស័យ (ទី២) កំណត់តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ស្ថាប័នពាក់ព័ន្ធ ដើម្បីឱ្យស្ថាប័នទាំងនោះ អាចអនុវត្តបទប្បញ្ញត្តិនៃគោលនយោបាយនេះ រួមទាំងយន្តការសម្របសម្រួល។ (ទី៣) កំណត់គោលដៅដែលអាចវាស់វែងបាន សម្រាប់ការអនុវត្តការងារប្រសិទ្ធភាពថាមពលនៅកម្ពុជា ដែលត្រូវសម្រេចឱ្យបាននៅឆ្នាំ២០៣០។ (ទី៤) ចែងអំពីវិធានការ ឧបករណ៍ និងយន្តការ ដើម្បីធានាជំនះនូវឧបសគ្គរាំងដល់ដំណើរការអនុវត្តការងារប្រសិទ្ធភាពថាមពលប្រកបដោយប្រសិទ្ធភាព។ (ទី៥) បង្កើតក្របខណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃរួម ដែលមានខ្នាតវាស់ត្រឹមត្រូវ ដើម្បីតាមដានវឌ្ឍនភាពនៃការអនុវត្ត និង(ទី៦) ផ្តល់អាទិភាពដល់កត្តាជំរុញការផ្លាស់ប្តូរការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស និងការផ្សព្វផ្សាយចំណេះដឹងអំពីប្រសិទ្ធភាពថាមពល។

គោលនយោបាយនេះកំណត់ការកាត់បន្ថយការប្រើប្រាស់ថាមពលសរុប (ថាមពលកម្តៅ និងអគ្គិសនី) យ៉ាងតិច ១៩% នៅឆ្នាំ២០៣០ ធៀបនឹងសេណារីយ៉ូ "ធុរកិច្ចធម្មតា" (BAU) គឺពី ៨៩.៨៣៧ GWh មក ៧២.៤៧០ GWh។ សម្រាប់វិស័យប្រើប្រាស់ថាមពលសំខាន់ៗ គោលនយោបាយនេះ មានគោលដៅជាក់លាក់ដើម្បីកាត់បន្ថយការប្រើប្រាស់ថាមពលនៅឆ្នាំ២០៣០ ធៀបនឹងសេណារីយ៉ូ "ធុរកិច្ចធម្មតា" (BAU) យ៉ាងហោចណាស់ឱ្យបានៈ

- ២០% នៅក្នុងវិស័យឧស្សាហកម្ម គឺពី ៣៨.៦០០ GWh មក ៣០.៨៨០ GWh
- ៣៤% នៅក្នុងវិស័យអគារលំនៅឋាន គឺពី ១៧.៩៨១ GWh មក ១១.៨២៦ GWh
- ២៥% នៅក្នុងវិស័យអគារពាណិជ្ជកម្ម និង អគារផ្សេងទៀត (រាប់ទាំងអគារសាធារណៈ) គឺពី ៨.៥៥២ GWh មក ៦.៤៣១ GWh
- ២៩% នៅក្នុងវិស័យសេវាសាធារណៈ គឺពី ៤២ GWh មក ៣០ GWh
- ៥% នៅក្នុងវិស័យដឹកជញ្ជូន គឺពី ២៤.៦៦២ GWh មក ២៣.៣៨៣ GWh។

គោលនយោបាយនេះទទួលស្គាល់ថា ដើម្បីសម្រេចបានគោលដៅទាំងនេះ ទាមទារឱ្យមានវិធានការដាក់លាក់ និងឧបករណ៍ជំនួយគ្រប់គ្រាន់តាមវិស័យ ដែលអាចជំរុញការអនុវត្តវិធានការគោលនយោបាយប្រសិទ្ធភាពថាមពលដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងសាធារណៈ និងឯកជន។ គោលនយោបាយនេះកំណត់នូវវិធានការ និងឧបករណ៍ប្រសិទ្ធភាពថាមពលជាអាទិភាពដែលត្រូវដាក់បញ្ចូល ឬបង្កើតក្នុងវិស័យនៃការប្រើប្រាស់ថាមពលរួមមានដូចខាងក្រោម៖

- **វិស័យឧស្សាហកម្ម៖** ការដាក់បញ្ចូលបទដ្ឋានគុណផលការប្រើប្រាស់ថាមពល សម្រាប់កិច្ចប្រតិបត្តិការ និងឧបករណ៍ថាមពលសំខាន់ៗ។
- **វិស័យអគារ** (រួមមាន អគារលំនៅឋាន អគារពាណិជ្ជកម្ម និងអគារសាធារណៈ)៖ ការបង្កើត និងការអនុវត្តវិធានថាមពលសម្រាប់អគារ រួមជាមួយនឹងគោលការណ៍ណែនាំ និងវិញ្ញាបនបត្រកម្មអគារបៃតង និងវិញ្ញាបនបត្រចាំបាច់ៗនានាជាលក្ខណៈរួម។
- **វិស័យអគារលំនៅឋាន៖** ការបង្កើតកម្មវិធីបទដ្ឋាន និងការបិទស្លាកសញ្ញា (ប&ប.ស) សម្រាប់ឧបករណ៍ប្រើប្រាស់ និងគ្រឿងបរិក្ខារថាមពល រួមមានការដាក់បញ្ចូល "បទដ្ឋានគុណផលការប្រើប្រាស់ថាមពលអប្បបរមា" និងការលើកទឹកចិត្តដើម្បីពន្លឿនការផ្លាស់ប្តូរទៅប្រើប្រាស់ចង្ក្រានស្អាតនិងមានប្រសិទ្ធភាពជាងមុន។
- **វិស័យដឹកជញ្ជូន៖** ការជំរុញអគ្គិសនីកម្ម និងការប្រើថាមពលបៃតងផ្សេងទៀតក្នុងការដឹកជញ្ជូន ការដាក់បញ្ចូលស្តង់ដារប្រសិទ្ធភាពប្រេង និងការផ្លាស់ប្តូរគំរូដឹកជញ្ជូនទៅជាការដឹកជញ្ជូនសាធារណៈវិញ។
- **វិស័យសេវាសាធារណៈ៖** ការប្តូរពីការប្រើអំពូលធម្មតាទៅប្រើអំពូលអិលអ៊ីឌី (LED) ដែលមានប្រសិទ្ធភាពខ្ពស់សម្រាប់ការបំភ្លឺផ្លូវ និងការជំនួសម៉ាស៊ីនភ្លើងម៉ាស៊ូតដែលគ្មានប្រសិទ្ធភាព មកប្រើប្រព័ន្ធថាមពលដែលមានប្រសិទ្ធភាពជាងវិញសម្រាប់ការបូមទឹកកខ្វក់។
- **វិស័យចម្រុះសម្រាប់ទាំងឧស្សាហកម្ម និងអគារ៖** ការបង្កើតកម្មវិធីគ្រប់គ្រងថាមពលដោយផ្អែកលើការកំណត់អត្តសញ្ញាណ "អ្នកប្រើប្រាស់ថាមពលមុខសញ្ញា" និងលក្ខខណ្ឌតម្រូវលើការធ្វើរបាយការណ៍ថាមពល ក៏ដូចជាការបង្កើតក្របខណ្ឌសម្រាប់ការពង្រឹង និងវាយតម្លៃក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល។

ការសម្រេចបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅនៃគោលនយោបាយនេះ តម្រូវឱ្យមានការដឹកនាំដ៏រឹងមាំរបស់រាជរដ្ឋាភិបាលកម្ពុជាទាំងមូល។ ដើម្បីឈានដល់ចំណុចនេះ គោលនយោបាយនេះបង្កើតក្របខណ្ឌអភិបាលកិច្ចដែលកំណត់តួនាទី ភារកិច្ច និងការទទួលខុសត្រូវជាក់លាក់ចំពោះក្រសួងស្ថាប័នផ្សេងៗ រួមទាំងយន្តការសម្របសម្រួលផងដែរ។ ក្របខណ្ឌនេះកំណត់ថាគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ.) មានភារកិច្ចដឹកនាំ ត្រួតពិនិត្យ តាមដាន សម្របសម្រួល និងផ្តល់ការតម្រង់ទិសជាគោលនយោបាយឱ្យ "គណៈកម្មាធិការជាតិប្រសិទ្ធភាពថាមពល" ដែលត្រូវបានបង្កើតឡើងជាអង្គភាព

សម្របសម្រួលលើការងារប្រសិទ្ធភាពថាមពលទាំងអស់ដឹកនាំដោយក្រសួងរ៉ែ និងថាមពល និងមានតំណាងមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ។ គណៈកម្មាធិការជាតិប្រសិទ្ធភាពថាមពលត្រូវរាយការណ៍ទៅគ.ស.ហ. និងត្រូវអនុវត្តតាមសេចក្តីសម្រេចរបស់គ.ស.ហ.ដើម្បីដោះស្រាយបញ្ហាសំខាន់ៗ និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តការងារ។

ក្របខណ្ឌអភិបាលកិច្ចដែលបានដាក់ចេញនៅក្នុងគោលនយោបាយនេះ ផ្តល់សិទ្ធិអំណាចពេញលេញដល់ក្រសួងរ៉ែ និងថាមពល ក្នុងនាមជា "ស្ថាប័នបង្គោល" នៃគោលនយោបាយនេះ។ ក្រសួងរ៉ែ និងថាមពលនឹងដើរតួនាទីនាំមុខគេលើការអភិវឌ្ឍប្រសិទ្ធភាពថាមពលនៅកម្ពុជា និង ទទួលខុសត្រូវចំពោះការត្រួតពិនិត្យការសម្របសម្រួល និងការអនុវត្តបទប្បញ្ញត្តិនៃគោលនយោបាយនេះ។ គោលនយោបាយនេះ ក៏បង្កើតឱ្យមាន "ស្ថាប័នដៃគូ" ជាស្ថាប័នរដ្ឋាភិបាលដែលមានតួនាទីលើកកម្ពស់ប្រសិទ្ធភាពថាមពលនៅកម្ពុជាជាមួយស្ថាប័នបង្គោល។ ដើម្បីសម្រេចបាននូវភារកិច្ចរបស់ខ្លួន គណៈកម្មាធិការជាតិប្រសិទ្ធភាពថាមពលមានស្ថាប័នដៃគូតាមវិស័យជួយគាំទ្រ ដោយទទួលបន្ទុកការងារប្រសិទ្ធភាពថាមពលតាមផ្នែករៀងៗខ្លួន។ ស្ថាប័នដៃគូទាំងនោះមានក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ក.ឧ.វ.ប.ន.) សម្រាប់វិស័យ ឧស្សាហកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ក.ដ.ន.ស.) សម្រាប់វិស័យអគារ និងក្រសួងសាធារណការនិងដឹកជញ្ជូន (ក.ស.ដ.) សម្រាប់វិស័យសេវាសាធារណៈ និងដឹកជញ្ជូន។ ការទទួលខុសត្រូវចម្បងរបស់ក្រសួង ស្ថាប័នទាំងនេះ គឺដើម្បីបញ្ជ្រាបប្រសិទ្ធភាពថាមពលទៅក្នុងដំណើរការនៃការរៀបចំផែនការតាមវិស័យរបស់ខ្លួន និងចូលរួមក្នុងការអនុវត្តការងារប្រសិទ្ធភាពថាមពល។ ស្ថាប័នដៃគូទាំងនេះ នឹងទទួលខុសត្រូវលើការបង្កើត និងអនុវត្ត "ផែនការសកម្មភាពប្រសិទ្ធភាពថាមពលតាមវិស័យ" ដែលនឹងត្រូវរៀបចំឡើងក្រោមការសម្របសម្រួល និងការណែនាំផ្នែកបច្ចេកទេសពីស្ថាប័នបង្គោល។ នៅកម្រិតថ្នាក់ក្រោមជាតិ រដ្ឋបាលរាជធានីខេត្ត ត្រូវដាក់បញ្ចូលការគិតគូរអំពីការងារប្រសិទ្ធភាពថាមពលទៅក្នុងផែនការរាជធានី ខេត្តក្រុងបៃតង ឬផែនការរាជធានី ខេត្តក្រុងប្រកបដោយចីរភាពរបស់ខ្លួន។ តួនាទី និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នដៃគូនីមួយៗ មានចែងលម្អិតនៅក្នុងគោលនយោបាយនេះ។ ក្នុងនោះផងដែរ ក្របខណ្ឌអភិបាលកិច្ចដែលបានរំលេចនៅក្នុងគោលនយោបាយនេះ ក៏បានចែងយ៉ាងច្បាស់អំពីបទប្បញ្ញត្តិសម្រាប់ឱ្យក្រសួងស្ថាប័នដៃគូ ចាត់តាំងជនបង្គោលផ្នែកការងារប្រសិទ្ធភាពថាមពលរបស់ខ្លួនដើម្បីជួយបំពេញភារកិច្ចរបស់ក្រសួង ស្ថាប័នសាមីស្របតាមគោលនយោបាយនេះ។

គោលនយោបាយនេះ ក៏កំណត់នូវសំណុំឧបករណ៍ច្បាប់ រដ្ឋបាល និងហិរញ្ញវត្ថុដែលអាចត្រូវបានប្រើដោយរាជរដ្ឋាភិបាល ដើម្បីសម្រេចគោលបំណងនៃគោលនយោបាយនេះផងដែរ។ ក្នុងចំណោមឧបករណ៍ទាំងនេះគោលនយោបាយនេះ ទទួលស្គាល់តួនាទីនៃយន្តការហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រតិដ្ឋដូចជា មូលនិធិប្រសិទ្ធភាពថាមពលវិលជុំ និងមូលនិធិហិរញ្ញវត្ថុបៃតងពិសេសជាដើម ថាជាកត្តាជំរុញការងារប្រសិទ្ធភាពថាមពលដែលពាក់ព័ន្ធនឹងការបង្កើតមូលនិធិគាំទ្រដល់ការវិនិយោគរបស់វិស័យឯកជនលើគម្រោង ឬការងារប្រសិទ្ធភាពថាមពល៕

# ១- សេចក្តីផ្តើម

## ១.១. ភាពចាំបាច់នៃគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០

ប្រសិទ្ធភាពថាមពល គឺជាការប្រើប្រាស់ថាមពលតិចជាងមុន ប៉ុន្តែរក្សាបានទិន្នផលដូចមុន ឬប្រសើរជាងមុន។ តាមនិយមន័យនេះ ប្រសិទ្ធភាពថាមពលធ្វើឱ្យ "**ទិន្នផល**" នៃការប្រើប្រាស់ថាមពលមួយឯកតាកើនឡើងច្រើនជាងមុន ដូច្នេះ ប្រសិទ្ធភាពថាមពល គឺជាវិធីសាស្ត្រដ៏សំខាន់មួយក្នុងការកាត់បន្ថយតម្រូវការថាមពល ការសន្សំសំចៃ និងកាត់បន្ថយថ្លៃចំណាយលើការប្រើប្រាស់ថាមពល ការគាំទ្រដល់ការដោះស្រាយបញ្ហាសន្តិសុខថាមពល និងបញ្ហាចីរភាពបរិស្ថាននៃការផ្គត់ផ្គង់ថាមពល។

កម្ពុជានៅមិនទាន់បានប្រើប្រាស់សក្តានុពលប្រសិទ្ធភាពថាមពលច្រើននៅឡើយទេ ដូច្នេះការប្រើប្រាស់កាលានុវត្តភាពទាំងនេះ អាចនឹងនាំមកនូវអត្ថប្រយោជន៍ជាច្រើន ជាពិសេសអត្ថប្រយោជន៍ដូចខាងក្រោម៖

១. **ការពង្រឹងសន្តិសុខថាមពលឱ្យកាន់តែប្រសើរឡើង៖** ការបង្កើនប្រសិទ្ធភាពថាមពលនឹងជួយពង្រឹងសន្តិសុខថាមពលជាតិឱ្យកាន់តែប្រសើរឡើង តាមរយៈការកាត់បន្ថយតម្រូវការប្រើប្រាស់ថាមពល ដែលធ្វើឱ្យដំណើរការ និងការផ្តល់សេវាថាមពលកាន់តែប្រសើ និងការពឹងផ្អែកលើការនាំចូលថាមពលកាន់តែថយចុះ។

២. **ការកាត់បន្ថយថ្លៃចំណាយលើថាមពល និងការបង្កើនភាពប្រកួតប្រជែងសេដ្ឋកិច្ចឱ្យខ្ពស់ជាងមុន៖** ការកាត់បន្ថយតម្រូវការថាមពលជាបន្តបន្ទាប់ដោយប្រសិទ្ធភាពថាមពលក្នុងរយៈពេលមធ្យមទៅវែង នឹងជួយធ្វើឱ្យថ្លៃចំណាយលើថាមពលថយចុះ តាមរយៈការកាត់បន្ថយការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធថាមពល និងការនាំចូលថាមពលដែលមានថ្លៃខ្ពស់។ ការកាត់បន្ថយថ្លៃចំណាយលើថាមពលនេះ នឹងជះឥទ្ធិពលជាវិជ្ជមានដល់ភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ ជាពិសេសសម្រាប់សហគ្រាស ឧស្សាហកម្ម និងពាណិជ្ជកម្ម។

៣. **ការកាត់បន្ថយការចំណាយលើការរស់នៅ និងភាពក្រីក្រ៖** ការកាត់បន្ថយបរិមាណថាមពលប្រើប្រាស់ដោយប្រសិទ្ធភាពថាមពល អាចជួយកាត់បន្ថយបន្ទុកថ្លៃចំណាយលើការប្រើប្រាស់ថាមពល និងអាចរំដោះថវិកាខ្លះយកទៅបម្រើសកម្មភាពសេដ្ឋកិច្ចផ្សេងៗទៀតដើម្បីលើកកម្ពស់កម្រិតជីវភាពរស់នៅ។

៤. **ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការបំពុលបរិស្ថានផ្សេងៗ៖** ប្រសិទ្ធភាពថាមពលនឹងកាត់បន្ថយតម្រូវការថាមពលដែលជាមួយគ្នានោះ ការប្រើប្រាស់ឥន្ធនៈហ្វូស៊ីលក៏ត្រូវបានកាត់បន្ថយផងដែរ។ ការណ៍នេះមិនត្រឹមតែនាំឱ្យការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ថយចុះ ដែលជាការជួយគាំទ្រកម្ពុជាក្នុងការបំពេញការ

ប្តេជ្ញាចិត្តរបស់ខ្លួនក្នុងក្របខណ្ឌកិច្ចព្រមព្រៀងទីក្រុងប៉ារីសប៉ុណ្ណោះទេ ប៉ុន្តែក៏ជួយកាត់បន្ថយការបំពុលបរិស្ថាននៅក្នុងស្រុក និងជួយលើកកម្ពស់សុខភាពនិងសុខុមាលភាពរបស់ប្រជាជនក្នុងមូលដ្ឋានផងដែរ។

៥. **ការបង្កើតទីផ្សារថ្មីសម្រាប់បច្ចេកវិទ្យា និងសេវាកម្មប្រសិទ្ធភាពថាមពល៖** ការអនុវត្តវិធានការប្រសិទ្ធភាពថាមពល នាំមកនូវវិនិយោគទុនថ្មីៗបន្ថែមទៀតក្នុងប្រទេសកម្ពុជា ដែលនឹងជួយបង្កើតបាននូវការងារជាច្រើនបន្ថែមទៀត។

ដើម្បីជំរុញការទទួលយកការងារប្រសិទ្ធភាពថាមពល និងទាញយកផលប្រយោជន៍ជាច្រើនពីការងារនេះ ចាំបាច់ត្រូវបង្កើតឱ្យមានគោលនយោបាយ និងក្របខណ្ឌគតិយុត្តពាក់ព័ន្ធ។ គោលនយោបាយនេះ ក៏រំលេចផងដែរនូវក្របខណ្ឌរួមអំពីគោលនយោបាយ និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងប្រសិទ្ធភាពថាមពលក្នុងវិស័យផ្សេងទៀតដែលត្រូវរៀបចំ និងអនុម័តនាពេលអនាគតផងដែរ។

## ១.២. ប្រសិទ្ធភាពថាមពលជាមធ្យោបាយជួយគាំទ្រដល់គោលនយោបាយ និង យុទ្ធសាស្ត្រផ្សេងទៀតរបស់កម្ពុជា

កន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់តួនាទីប្រសិទ្ធភាពថាមពល អាចចូលរួមជួយសម្រេចគោលបំណងនៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា។ គោលនយោបាយជាតិស្តីពីវិស័យថាមពលដែលបានអនុម័តកាលពីខែតុលា ឆ្នាំ១៩៩៤បានកំណត់អំពីតម្រូវការឱ្យមានសេវាកម្មថាមពលមួយអាចទុកចិត្តបាន និងមានថ្លៃសមរម្យ និងជាមធ្យោបាយដើម្បីគាំទ្រដល់ការធ្វើឱ្យកម្ពុជាក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ គោលនយោបាយនេះ អាចជួយគាំទ្រដល់ការសម្រេចគោលបំណង និងគោលដៅនៃគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិមួយចំនួនផ្សេងទៀត ដូចជា៖

- **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤** ដែលត្រូវបានអនុម័ត នៅខែកញ្ញា ឆ្នាំ២០១៨ កំណត់គោលដៅយុទ្ធសាស្ត្រ និងវិស័យអាទិភាព ដើម្បីគាំទ្រប្រទេសកម្ពុជាឱ្យសម្រេចបានចក្ខុវិស័យរបស់ខ្លួនដើម្បីក្លាយជាប្រទេសមានចំណូលខ្ពស់ប្រកបដោយចីរភាព និងបរិយាបន្ន នៅឆ្នាំ២០៥០។ យុទ្ធសាស្ត្រនេះកំណត់យក "ប្រសិទ្ធភាព" ជាគោលដៅសំខាន់មួយក្នុងចំណោមគោលដៅអាទិភាពទាំងបួន ដែលបីទៀតគឺ កំណើនការងារ និងសមធម៌។ យុទ្ធសាស្ត្រនេះ ក៏បង្ហាញផងដែរនូវសំណុំវិស័យអាទិភាពដែលអាចជួយគាំទ្រដោយការអនុវត្តប្រសិទ្ធភាពថាមពលឱ្យបានទូលំទូលាយ ដូចជាជួយលើកកម្ពស់ការប្រកួតប្រជែងផ្នែកធុរកិច្ច ជួយដល់ការលើកកម្ពស់នវានុវត្តន៍ឧស្សាហកម្ម និងសហគ្រិនភាព និងជួយដល់ការគ្រប់គ្រងធនធានធម្មជាតិ

ប្រកបដោយចីរភាព។ យុទ្ធសាស្ត្រចតុកោណខាងលើនេះ លើកឡើងអំពីការប្រឈម ជាមួយថ្លៃថាមពលខ្ពស់ និងភាពចាំបាច់ដើម្បីធានាដល់សន្តិសុខថាមពលក្នុងរយៈពេលវែង ដែលបញ្ហាទាំងពីរនេះ អាចនឹងត្រូវបានដោះស្រាយតាមរយៈគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០ នេះ។

- **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣** ដែលត្រូវបានអនុម័តនៅខែកញ្ញា ឆ្នាំ២០១៩ គឺជាផែនការគាំទ្រការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងកំណត់អាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី៦។ ក្នុងចំណោមគោលនយោបាយវិស័យថាមពល ការលើកកម្ពស់ និងការអភិវឌ្ឍប្រសិទ្ធភាពថាមពល ព្រមទាំងការសន្សំសំចៃថាមពល ត្រូវបានកំណត់យ៉ាងច្បាស់ថាជាគម្រោងអាទិភាពរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលអាទិភាពទាំងនេះអាចត្រូវបានគាំទ្របន្ថែមទៀតតាមរយៈគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០។
- **ច្បាប់ស្តីពីអគ្គិសនី** ដែលត្រូវបានអនុម័តនៅឆ្នាំ២០០១ និងត្រូវបានធ្វើវិសោធនកម្មនៅឆ្នាំ២០០៧ និងឆ្នាំ២០១៥ ដែលបានបង្កើតមូលដ្ឋានសម្រាប់ក្របខណ្ឌគតិយុត្ត និងគ្រប់គ្រងសកម្មភាពទាក់ទងនឹងការផ្គត់ផ្គង់អគ្គិសនី និងសេវាកម្មពាក់ព័ន្ធ។ គោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០ នឹងជួយបំពេញបន្ថែមច្បាប់ស្តីពីអគ្គិសនី តាមរយៈការបង្កើតក្របខណ្ឌមួយដែលគ្របដណ្តប់ជាពិសេសលើសកម្មភាពប្រសិទ្ធភាពថាមពល។
- **ការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ** ដែលបានធ្វើបច្ចុប្បន្នភាពជាថ្មី ស្របតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ និងបានដាក់ជាផ្លូវការទៅអនុសញ្ញាក្របខណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ កាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ដោយបានកំណត់អំពីកម្មវិធី ផែនការ និងសកម្មភាពរបស់ជាតិក្នុងការកាត់បន្ថយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ រាប់បញ្ចូលទាំងសេណារីយ៉ូ និងគោលដៅសម្រាប់ឆ្នាំ២០៣០។ នៅក្នុងការចូលរួមចំណែករបស់ជាតិនេះ ប្រសិទ្ធភាពថាមពលត្រូវបានចាត់ទុកថាជាសកម្មភាពកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ដ៏សំខាន់តាមវិស័យ និងតាមអន្តរវិស័យ។ ការចូលរួមចំណែករបស់ជាតិនេះក៏បានទទួលស្គាល់ផងដែរថា វិធានការគោលនយោបាយនេះ ក៏ដូចជាសកម្មភាពកាត់បន្ថយផ្សេងទៀត អាចរួមចំណែកយ៉ាងច្រើនដល់ការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា។ ដូច្នេះគោលនយោបាយជាតិស្តីពី ប្រសិទ្ធភាពថាមពល ២០២២-២០៣០ ដាក់ចេញនូវលក្ខខណ្ឌក្នុងការពន្លឿនការអនុវត្តគម្រោងប្រសិទ្ធភាពថាមពលនៅក្នុងការចូលរួមចំណែករបស់ជាតិខាងលើ។

- **ផែនការយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុកម្ពុជា (២០១៤-២០២៣)** បានដាក់ចេញគោលដៅជាយុទ្ធសាស្ត្រក្នុងការលើកកម្ពស់ការរៀបចំផែនការ និងការប្រើប្រាស់បច្ចេកវិទ្យាកាបូនទាបដើម្បីគាំទ្រការអភិវឌ្ឍប្រកបដោយចីរភាព។ ផែនការនេះ ជំរុញឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ចូលរួមទទួលខុសត្រូវ ក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដោយរៀបចំផែនការសកម្មភាពការងារនេះរៀងៗខ្លួន។ ផែនការនេះកំណត់យកប្រសិទ្ធភាពថាមពល ជាមធ្យោបាយសំខាន់មួយក្នុងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងបង្ហាញអំពីភាពវិជ្ជមានក្នុងការជួយគាំទ្រដល់សុខភាព សុខុមាលភាព និងសន្តិសុខថាមពល។ ផែនការនេះ ផ្តល់អនុសាសន៍ឱ្យលើកកម្ពស់ "ការធ្វើផែនការ និងការប្រើប្រាស់បច្ចេកវិទ្យាបញ្ចេញកាបូនទាប" និង ពន្លឿនការងារប្រសិទ្ធភាពថាមពលទាំងក្នុងផ្នែកផ្គត់ផ្គង់ និងក្នុងផ្នែកប្រើប្រាស់ ដែលគាំទ្រដោយគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០ នេះ។
- **ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០** ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីក្នុងឆ្នាំ២០១៣ ដើម្បីបញ្ជ្រាបការអភិវឌ្ឍប្រកបដោយចីរភាពទៅក្នុងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រដទៃទៀតរបស់កម្ពុជា តាមរយៈការបង្កើតក្រុមប្រឹក្សាជាតិស្តីពីការអភិវឌ្ឍបៃតងដើម្បីគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព កែលម្អគុណភាពបរិស្ថាន និងកាត់បន្ថយភាពក្រីក្រ។ ផែនការយុទ្ធសាស្ត្រនេះ ផ្តល់នូវការតម្រង់ទិសដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន និងសង្គមស៊ីវិលឆ្ពោះទៅរកកំណើនបៃតងប្រកបដោយភាពស័ក្តិសិទ្ធិ។ ផែនការយុទ្ធសាស្ត្រនេះ ក៏ផ្តល់នូវយុទ្ធសាស្ត្រពង្រឹងកំណើនបៃតងនៅក្នុងប្រទេស គ្របដណ្តប់លើវិស័យជាច្រើន ដែលរួមមាន ការវិនិយោគលើថាមពលស្អាត និង ប្រសិទ្ធភាពថាមពល ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិផងដែរ។ គោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០ នេះនឹងរួមចំណែក **និងបំពេញបន្ថែម**ការអនុវត្តរបៀបវារៈដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងនេះ។
- **គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ២០១៥-២០២៥** ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីក្នុងឆ្នាំ២០១៥ មានគោលបំណងជំរុញឱ្យមានការផ្លាស់ប្តូរលើវិស័យឧស្សាហកម្មរបស់កម្ពុជាពីឧស្សាហកម្មដែលពឹងផ្អែកលើកម្លាំងពលកម្ម ទៅជាឧស្សាហកម្មពឹងផ្អែកលើជំនាញដោយផ្តោតលើនវានុវត្តន៍ បច្ចេកវិទ្យា និងផលិតភាពខ្ពស់។ គោលនយោបាយនេះ សង្កត់ធ្ងន់លើតម្រូវការនៃការពង្រឹងភាពប្រកួតប្រជែងផ្នែកឧស្សាហកម្មជាតិនីមួយៗ ក្នុងកម្រិតពិភពលោក។ ថ្វីត្បិតតែគោលនយោបាយនេះ មិនបានបញ្ជាក់ថាប្រសិទ្ធភាពថាមពល គឺជាវិធីសាស្ត្រលើកកម្ពស់ភាពប្រកួតប្រជែងផ្នែកឧស្សាហកម្មក្តី តែប្រសិទ្ធភាពថាមពលអាចជួយគាំទ្រដល់យុទ្ធសាស្ត្ររបស់គោលនយោបាយនេះ ជាពិសេសការបន្ថយថ្លៃចំណាយលើ

ថាមពលអគ្គិសនី និងការពង្រីកការផ្គត់ផ្គង់អគ្គិសនីដែលអាចទុកចិត្តបានដល់ផ្នែកឧស្សាហកម្មទាំងនេះ។ ហេតុដូច្នេះ គោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០ ត្រូវបានចាត់ទុកថាស្រប តាមទិសដៅ និងជួយបំពេញបន្ថែមឱ្យគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ២០១៥-២០២៥។

- **ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣** ជាផែនការរបស់រាជរដ្ឋាភិបាលកម្ពុជាដែលផ្តោតលើ អភិក្រម 3Rs សម្រាប់ការស្តារសេដ្ឋកិច្ចឡើងវិញបន្ទាប់ពីវិបត្តិនៃជំងឺកូវីដ-១៩៖ (១). ការស្តារ (Recovery) (២). ការកែទម្រង់ (Reform) និង (៣). ភាពធន់ (Resilience)។ ក្នុងនោះអភិក្រមភាពធន់ផ្តោត សំខាន់លើការអភិវឌ្ឍប្រកបដោយបរិយាបន្ន និងចីរភាព ដោយបានដាក់ចេញនូវវិធានការនានា ដែលគាំទ្រ ការស្តារសេដ្ឋកិច្ចឡើងវិញលក្ខណៈបៃតង ជាពិសេសការលើកកម្ពស់ប្រសិទ្ធភាពថាមពល និងការ ប្រើប្រាស់ប្រភពថាមពលកកើតឡើងវិញ។

## ១.៣. រចនាសម្ព័ន្ធនៃគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០

**គោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០** ត្រូវបានរៀបចំជា ៩ ផ្នែក។ បន្ទាប់ពី សេចក្តីផ្តើមនេះ ផ្នែកទី២បង្ហាញអំពីស្ថានភាពនៃការប្រើប្រាស់អគ្គិសនី និងប្រសិទ្ធភាពថាមពលនៅកម្ពុជា ដោយបង្ហាញអំពីតម្រូវការនៃប្រសិទ្ធភាពថាមពល ក៏ដូចជាឧបសគ្គនានាដែលរារាំងដល់ការទទួលយកវិធានការ ប្រសិទ្ធភាពថាមពល។ ផ្នែកទី៣ ដាក់ចេញនូវទស្សនវិស័យរយៈពេលវែងនៃគោលនយោបាយនេះ ចំណែកផ្នែកទី៤ កំណត់ចក្ខុវិស័យ គោលបំណងនៃគោលនយោបាយ និងគោលដៅនៃការងារប្រសិទ្ធភាពថាមពលដែលត្រូវ សម្រេចឱ្យបាននៅឆ្នាំ២០៣០។ ផ្នែកទី៥ដាក់ចេញនូវក្របខណ្ឌយុទ្ធសាស្ត្រដែលជាមូលដ្ឋានសម្រាប់សម្រេច ចក្ខុវិស័យ និងគោលបំណងនៃគោលនយោបាយនេះ។ ផ្នែកទី៦ចែងអំពីវិធានការប្រសិទ្ធភាពថាមពលក្នុង វិស័យផ្សេងៗរួមមានវិស័យ អគារ ឧស្សាហកម្ម ដឹកជញ្ជូន និងសេវាសាធារណៈ។ ផ្នែកទី៧កំណត់អំពីរចនាសម្ព័ន្ធ អភិបាលកិច្ចនៃគោលនយោបាយនេះ ដោយបញ្ជាក់ពីតួនាទី និងការទទួលខុសត្រូវសម្រាប់អ្នកពាក់ព័ន្ធផ្សេងៗ ព្រមទាំងសំណុំឧបករណ៍ដើម្បីគាំទ្រដល់ការអនុវត្តគោលនយោបាយនេះ។ ផ្នែកទី៨ចែងអំពីផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីតាមដានវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយនេះ។ ផ្នែកទី៩ចែងអំពីសេចក្តី សន្និដ្ឋានបញ្ចប់ ដោយបង្ហាញសង្ខេបអំពីលទ្ធផលដែលបានគ្រោងទុកចេញពីការអនុវត្តគោលនយោបាយនេះ។

## ២- ស្ថានភាពនៃការប្រើប្រាស់ថាមពល និងប្រសិទ្ធភាពថាមពល នៅកម្ពុជា

ប្រទេសកម្ពុជាបានប្រែក្លាយខ្លួនជាប្រទេសមួយមានកំណើនសេដ្ឋកិច្ចខ្ពស់ ជាមួយអត្រាមធ្យមប្រចាំឆ្នាំក្នុងរង្វង់ ៧% ក្នុងអំឡុងពេលឆ្នាំ២០០៣-២០១៩ មុននឹងទទួលរងនូវផលប៉ះពាល់ជាអវិជ្ជមានពីជំងឺកូវីដ-១៩ នៅឆ្នាំ២០២០។ កំណើនសេដ្ឋកិច្ចដ៏ខ្ពស់នេះ មានផលជះ ចំនួន ៣ ដល់វិស័យថាមពល៖ ១) កំណើនជាបន្តបន្ទាប់នៃសេចក្តីត្រូវការថាមពលខ្ពស់ ជាពិសេសផ្នែកថាមពលអគ្គិសនី ២) ការកើនឡើងនៃការពឹងផ្អែកលើថាមពលនាំចូលកាន់តែខ្លាំង ជាពិសេស ប្រេងឥន្ធនៈ និងធ្យូងថ្ម ៣) សមាមាត្រឥន្ធនៈហ្វូស៊ីលក្នុងល្បាយថាមពលកាន់តែខ្ពស់។

បើគិតត្រឹមពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៩ បរិមាណថាមពលប្រើប្រាស់សរុបរបស់ប្រទេសកម្ពុជា បានកើនឡើងចំនួន ៦៣%។ ទន្ទឹមនឹងនេះ ការប្រើប្រាស់ផ្នែកថាមពលអគ្គិសនីក៏បានកើនឡើងគួរឱ្យកត់សម្គាល់គឺប្រមាណ ៣៥៣%។ ការប្រើប្រាស់ជីវម៉ាសជាថាមពលមានចំណែកធំជាងគេប្រហែល ៤៧% នៃការប្រើប្រាស់ថាមពលសរុបនៅកម្ពុជាក្នុងឆ្នាំ២០១៩ បន្ទាប់ពីនេះ គឺការប្រើប្រាស់ឥន្ធនៈហ្វូស៊ីល ដែលមានប្រមាណ ៤១% និងអគ្គិសនីមានប្រមាណ១៣%។ ថាមពលជីវម៉ាសត្រូវបានប្រើប្រាស់ច្រើនក្នុងវិស័យអគារលំនៅឋានសម្រាប់ចម្អិនអាហារ និង ការប្រើប្រាស់ជាប្រភពឥន្ធនៈសម្រាប់វិស័យឧស្សាហកម្មផងដែរ។

នៅឆ្នាំ២០១៩ វិស័យសេដ្ឋកិច្ចសំខាន់ៗដែលប្រើប្រាស់ថាមពលច្រើនមានដូចខាងក្រោម៖

១) ការប្រើប្រាស់ថាមពលក្នុងវិស័យអគារលំនៅឋានមានចំនួន ២៧.៣៣៣ លានគីឡូវ៉ាត់ម៉ោង ស្មើនឹង ៣៥% នៃបរិមាណថាមពលប្រើប្រាស់សរុប។

២) ការប្រើប្រាស់ថាមពលក្នុងវិស័យដឹកជញ្ជូនមានចំនួន ២២.១០៨ លានគីឡូវ៉ាត់ម៉ោង ស្មើនឹង ២៨% នៃបរិមាណថាមពលប្រើប្រាស់សរុប។

៣) ការប្រើប្រាស់ថាមពលក្នុងវិស័យឧស្សាហកម្មមានចំនួន ២០.៤១១ លានគីឡូវ៉ាត់ម៉ោង ស្មើនឹង ២៦% នៃបរិមាណថាមពលប្រើប្រាស់សរុប។

៤) ការប្រើប្រាស់ថាមពលក្នុងវិស័យពាណិជ្ជកម្ម និងសេវាសាធារណៈ មានចំនួន ៦.១៧១ លានគីឡូវ៉ាត់ម៉ោង ស្មើនឹង ៨% នៃបរិមាណថាមពលប្រើប្រាស់សរុប។

តម្រូវការប្រើប្រាស់ថាមពលអគ្គិសនីរបស់ប្រទេសកម្ពុជា កើនឡើងយ៉ាងខ្លាំងនៅទសវត្សរ៍ចុងក្រោយនេះ ដែលការប្រើប្រាស់អគ្គិសនីសរុបចុងក្រោយបានកើនឡើងជាង ៤ដង គឺពី ២.៥១៥ លានគីឡូវ៉ាត់ម៉ោង

នៅឆ្នាំ២០១០ ដល់ ១១.៨១៦ លានគីឡូវ៉ាត់ម៉ោងនៅឆ្នាំ២០២១ និងមានអត្រាកំណើន ជាមធ្យមប្រចាំឆ្នាំប្រមាណ ១៨%។ ការប្រើប្រាស់អគ្គិសនីប្រចាំឆ្នាំសម្រាប់មនុស្សម្នាក់ៗក៏មានការកើនឡើងប្រមាណជាង ៤ដងផងដែរ ពោលគឺបានកើនពី ១៦១ គីឡូវ៉ាត់ម៉ោងក្នុងមួយឆ្នាំសម្រាប់មនុស្សម្នាក់ៗនៅឆ្នាំ២០១០ ដល់ ៧០៦ គីឡូវ៉ាត់ម៉ោងក្នុង មួយឆ្នាំសម្រាប់មនុស្សម្នាក់ៗនៅឆ្នាំ២០២១។

ទោះបីជាត្រូវទប់ទល់ជាមួយកំណើនសេចក្តីត្រូវការថាមពល ការនៅពឹងផ្អែកលើការនាំចូលថាមពល និងតម្លៃថាមពលមិនទាន់អាចប្រកួតប្រជែងជាមួយប្រទេសជិតខាងក៏ដោយ ក៏សក្តានុពលប្រសិទ្ធភាពថាមពលនៅកម្ពុជា នៅមិនទាន់ត្រូវបានគេប្រើច្រើននៅឡើយទេ។ មូលហេតុដោយសារតែការអនុវត្តការងារប្រសិទ្ធភាពថាមពលកន្លងមក ផ្អែកតែលើជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍ កិច្ចសហការ និងកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីនៅក្នុងស្រុក និងក្នុងតំបន់តែប៉ុណ្ណោះ។ ការអនុវត្តគម្រោងប្រសិទ្ធភាពថាមពលកន្លងមក ក៏មានផងដែរក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ វាយនភណ្ឌ និងស្បែកជើងដោយសារមានការតម្រូវពីអ្នកបញ្ជាទិញនិងម្ចាស់ម៉ាកល្បីៗ ការយល់ដឹង និងការចូលរួមកាត់បន្ថយថ្លៃដើមនិងការការពារបរិស្ថានរបស់អ្នកប្រើប្រាស់មួយចំនួន។ បទពិសោធន៍ក្នុងតំបន់និងពិភពលោក បានបង្ហាញថាការបង្កើតក្របខណ្ឌគោលនយោបាយដើម្បីគាំទ្រ គឺជាជំហានដំបូងបំផុតក្នុងការផ្លាស់ប្តូរឆ្ពោះទៅរកសេដ្ឋកិច្ចប្រសិទ្ធភាពថាមពល។ បច្ចុប្បន្ន ក្របខណ្ឌគោលនយោបាយជាតិរបស់កម្ពុជា ជាទូទៅគាំទ្រដល់ការងារប្រសិទ្ធភាពថាមពល ដូច្នេះកម្ពុជាត្រូវការគោលនយោបាយជាក់លាក់មួយ ដើម្បីជំនះឧបសគ្គនានាក្នុងការអភិវឌ្ឍគម្រោងប្រសិទ្ធភាពថាមពល និងជំរុញការប្រើប្រាស់សក្តានុពលប្រសិទ្ធភាពថាមពលឱ្យបានទូលំទូលាយ។

បញ្ហាប្រឈមក្នុងការអនុវត្តការងារប្រសិទ្ធភាពថាមពលនៅកម្ពុជា ត្រូវបានពិនិត្យឃើញនៅតាមកម្រិតដូចខាងក្រោម៖

### ១. គោលនយោបាយ និងស្ថាប័ន៖

- មិនទាន់បានកំណត់ក្របខណ្ឌអភិបាលកិច្ចចំពោះការងារប្រសិទ្ធភាពថាមពលនៅឡើយ រួមមានភារកិច្ចតួនាទី និងយន្តការសម្រាប់សហប្រតិបត្តិការក្នុងចំណោមក្រសួង ស្ថាប័នរាជរដ្ឋាភិបាល កង្វះគោលនយោបាយជាក់លាក់ និងបទប្បញ្ញត្តិដើម្បីជំរុញការវិនិយោគលើប្រសិទ្ធភាពថាមពល (ឧទាហរណ៍ដូចជា ការដាក់ចេញវិធានថាមពល ការបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពល និងការកំណត់បទដ្ឋាននានា ជាដើម)។

- កង្វះយន្តការ និងបទប្បញ្ញត្តិទីផ្សារ ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេវាកម្មប្រសិទ្ធភាពថាមពល និងសវនកម្មថាមពល ជាពិសេសវិធានថាមពលសម្រាប់អគារ ការផ្តល់សិទ្ធិដល់ "ក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល" (ក្រ.ផ.ស.ដ.ថ = ESCOs) និងការទទួលស្គាល់សវនករថាមពល។
- កង្វះក្របខណ្ឌ និងយន្តការជាធរមានសម្រាប់ការវាស់វែង ការរាយការណ៍ និងការផ្ទៀងផ្ទាត់ការប្រើប្រាស់ថាមពលនៅក្នុងផ្នែកអ្នកប្រើប្រាស់ថាមពលធំៗ រួមមានឧស្សាហកម្ម និងអគារ។
- ភាពលំបាករកទិន្នន័យតាមវិស័យ និងកង្វះយន្តការចែករំលែកទិន្នន័យស្តីអំពីការប្រើប្រាស់ថាមពលតាមបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ។
- កង្វះក្របខណ្ឌក្នុងការទទួលស្គាល់សវនករ និងអ្នកគ្រប់គ្រងថាមពល។
- សមត្ថភាពរបស់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាលនៅមានកម្រិតទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការកំណត់អត្តសញ្ញាណ និងការអនុវត្តគម្រោងប្រសិទ្ធភាពថាមពល។
- កង្វះការលើកទឹកចិត្តផ្នែកសារពើពន្ធ និងហិរញ្ញវត្ថុដើម្បីគាំទ្រនិងផ្តល់រង្វាន់ដល់គម្រោងប្រសិទ្ធភាពថាមពល។

២. បច្ចេកទេស

- កង្វះបទប្បញ្ញត្តិបច្ចេកទេស និងគោលការណ៍ណែនាំ តាមកម្រិតវិស័យ និងអន្តរវិស័យ ដើម្បីលើកទឹកចិត្តដល់ការវិនិយោគលើផលិតផល និងសេវាកម្មដែលមានប្រសិទ្ធភាពថាមពល។
- កង្វះក្របខណ្ឌសម្រាប់ការវាស់វែង ការរាយការណ៍ និងការផ្ទៀងផ្ទាត់គម្រោងប្រសិទ្ធភាពថាមពល។
- សមត្ថភាពរបស់អ្នកប្រើប្រាស់ថាមពល និងអ្នកអនុវត្តគោលនយោបាយក្នុងវិស័យថាមពលក្នុងការកំណត់អភិវឌ្ឍ និងអនុវត្តគម្រោងប្រសិទ្ធភាពថាមពល នៅមានកម្រិត។

៣. ហិរញ្ញវត្ថុ

- វិនិយោគបឋមខ្ពស់ រយៈពេលស្រង់ដើមវែង និងមានហានិភ័យពាក់ព័ន្ធជាមួយប្រាក់ចំណេញ។
- កង្វះឧបករណ៍ផ្លូវច្បាប់សម្រាប់កាត់បន្ថយហានិភ័យចំពោះគម្រោងប្រសិទ្ធភាពថាមពល។
- កង្វះលទ្ធភាពទទួលបានហិរញ្ញវត្ថុដែលមានតម្លៃសមរម្យសម្រាប់ធ្វើការវិនិយោគគម្រោងប្រសិទ្ធភាពថាមពល។
- កង្វះយន្តការហិរញ្ញវត្ថុសាធារណៈ និងឯកជនសម្រាប់គាំទ្រដល់ការវិនិយោគគម្រោងប្រសិទ្ធភាពថាមពល ព្រោះគម្រោងប្រសិទ្ធថាមពលត្រូវការទំហំទុនធំសម្រាប់វិនិយោគដំបូង ហើយការសន្សំសំចៃសម្រាប់ឆ្នាំបន្តបន្ទាប់មានចំនួនតិចដែលធ្វើឱ្យរយៈពេលស្រង់ដើមវែង។

- ស្ថាប័នហិរញ្ញវត្ថុ ខ្វះជំនាញវាយតម្លៃគម្រោងប្រសិទ្ធភាពថាមពល។

**៤. ព័ត៌មាន និងការយល់ដឹង៖**

- កង្វះការយល់ដឹងក្នុងចំណោមអ្នកប្រើប្រាស់ថាមពលអំពីអត្ថប្រយោជន៍នៃប្រសិទ្ធភាពថាមពល ដែលជះឥទ្ធិពលដល់ការសម្រេចចិត្តទិញរបស់អ្នកប្រើប្រាស់ទៅជ្រើសរើសជម្រើសដែលមានប្រសិទ្ធភាពថាមពលតិច។
- គំរូអាជីវកម្មថ្មីជួយជំរុញគម្រោងប្រសិទ្ធភាពថាមពលសម្រាប់អ្នកប្រើប្រាស់ថាមពលដែលមានឈ្មោះថា "ថាមពលប្តូរទៅជាការបម្រើសេវា" នៅថ្មី ហើយមិនទាន់មានគេស្គាល់នៅក្នុងបរិបទទីផ្សារកម្ពុជានៅឡើយ។
- កង្វះកម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងអប់រំសម្រាប់ការកសាងសមត្ថភាពពាក់ព័ន្ធនឹងការងារប្រសិទ្ធភាពថាមពល។

គោលនយោបាយនេះ ដាក់ចេញនូវក្របខណ្ឌមួយ ដែលនឹងគាំទ្រការជំនះឱ្យបាននូវឧបសគ្គខាងលើនេះ ដោយបង្កើតបរិយាកាសអំណោយផលសម្រាប់ការងារប្រសិទ្ធភាពថាមពល។ ឧបសគ្គភាគច្រើន អាចដោះស្រាយបានដោយរៀបចំឱ្យបានល្អនូវយន្តការផ្តល់ហិរញ្ញប្បទាន ការលើកទឹកចិត្ត និងការបង្កើតគំរូអាជីវកម្មរួមជាមួយការបំពេញបន្ថែមផ្នែកច្បាប់ បទប្បញ្ញត្តិ និងសកម្មភាពលើកកម្ពស់ការយល់ដឹង។ គំនិតផ្តួចផ្តើមទាំងនេះត្រូវបានគេរំពឹងថានឹងក្រាលជាមូលដ្ឋានគ្រឹះសម្រាប់ពង្រឹងការអនុវត្តវិធានការប្រសិទ្ធភាពថាមពល។

## ៣- ចក្ខុវិស័យ

គោលនយោបាយនេះមានចក្ខុវិស័យកែប្រែការប្រើប្រាស់ថាមពលនៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ដើម្បីលើកកម្ពស់សេដ្ឋកិច្ចជាតិឱ្យរឹងមាំ រស់រវើក ប្រកួតប្រជែង និងការអភិវឌ្ឍប្រកបដោយចីរភាព។

## ៤- គោលបំណង និងគោលដៅ

គោលនយោបាយនេះមានគោលបំណងជំរុញ និងពន្លឿនការប្រើប្រាស់សក្តានុពលប្រសិទ្ធភាពថាមពលនៅកម្ពុជា ក្នុងការប្រើប្រាស់ថាមពលតិចជាងមុន ប៉ុន្តែរក្សាបានទិន្នផលប្រសើរជាងមុន ជួយសន្សំសំចៃធនធានហិរញ្ញវត្ថុ ជួយបង្កើនភាពប្រកួតប្រជែងវិស័យឯកជន និងទប់ស្កាត់ការប្រែប្រួលអាកាសធាតុនិងបញ្ហាបរិស្ថាន។

ដើម្បីសម្រេចបានចក្ខុវិស័យនិងគោលបំណងខាងលើ គោលនយោបាយនេះកំណត់គោលដៅដូចខាងក្រោម៖

-បង្កើតលិខិតបទដ្ឋានគតិយុត្តិចាំបាច់នានា សម្រាប់កំណត់សកម្មភាពអនុវត្តវិធានការគោលនយោបាយតាមវិស័យ និងតាមកម្មវិធីប្រសិទ្ធភាពថាមពល។

- កំណត់តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ស្ថាប័នពាក់ព័ន្ធ ដើម្បីបើកឱ្យមានការអនុវត្តបញ្ញត្តិនៃគោលនយោបាយនេះ រួមទាំងយន្តការសម្របសម្រួលរវាងស្ថាប័នពាក់ព័ន្ធទាំងនេះ។
- កំណត់ផែនការសកម្មភាពដែលអាចវាស់វែងនិងវាយតម្លៃបាន សម្រាប់ការអនុវត្តការងារប្រសិទ្ធភាពថាមពលនៅកម្ពុជាសម្រាប់ឆ្នាំ២០២២-២០៣០។
- រៀបចំវិធានការ ឧបករណ៍ផ្លូវច្បាប់ និងយន្តការនានា ដើម្បីគាំទ្រដល់ការដកចេញនូវឧបសគ្គនានាក្នុងការអនុវត្តការងារប្រសិទ្ធភាពថាមពលនៅកម្ពុជា។
- បង្កើតក្របខណ្ឌរួមមួយសម្រាប់ធ្វើការត្រួតពិនិត្យ និងវាយតម្លៃ ការវាស់វែងលើការងារប្រសិទ្ធភាពថាមពលដើម្បីតាមដានវឌ្ឍនភាពនៃការអនុវត្ត។
- ផ្សព្វផ្សាយការយល់ដឹងអំពីប្រសិទ្ធភាពថាមពល និងអភិវឌ្ឍសមត្ថភាពធនធានមនុស្សចាំបាច់ដើម្បីឱ្យបុគ្គលនិងស្ថាប័ន អាចកំណត់អត្តសញ្ញាណ អភិវឌ្ឍ និងអនុវត្តគម្រោងប្រសិទ្ធភាពថាមពលបាន។

គោលនយោបាយនេះ កំណត់ការកាត់បន្ថយតម្រូវការថាមពលសរុបឱ្យបាន ១៩% ត្រឹមឆ្នាំ២០៣០ សម្រាប់ការប្រើប្រាស់ថាមពលសរុបធៀបនឹងតម្រូវការថាមពលសរុបក្នុងសេណារីយ៉ូធុរកិច្ចធម្មតា។ កំណើន

ការប្រើប្រាស់ថាមពលនឹងថយចុះពី ៨៩.៨៣៧ GWh ក្នុងសេណារីយ៉ូគ្មានវិធានការគោលនយោបាយប្រសិទ្ធភាពថាមពល មកនៅត្រឹម ៧២.៤៧០ GWh ក្នុងករណីមានការអនុវត្តវិធានការគោលនយោបាយប្រសិទ្ធភាពថាមពល។ សម្រាប់វិស័យប្រើប្រាស់ថាមពលសំខាន់ៗ គោលនយោបាយនេះ ដាក់ចេញគោលដៅជាក់លាក់ដើម្បីកាត់បន្ថយការប្រើប្រាស់ថាមពលធៀបនឹងសេណារីយ៉ូធុរកិច្ចធម្មតានៅត្រឹមឆ្នាំ២០៣០ យ៉ាងហោចណាស់កាត់បន្ថយឱ្យបានដូចខាងក្រោម៖

- ២០% នៅក្នុងវិស័យឧស្សាហកម្ម គឺពី ៣៨.៦០០ GWh មកត្រឹមតែ ៣០.៨៨០ GWh
- ៣៤% នៅក្នុងវិស័យអគារលំនៅឋាន គឺពី ១៧.៩៨១ GWh មកត្រឹមតែ ១១.៨២៦ GWh
- ២៥% នៅក្នុងវិស័យអគារពាណិជ្ជកម្ម និងអគារផ្សេងទៀត គឺពី ៨.៥៥២ GWh មកត្រឹមតែ ៦.៤៣១ GWh
- ២៩% នៅក្នុងវិស័យសេវាសាធារណៈ គឺពី ៤២ GWh មកត្រឹមតែ ៣០ GWh
- ៥% នៅក្នុងវិស័យដឹកជញ្ជូន គឺពី ២៤.៦៦២GWh មកត្រឹមតែ ២៣.៣៨៣ GWh ។

គោលនយោបាយនេះ អនុវត្តលើប្រសិទ្ធភាពថាមពលក្នុងផ្នែកប្រើប្រាស់ថាមពលតែប៉ុណ្ណោះ ដោយមិនគ្របដណ្តប់លើប្រសិទ្ធភាពថាមពលនៅក្នុងផ្នែកផ្គត់ផ្គង់ រួមមានការផលិត ការបញ្ជូន និងការចែកចាយថាមពលឡើយ ដោយសារមានកំណត់រួចហើយនៅក្នុងផែនការមេអភិវឌ្ឍវិស័យថាមពល។ ជាមួយនឹងការជំរុញ និងពន្លឿនការបង្កើនប្រសិទ្ធភាពថាមពលក្នុងការប្រើប្រាស់ថាមពលអគ្គិសនី និងថាមពលកម្តៅតាមរយៈវិធានការគោលនយោបាយ និងផែនការសកម្មភាពដែលកំណត់នៅក្នុងគោលនយោបាយនេះ ក្រសួងនិងស្ថាប័នពាក់ព័ន្ធក៏ត្រូវគិតគូរបង្កើនប្រសិទ្ធភាពថាមពលនៅក្នុងការប្រើប្រាស់ថាមពលប្រភេទផ្សេងទៀតតាមរយៈការអនុវត្តគម្រោងប្រសិទ្ធភាពថាមពលដោយឡែកនានា ទៅតាមលទ្ធភាពដែលអាចធ្វើទៅបានទៅតាមវិស័យរបស់ខ្លួនផងដែរ។

## ៥- ក្របខណ្ឌយុទ្ធសាស្ត្រ

ដើម្បីសម្រេចនូវចក្ខុវិស័យ គោលបំណង និងគោលដៅនៃគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០ រាជរដ្ឋាភិបាលកម្ពុជារៀបចំក្របខណ្ឌយុទ្ធសាស្ត្រប្រសិទ្ធភាពថាមពលដែលមានសសរស្តម្ភយុទ្ធសាស្ត្រចំនួនប្រាំ។ សសរស្តម្ភនីមួយៗ មានលក្ខណៈសម្របសម្រួល ប្រទាក់ក្រឡាគ្នា និងបំពេញឱ្យគ្នាទៅវិញទៅមក ដើម្បីធានាឱ្យការអនុវត្តគោលនយោបាយនេះ សម្រេចបានជោគជ័យប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព។ សសរស្តម្ភយុទ្ធសាស្ត្រទាំងប្រាំនៃក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់ប្រសិទ្ធភាពថាមពលនេះ គឺ

ទី១) ការបង្កើតក្របខណ្ឌច្បាប់និងបទប្បញ្ញត្តិសម្រាប់ប្រសិទ្ធភាពថាមពល ទី២) អភិបាលកិច្ចនិងយន្តការសម្របសម្រួល ទី៣) ការកសាងធនធានមនុស្ស ទី៤) ការលើកកម្ពស់ការយល់ដឹង និងការបញ្ជ្រាបព័ត៌មាន និង ទី៥) ការប្រមូលមូលនិធិសម្រាប់ការងារប្រសិទ្ធភាពថាមពល។




*រូបភាពទី១៖ ក្របខណ្ឌយុទ្ធសាស្ត្រគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល*

ការរៀបចំ និងអនុវត្តនូវសសរស្តម្ភយុទ្ធសាស្ត្រទាំងប្រាំនៃក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់ប្រសិទ្ធភាពថាមពលខាងលើនេះ នឹងបង្កើតឱ្យមានបរិយាកាសអំណោយផលសម្រាប់ការងារប្រសិទ្ធភាពថាមពល ដែលអាចនឹងនាំមកនូវការវិនិយោគលើបច្ចេកវិទ្យា និងវិធីសាស្ត្រនៃប្រសិទ្ធភាពថាមពលកាន់តែច្រើននៅក្នុងវិស័យនៃការប្រើប្រាស់ថាមពល ដូចជា អគារ ឧស្សាហកម្ម ការដឹកជញ្ជូន និងសេវាសាធារណៈ។ ក្របខណ្ឌយុទ្ធសាស្ត្រនេះ តម្រូវឱ្យរៀបចំការអនុវត្តគម្រោងសាកល្បង និងការអនុវត្តបង្ហាញអំពីប្រសិទ្ធភាពថាមពល ដើម្បីបង្កើតនូវទំនុកចិត្តរបស់វិនិយោគិន ការកសាងសមត្ថភាពរបស់ជាតិ និងបើកផ្លូវឆ្ពោះទៅរកការអនុវត្តគម្រោងធំៗ។

ទិដ្ឋភាពទូទៅនៃសសរស្តម្ភយុទ្ធសាស្ត្រខាងលើនេះ មានចែងលម្អិតនៅខាងក្រោម ចំណែកឯយុទ្ធសាស្ត្រតាមវិស័យនៃការប្រើប្រាស់ថាមពលនីមួយៗ មានបង្ហាញនៅក្នុងផ្នែកទី៦។

## ៥.១. ការបង្កើតក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិសម្រាប់ការងារប្រសិទ្ធភាពថាមពល

គោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល កំណត់នូវយុទ្ធសាស្ត្រនិងវិធានការគោលនយោបាយមួយចំនួននៅកម្រិតវិស័យ ដើម្បីបង្កើត និងគាំទ្រការអនុវត្តការងារប្រសិទ្ធភាពថាមពលតាមវិស័យនៃការប្រើប្រាស់ថាមពលអគ្គិសនីនីមួយៗ(ផ្នែកទី៦)។ យុទ្ធសាស្ត្រនិងវិធានការទាំងនេះ នឹងត្រូវគាំទ្របន្ថែមដោយឧបករណ៍ផ្សេងទៀតដូចជា ឧបករណ៍ផ្លូវច្បាប់ ឧបករណ៍រដ្ឋបាល និងឧបករណ៍ហិរញ្ញវត្ថុ ដូចបានកំណត់នៅក្នុងផ្នែកទី៥ នៃផ្នែកទី៧។ គោលនយោបាយនេះក៏ជាមូលដ្ឋានសម្រាប់ការរៀបចំ និងដាក់ចេញលិខិតបទដ្ឋានគតិយុត្តបន្តទៀត ដែលចាំបាច់សម្រាប់គាំទ្រការអនុវត្តការងារប្រសិទ្ធភាពថាមពលទៅតាមតម្រូវការនិងស្ថានភាពជាក់ស្តែងក្នុងវិស័យផ្សេងៗផងដែរ។

## ៥.២. អភិបាលកិច្ចនិងយន្តការសម្របសម្រួល

អភិបាលកិច្ចប្រសិទ្ធភាពថាមពល គឺជាការរួមបញ្ចូលគ្នានៃក្របខណ្ឌច្បាប់ និងយន្តការផ្តល់មូលនិធិការរៀបចំស្ថាប័ន និងយន្តការសម្របសម្រួលដែលធ្វើការរួមគ្នាដើម្បីគាំទ្រការអនុវត្តយុទ្ធសាស្ត្រ គោលនយោបាយ និងកម្មវិធីប្រសិទ្ធភាពថាមពល។ នៅក្នុងបរិបទនៃគោលនយោបាយនេះ អភិបាលកិច្ច និងយន្តការសម្របសម្រួលប្រសិទ្ធភាពថាមពល ត្រូវការឧបករណ៍រដ្ឋបាល ចំនួន ២ ដូចខាងក្រោម៖

ឧបករណ៍រដ្ឋបាលទី១ គឺការបង្កើតរចនាសម្ព័ន្ធស្ថាប័នសម្រាប់គ្រប់គ្រងការងារប្រសិទ្ធភាពថាមពលទាំងមូលទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ឧបករណ៍រដ្ឋបាលទី២ គឺការកំណត់តួនាទី ភារកិច្ច ការទទួលខុសត្រូវ និងការរៀបចំនានា ដើម្បីធានាឱ្យមានកិច្ចសហការរវាងស្ថាប័នពាក់ព័ន្ធក្នុងរាជរដ្ឋាភិបាល សម្រាប់ការអនុវត្តការងារប្រសិទ្ធភាពថាមពល។

## ៥.៣. ការកសាងធនធានមនុស្ស

ប្រទេសកម្ពុជា ស្ថិតក្នុងដំណាក់កាលដំបូងនៃការផ្លាស់ប្តូរឆ្ពោះទៅរកសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាពថាមពល ដូច្នេះចាំបាច់ត្រូវបង្កើនការកសាងកម្រិតសមត្ថភាពនិងជំនាញបន្ថែម ដើម្បីធ្វើការកំណត់ អភិវឌ្ឍ

និងអនុវត្តវិធានការគោលនយោបាយប្រសិទ្ធភាពថាមពល។ ការងារទាំងនេះ អាចសម្រេចបានតាមរយៈវិធីសាស្ត្រប្រឹក្សាយោបល់ និងវិធីសាស្ត្រចម្រុះវិធី។ ដើម្បីកសាងសមត្ថភាពប្រកបដោយប្រសិទ្ធភាព នៅពេលរៀបចំយុទ្ធសាស្ត្រសម្រាប់កសាងសមត្ថភាពតាមវិស័យនីមួយៗ (សូមមើលផ្នែកទី៦) ត្រូវអនុវត្តតាមគោលការណ៍ទូទៅដូចខាងក្រោម ៖

១. កំណត់ការខ្វះចន្លោះនៃសមត្ថភាពរបស់ក្រុមគោលដៅ (ឧទាហរណ៍ ស្ថាប័នរាជរដ្ឋាភិបាល សង្គមស៊ីវិល ក្រុមហ៊ុនឯកជន និងសមាគមធុរកិច្ចជាដើម)។

២. បង្កើតកម្មវិធីសិក្សាវគ្គបណ្ដុះបណ្ដាលឱ្យស្របតាមតម្រូវការរបស់ក្រុមគោលដៅ និងឱ្យស្របនឹងឧត្តមានុវត្តន៍នានាក្នុងតំបន់។

៣. រៀបចំប្រព័ន្ធផ្ដល់វិញ្ញាបនបត្រដល់អ្នកគ្រប់គ្រងផ្នែកថាមពលនិងគ្រូបង្គោលសម្រាប់ការបណ្ដុះបណ្ដាលបន្ត។

៤. អនុវត្តកម្មវិធីកសាងសមត្ថភាពជាមួយនឹងការពិនិត្យឡើងវិញជាទៀងទាត់ដោយផ្អែកលើមតិយោបល់ និងការពិគ្រោះយោបល់។

## ៥.៤. ការលើកកម្ពស់និងការបង្ក្រាបការយល់ដឹង

ជាទូទៅ ប្រជាពលរដ្ឋភាគច្រើន មិនបានដឹងអំពីអត្ថប្រយោជន៍នៃប្រសិទ្ធភាពថាមពលទេ។ ករណីនេះគេអាចសង្កេតឃើញពីវត្តមាននៃឧបករណ៍និងបរិក្ខារគ្មានប្រសិទ្ធភាពនៅក្នុងទីផ្សារ និងកង្វះការយល់ដឹងរបស់អ្នកប្រើប្រាស់អំពីប្រសិទ្ធភាពថាមពល។

យុទ្ធសាស្ត្រដែលដាក់ចេញក្នុងគោលនយោបាយនេះ (ផ្នែកទី៦) មានគោលបំណងធ្វើឱ្យសង្គមចាប់អារម្មណ៍ និងបានជ្រួតជ្រាបអំពីភាពចាំបាច់នៃប្រសិទ្ធភាពថាមពល។ ដើម្បីសម្រេចគោលបំណងនេះ ត្រូវរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយផ្សេងៗ ដូចជាយុទ្ធនាការផ្សព្វផ្សាយជាសាធារណៈ(ឧទាហរណ៍ ការផ្សាយពាណិជ្ជកម្មជាឯកសារ និងការផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយនានា) និងការផ្សព្វផ្សាយដល់ក្រុមគោលដៅជាក់លាក់(ឧទាហរណ៍ បុគ្គលិកថែទាំនិងប្រតិបត្តិឧស្សាហកម្ម អ្នកគ្រប់គ្រងអគារ អ្នកគ្រប់គ្រងភ្លើងបំភ្លឺផ្លូវ និវាសនជន អ្នកបើកបរ។ល។)។

## ៥.៥. ការប្រមូលមូលនិធិសម្រាប់ប្រសិទ្ធភាពថាមពល

នៅទូទាំងពិភពលោក កម្មវិធីហិរញ្ញប្បទានសាធារណៈបានក្លាយជាជម្រើសឈានមុខគេក្នុងការបំពេញតម្រូវការហិរញ្ញប្បទានសម្រាប់វិស័យអ្នកប្រើប្រាស់ថាមពលចុងក្រោយ។ ស្របជៀងគ្នានេះ យុទ្ធសាស្ត្រហិរញ្ញប្បទាន

ប្រសិទ្ធភាពថាមពលនៅកម្ពុជាក្នុងដំណាក់កាលដំបូង ត្រូវពឹងផ្អែកជាចម្បងលើប្រភពហិរញ្ញវត្ថុសាធារណៈដែលជាឧបករណ៍ជួយបង្កើតទីផ្សារដំបូងសម្រាប់ផលិតផលនិងសេវាកម្មប្រសិទ្ធភាពថាមពល។ បន្ទាប់មក ត្រូវបង្កើតយន្តការទីផ្សារ និងទម្រង់ហិរញ្ញវត្ថុច្នៃប្រឌិតផ្សេងទៀត ដើម្បីពង្រីកវិសាលភាពកម្មវិធីសាធារណៈទៅក្នុងវិស័យថ្មីៗថែមទៀត និងការផ្តល់កម្ចីហិរញ្ញប្បទានពីវិស័យឯកជនសម្រាប់ការវិនិយោគលើការងារប្រសិទ្ធភាពថាមពលដែលត្រូវបានរៀបរាប់លម្អិតនៅក្នុងផ្នែកទី៥ នៃផ្នែកទី៧។

## ៦- វិធានការគោលនយោបាយ

### ៦.១. ទស្សនាទាននៃប្រសិទ្ធភាពថាមពលតាមវិស័យនៃការប្រើប្រាស់ថាមពល

ទស្សនាទាននៃប្រសិទ្ធភាពថាមពលនៃគោលនយោបាយនេះ ត្រូវបានកំណត់តាមវិស័យនៃការប្រើប្រាស់ថាមពលសំខាន់ៗចំនួន ៤ គឺឧស្សាហកម្ម អគារ សេវាសាធារណៈ និងការដឹកជញ្ជូន។ ទិដ្ឋភាពទូទៅ ការកំណត់យុទ្ធសាស្ត្រ និងវិធានការគោលនយោបាយនៃវិស័យប្រើប្រាស់ថាមពលនីមួយៗមានសង្ខេបដូចខាង ក្រោម៖

#### ៦.១.១. វិស័យឧស្សាហកម្មកម្មន្តសាល

វិស័យឧស្សាហកម្មកម្មន្តសាល គឺជាកម្លាំងចលករស្នូលមួយនៃសេដ្ឋកិច្ចកម្ពុជា ដែលមានកំណើនជាមធ្យម ៧-៨% ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ។ ជាមួយនឹងតម្លៃផលិតផលកម្មន្តសាលសរុប ១៦.២៧៥ ពាន់លានរៀល (៤,០៧ ពាន់លានដុល្លារ) វិស័យឧស្សាហកម្មកម្ពុជាបានចូលរួមចំណែក ៣២,៦% ដល់ផលិតផលក្នុងស្រុកសរុបរបស់កម្ពុជាក្នុងឆ្នាំ២០១៨។ វិស័យនេះមានឧស្សាហកម្មធុនធំចុះបញ្ជីចំនួន ១.៧៣០ និងសហគ្រាសធុនតូច និងមធ្យមចុះបញ្ជីចំនួន ៥២.១៥៤ សហគ្រាស និងមានកម្មករសរុបចំនួន ១,០៤ លាននាក់។ ឧស្សាហកម្មមួយចំនួនធំ មានលក្ខណៈជាសេដ្ឋកិច្ចក្រៅប្រព័ន្ធ ហើយ ៦២% នៃឧស្សាហកម្មទាំងនេះមានស្ត្រីជាម្ចាស់។ ភាគច្រើន (៦៧%) នៃសហគ្រាសឧស្សាហកម្មធុនធំ ស្ថិតក្នុងផលិតកម្មវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងកាបូប។ ទន្ទឹមនឹងនេះ ប្រហែល ៨០% នៃសហគ្រាសធុនតូច និង មធ្យម គឺជាផលិតកម្មម្ហូបអាហារ និងភេសជ្ជៈ។ ដោយសារការរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យនេះ ធ្វើឱ្យគេមើលឃើញអំពីកំណើននៃចំណែកការប្រើប្រាស់ថាមពលរបស់វិស័យឧស្សាហកម្ម។ យោងតាមការព្យាករនៅក្នុងផែនការមេអភិវឌ្ឍថាមពល ២០២០-២០៤០ តាមសេណារីយ៉ូកំណើនមធ្យម កំណើនប្រើប្រាស់ថាមពលអគ្គិសនីរបស់វិស័យឧស្សាហកម្មត្រូវបានគេព្យាករថា នឹងមានកំណើនប្រចាំឆ្នាំចំនួន ១៤,០១% នៃការប្រើប្រាស់ថាមពលអគ្គិសនីសរុប។

វិស័យឧស្សាហកម្មនៅកម្ពុជាត្រូវបានគ្រប់គ្រងដោយវិស័យឯកជន។ នៅក្នុងវិស័យនេះ ការប្រើប្រាស់បច្ចេកវិទ្យាប្រសិទ្ធភាពថាមពលនៅមានកម្រិតនៅឡើយ។ មួយវិញទៀតសហគ្រាសដែលមិនបានចុះបញ្ជី និងសហគ្រាសដែលគ្រប់គ្រងដោយស្ត្រី ភាគច្រើនជាអ្នកផលិតផលិតផលសម្រាប់ទីផ្សារក្នុងស្រុកហើយងាយរងគ្រោះដោយសារវដ្តនៃតម្រូវការក្នុងស្រុក។ ការដែលមិនបានចុះបញ្ជី ក៏រារាំងដល់វិស័យនេះពីការទទួលបានប្រាក់កម្ចីពីធនាគារសម្រាប់ការអនុវត្តគម្រោងប្រសិទ្ធភាពថាមពលផងដែរ។ វាយនភណ្ឌ សំលៀកបំពាក់ ស្បែកជើង កាបូប និង អង្ករ គឺជាផលិតផលនាំចេញដ៏សំខាន់នៃឧស្សាហកម្មកម្ពុជា ដែលថ្មីៗនេះមានការកើនឡើងនៃការប្រកួតប្រជែងពីប្រទេសផ្សេងៗ។ ក្នុងករណីឧស្សាហកម្មនាំចេញ អ្នកទិញអន្តរជាតិក៏តែងតែទាមទារឱ្យមានការអនុលោមតាមស្តង់ដារបរិស្ថានខ្ពស់។ សមត្ថភាពធ្វើផែនការ ការអនុវត្ត និងការយល់ដឹងពាក់ព័ន្ធនឹងការងារប្រសិទ្ធភាពថាមពលរបស់ឧស្សាហកម្មទាំងនោះនៅមានកម្រិតនៅឡើយ។ កង្វះសមត្ថភាពនេះរឹតតែចោទជាបញ្ហាថែមទៀតដោយសារមិនមាន *"ក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល"*។

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ សសរស្តម្ភយុទ្ធសាស្ត្រដែលបានកំណត់ក្នុងផ្នែកទី៥ ត្រូវបានប្រើជាមូលដ្ឋានដើម្បីបង្កើត និងផ្តល់អាទិភាពលើយុទ្ធសាស្ត្រ និងវិធានការគោលនយោបាយប្រសិទ្ធភាពថាមពលសម្រាប់វិស័យឧស្សាហកម្ម ដូចខាងក្រោម៖

១. ដាក់ចេញនូវ*កម្មវិធីគ្រប់គ្រងថាមពល* តាមរយៈប្រកាស ឬសេចក្តីសម្រេចរបស់ស្ថាប័នបង្គោល និងស្ថាប័នជំនាញ តាមវិស័យនីមួយៗដែលបង្កើតមូលដ្ឋាន ដើម្បីកំណត់កាលានុវត្តភាពសម្រាប់កែលម្អប្រសិទ្ធភាពថាមពលតាមរយៈការកែច្នៃ ការសម្រេចប្រើបច្ចេកវិទ្យាថ្មី និងការប្រើវិធីសាស្ត្រផ្សេងទៀត។ កម្មវិធីគ្រប់គ្រងថាមពលត្រូវមានចំណុចសំខាន់ៗ ដូចខាងក្រោម៖

ក. កម្មវិធីនេះ ត្រូវគ្របដណ្តប់លើការប្រើប្រាស់ថាមពល របស់គ្រប់អង្គភាពឧស្សាហកម្ម និងអគារដែលការប្រើប្រាស់ថាមពល គិតជាមធ្យមប្រចាំឆ្នាំក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយ លើសពីកម្រិតដែលកំណត់ជាបន្តបន្ទាប់ដោយស្ថាប័នបង្គោល និងស្ថាប័នទទួលបន្ទុកតាមវិស័យ(កំណត់ក្នុងផ្នែកទី៧ នៃគោលនយោបាយនេះ) ដោយចាត់ទុកអ្នកប្រើថាមពលនេះជា *"អ្នកប្រើប្រាស់ថាមពលមុខសញ្ញា"* (*អ.ប្រ.ថ.ម.*)។

ខ. កម្មវិធីនេះត្រូវបង្កើតនូវគោលការណ៍ណែនាំស្តីពី *"បទដ្ឋានគុណផលការប្រើប្រាស់ថាមពល"* សម្រាប់ការដំណើរការ និងសម្រាប់ឧបករណ៍ថាមពលសំខាន់ៗរបស់ អ.ប្រ.ថ.ម. ដែលត្រូវមានសុពលភាពរហូតដល់មានការធ្វើវិសោធនកម្មជាថ្មី។

គ. *អ.ប្រ.ថ.ម.* ត្រូវតែងតាំងជាអ្នកគ្រប់គ្រងផ្នែកថាមពលមួយរបស់ខ្លួនដែលត្រូវមានវិញ្ញាបនបត្រគ្រប់គ្រងថាមពល ឬសវនកម្មថាមពល ចេញដោយស្ថាប័នបង្គោល ឬស្ថាប័នមានសមត្ថកិច្ច។

ឃ. អ្នកគ្រប់គ្រងផ្នែកថាមពល គឺជាជនបង្គោលក្នុងការធ្វើការងារអនុវត្ត ត្រួតពិនិត្យ និងកែលម្អ *"ប្រព័ន្ធគ្រប់គ្រងថាមពល"* ក្នុងទីតាំងរបស់ *អ.ប្រ.ថ.ម.* ដោយអនុវត្តតាមបទដ្ឋានគ្រប់គ្រងថាមពលដែលត្រូវបានទទួលស្គាល់ជាសកល។

ង. អ.ប្រ.ថ.ម. ចាំបាច់ត្រូវចូលរួមធ្វើការជាមួយក្រុមហ៊ុនសវនកម្មថាមពលដែលត្រូវបានចាត់តាំងដោយស្ថាប័នបង្គោល ដើម្បីធ្វើសវនកម្មថាមពលប្រចាំឆ្នាំក្នុងគោលដៅផ្ទៀងផ្ទាត់ និងរាយការណ៍អំពីភាពអនុលោមតាមបទដ្ឋានគុណផលប្រើប្រាស់ថាមពលដែលកំណត់ដោយស្ថាប័នបង្គោល និងស្ថាប័នពាក់ព័ន្ធ។

ច. ស្ថាប័នបង្គោលនឹងបង្កើតកម្មវិធីអនឡាញមួយដើម្បី អ.ប្រ.ថ.ម. អាចរាយការណ៍ជាប្រចាំពីការប្រើប្រាស់ថាមពល និងអាចដាក់របាយការណ៍ផ្ទៀងផ្ទាត់ដែលរៀបចំដោយសវនករថាមពលដែលបានចាត់តាំង។ បន្ទាប់មក កម្មវិធីអនឡាញនេះ អាចនឹងត្រូវបានអភិវឌ្ឍបន្ថែមទៀត ដើម្បីជាឧបករណ៍សម្រាប់ការធ្វើរបាយការណ៍ដោយខ្លួនឯង អំពីការប្រើប្រាស់ធនធាន និងការគោរពតាមបទដ្ឋានបរិស្ថានដល់ក្រសួងពាក់ព័ន្ធ។

២. ចេញបទប្បញ្ញត្តិដើម្បីបង្កើតប្រព័ន្ធចាត់តាំង និងផ្តល់ចំណាត់ថ្នាក់ដល់ "ក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល" ដូចខាងក្រោម៖

ក. ក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល ចាំបាច់ត្រូវដាក់ពាក្យសុំទៅស្ថាប័នបង្គោលដើម្បីទទួលបានការចាត់តាំង។

ខ. ស្ថាប័នបង្គោលនឹងចាត់តាំងភ្នាក់ងារវាយតម្លៃឯករាជ្យដើម្បីវាយតម្លៃពាក្យសុំរបស់ក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល និង ចាត់តាំងពួកគេដែលមានសុពលភាពរយៈពេល ២ឆ្នាំ។

៣. បង្កើតបទប្បញ្ញត្តិដើម្បីពង្រឹងការអនុវត្តច្បាប់របស់ អ.ប្រ.ថ.ម. ដោយរៀបចំឱ្យមានបញ្ញត្តិតម្រូវឱ្យ អ.ប្រ.ថ.ម. ត្រូវមានកម្មវិធីគ្រប់គ្រងថាមពល ដែលកំណត់ក្នុងគោលនយោបាយនេះ។

៤. រៀបចំពិធីសារសម្រាប់ ការវាស់វែង ការរាយការណ៍ និងការផ្ទៀងផ្ទាត់ (*វ.រ.ផ.*) លើបច្ចេកវិទ្យាប្រសិទ្ធភាពថាមពល ជាមួយអ្នកដែលមានសក្តានុពលអាចសន្សំសំចៃថាមពល ឬឧស្ម័នផ្ទះកញ្ចក់ខ្ពស់។

៥. ផ្តល់នូវការគាំទ្រ និងការរៀបចំគម្រោងដល់ស្ថាប័នដៃគូដែលបានកំណត់ក្នុងផ្នែកទី៧ នៃគោលនយោបាយនេះ និងផ្តល់នូវមធ្យោបាយផ្សេងទៀត (ឧទាហរណ៍៖ ការវាយតម្លៃទីផ្សារ និងការសិក្សាសមិទ្ធិលទ្ធភាព សេចក្តីណែនាំសម្រាប់ការវាយតម្លៃបច្ចេកទេស និងពាណិជ្ជកម្មនៃគម្រោងប្រសិទ្ធភាពថាមពល ។ល។)។

៦. ផ្តល់ការលើកទឹកចិត្តដល់ឧស្សាហកម្ម និងអគារទាំងឡាយណាដែលប្រើប្រាស់ថាមពលតិច (ដែលមិនមែនជា អ.ប្រ.ថ.ម.) ឱ្យមកចូលរួមក្នុងកម្មវិធីគ្រប់គ្រងថាមពល តាមគោលការណ៍ស្ម័គ្រចិត្ត។

៧. ផ្តល់ការគាំទ្រហិរញ្ញប្បទានប្រសិទ្ធភាពថាមពលវិស័យឧស្សាហកម្ម តាមរយៈទម្រង់ហិរញ្ញវត្ថុច្នៃប្រតិដ្ឋ សេវាផ្គូផ្គងអ្នកវិនិយោគ សេវាផ្តល់យោបល់លើកិច្ចការជំនួញ ។ល។

៨. បង្កើតកម្មវិធីបណ្តុះបណ្តាល និងកម្មវិធីអ្នកបណ្តុះបណ្តាល សម្រាប់អ្នកគ្រប់គ្រងផ្នែកថាមពល អ.ប្រ.ថ.ម. និងមន្ត្រីនៃក្រសួង ស្ថាប័ន ពាក់ព័ន្ធ។

៩. បង្កើតកម្មវិធីលើកកម្ពស់ការយល់ដឹងអំពីប្រសិទ្ធភាពថាមពលសម្រាប់ឧស្សាហកម្ម និងសមាគមន៍របស់ពួកគេ។

## ៦.១.២. វិស័យអគារ

វិស័យអគារ ដែលបានជ្រើសរើសសម្រាប់គ្រប់គ្រងក្នុងគោលនយោបាយនេះមាន ៨ ប្រភេទ គឺ អគារលំនៅឋាន អគារការិយាល័យ អគារសណ្ឋាគារ អគារលក់រាយនិងជុំ អគារសាលារៀន អគារមន្ទីរពេទ្យ ឃ្លាំង និង អគាររដ្ឋបាលសាធារណៈ។

### ៦.១.២.១. អគារលំនៅឋាន

នៅឆ្នាំ២០២០ កម្ពុជាមានគេហដ្ឋានចំនួនជាង ៣,៦ លានខ្នង នៅទូទាំងប្រទេស ដែលចំនួនគេហដ្ឋានបានកើនឡើងក្នុងអត្រាមធ្យមប្រចាំឆ្នាំប្រមាណ ១,៦៧%។ ទន្ទឹមនឹងការកើនឡើងនេះ តួលេខបានបង្ហាញថាការរស់នៅតំបន់ទីក្រុងកំពុងកើនឡើងយ៉ាងលឿនដែលតាមការព្យាករជាផ្លូវការប្រហែលមួយភាគបីនៃប្រជាជនកម្ពុជា នឹងរស់នៅក្នុងតំបន់ទីក្រុងនៅឆ្នាំ២០៣០។

ដោយសារតែជាវិស័យប្រើប្រាស់ថាមពលច្រើនជាងគេ សក្តានុពលនៃប្រសិទ្ធភាពថាមពលរបស់វិស័យអគារលំនៅឋានមានច្រើនសន្ធឹកសន្ធាប់ ហើយភាគច្រើនពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃឧបករណ៍ ឬបរិក្ខារប្រើប្រាស់អគ្គិសនីតាមគេហដ្ឋាន និងចង្ក្រានប្រសិទ្ធភាព ក្នុងការអនុវត្តការងារសិក្សាគម្រោងប្លង់អគារ។ ដោយសារតែកំណើនអត្រានៃការរស់នៅតំបន់ទីក្រុង និងកំណើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋកើនឡើងខ្ពស់

ឧបករណ៍ឬ បរិក្ខារអគ្គិសនីជាច្រើនដូចជាទូទឹកកក ឬ ម៉ាស៊ីនត្រជាក់ នឹងត្រូវប្រើប្រាស់ច្រើនថែមទៀតនាពេលអនាគត។ ដូច្នេះ ប្រសិទ្ធភាពថាមពលនៃឧបករណ៍ និងបរិក្ខារទាំងនេះមានសារៈសំខាន់ណាស់។ ជាមួយគ្នានេះ ការអនុវត្តការងារប្រសិទ្ធភាពថាមពលនៅក្នុងការងារសិក្សាគម្រោងប្លង់អគារ និងនៅក្នុងការផ្តល់ផាសុកភាពកម្តៅ នឹងនាំឱ្យមានការកាត់បន្ថយតម្រូវការប្រើប្រាស់ថាមពលអគ្គិសនីក្នុងអគារលំនៅឋានផងដែរ។ រហូតមកដល់ពេលនេះសកម្មភាពគោលនយោបាយសមស្រប ដើម្បីបង្កើនការប្រើប្រាស់ឧបករណ៍ដែលមានប្រសិទ្ធភាពថាមពល និងការអនុវត្តការរចនាថាមពលប្រកបដោយប្រសិទ្ធភាពនៅក្នុងវិស័យអគារលំនៅឋាន នៅមិនទាន់បានអនុវត្តនៅឡើយទេ។

ការប្រើប្រាស់ជីវម៉ាស គឺខ្ពស់ជាងគេនៅក្នុងវិស័យអគារលំនៅឋានដែលស្មើនឹង ៦៧,៥% នៃការប្រើប្រាស់សរុប។ ជីវម៉ាសត្រូវបានប្រើប្រាស់ជាឥន្ធនៈសម្រាប់ចម្អិនអាហារក្នុងវិស័យអគារលំនៅឋាន។ តាមការប៉ាន់ស្មាននៅឆ្នាំ២០១៨ ក្នុងចំណោមគ្រួសារប្រើប្រាស់ជីវម៉ាសសម្រាប់ចម្អិនអាហារនោះ ៦៦,៧% ប្រើប្រាស់ចង្ក្រានជីវម៉ាសជាចង្ក្រានចម្បងរបស់ពួកគេ ដែលក្នុងនោះ ៦២% ប្រើប្រាស់អុស និង ៥% ប្រើប្រាស់ធ្យូង។ ក្នុងចំណោម ៦៦,៧% នោះមានគ្រួសារប្រមាណ ៣៥,១% ប្រើចង្ក្រានមានប្រសិទ្ធភាព ចំណែកឯ ៣១,៦% ទៀតប្រើចង្ក្រានជីវម៉ាសតាមបែបប្រពៃណី។ បទពិសោធន៍គម្រោងចែកចាយចង្ក្រានស្អាតកន្លងមកបានបណ្តាលឱ្យមានការកើនឡើងនៃការប្រើប្រាស់ចង្ក្រានចំហេះស្អាត និង ចង្ក្រានជីវម៉ាសដែលមានប្រសិទ្ធភាពថាមពល។ នៅឆ្នាំ ២០១៨ ប្រហែល ៣២,៩% នៃគ្រួសារដែលប្រើប្រាស់ប្រភេទថាមពលនេះ ប្រើចង្ក្រានឥន្ធនៈស្អាតជាចង្ក្រានចម្បងរបស់ពួកគេដែលមាន ៣០,៩% ប្រើប្រាស់ហ្គាស LPG និង ១,៨% ប្រើថាមពលអគ្គិសនី។ ទោះយ៉ាងណាក្តី សកម្មភាពគោលនយោបាយពាក់ព័ន្ធនឹងការធ្វើស្តង់ដារនៃចង្ក្រានស្អាត និងសកម្មភាពដើម្បីបង្ខាក់ការប្រើប្រាស់ចង្ក្រានជីវម៉ាសដែលមានប្រសិទ្ធភាពទាបមិនទាន់ត្រូវបានអនុម័តនៅឡើយទេ។

តាមរយៈបទពិសោធន៍កន្លងមក ការអភិវឌ្ឍគម្រោងប្រសិទ្ធភាពថាមពលនៅក្នុងវិស័យអគារលំនៅឋាននៅកម្ពុជា មិនទទួលបានជោគជ័យជាដុំកំភួនទេ ភាគច្រើនដោយសារតែការយល់ដឹងអំពីការសន្សំសំចៃថ្លៃចំណាយលើការប្រើប្រាស់ថាមពល ក្នុងចំណោមអ្នកប្រើប្រាស់ប្រភេទលំនៅឋាននៅមានកម្រិត។ លើសពីនេះ ឧបករណ៍ប្រើប្រាស់ភាគច្រើននៅប្រទេសកម្ពុជា ត្រូវបាននាំចូលដោយមិនបានឆ្លងកាត់ការត្រួតពិនិត្យគុណផលប្រើប្រាស់ថាមពលបានត្រឹមត្រូវនៅឡើយ។ ដោយហេតុនេះ ជាការចាំបាច់ណាស់ក្នុងការជំរុញប្រសិទ្ធភាពថាមពលក្នុងវិស័យនេះ ដោយដំបូងត្រូវមានយន្តការដើម្បីធានាថាឧបករណ៍ និងបរិក្ខារប្រើប្រាស់ថាមពលអគ្គិសនីទាំងនេះ អនុលោមទៅតាម *បទដ្ឋានគុណផលការប្រើប្រាស់ថាមពលអប្បបរមា* ដែលអាចធ្វើទៅបានតាមរយៈការបង្កើត *បទដ្ឋាន & ការបិទស្លាកសញ្ញា*។ អវត្តមាន *"វិធានថាមពលសម្រាប់អគារ"* ក្នុងវិស័យអគារលំនៅឋាន

ធ្វើឱ្យការងារសិក្សាគម្រោងប្លង់អគារនៅកម្ពុជាមិនបានគិតគូរអំពីវិធានការប្រសិទ្ធភាពថាមពលដែលនាំឱ្យការប្រើប្រាស់ថាមពលពុំសូវមានប្រសិទ្ធភាព។ ដើម្បីឆ្លើយតបចំពោះបញ្ហានេះ ទាមទារឱ្យមានការចាត់វិធានការគោលនយោបាយសមស្របដើម្បីធ្វើឱ្យមានស្តង់ដារសម្រាប់ចង្ក្រានចំហេះស្អាត ក៏ដូចជាវិធានការក្នុងការមិនប្រើប្រាស់ចង្ក្រានជីវម៉ាសដែលមានប្រសិទ្ធភាពតិច។

### ៦.១.២.២. អគារពាណិជ្ជកម្ម និងអគារផ្សេងទៀត

ការប្រើប្រាស់ថាមពលក្នុងអគារពាណិជ្ជកម្ម និងអគារផ្សេងទៀតកំពុងកើនឡើងយ៉ាងឆាប់រហ័សក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ ផ្ទៃក្រឡានៃអគារពាណិជ្ជកម្ម និងអគារផ្សេងទៀតដែលសាងសង់រួច ត្រូវបានគេប៉ាន់ប្រមាណថានឹងកើនឡើងពី ២០ លានម៉ែត្រការ៉េ ក្នុងឆ្នាំ២០១៩ ដល់ ១០០ លានម៉ែត្រការ៉េ នៅឆ្នាំ២០៤០។ តាមការប៉ាន់ប្រមាណផ្ទៃក្រឡាសរុបរបស់អគារពាណិជ្ជកម្ម និងអគារផ្សេងទៀតក្នុងឆ្នាំ២០២១ មានចំនួន ២១,៥៦ លានម៉ែត្រការ៉េ ហើយគេរំពឹងថានឹងកើនឡើងដល់ ៤៣,៧៩ លានម៉ែត្រការ៉េ នៅឆ្នាំ២០៣០។ តួលេខនេះ បានបង្ហាញថានឹងមានតម្រូវការថាមពលសម្រាប់អគារពាណិជ្ជកម្ម និងអគារផ្សេងទៀតកើនឡើងពី ៤.៨៩១ ជីហ្គាវ៉ាត់ម៉ោងក្នុងឆ្នាំ២០២១ ដល់ ៩.៨០២ ជីហ្គាវ៉ាត់ម៉ោងក្នុងឆ្នាំ២០៣០ ក្នុងករណីមិនមានសកម្មភាពអនុវត្តគោលនយោបាយប្រសិទ្ធភាពថាមពលសម្រាប់អគារពាណិជ្ជកម្ម និងអគារផ្សេងទៀតទេនោះ។ ដោយមិនមានបទប្បញ្ញត្តិប្រសិទ្ធភាពថាមពលសម្រាប់អគារ ប្រព័ន្ធគ្រប់គ្រងថាមពល និងវិធានថាមពលសម្រាប់អគារ ទិន្នន័យអំពីការបំពេញគុណផលការប្រើប្រាស់ថាមពលនៃអគារនៅតែមិនទាន់ដឹងច្បាស់នៅឡើយ។ ទោះជាយ៉ាងណាក្តី ការចុះប្រមូលទិន្នន័យ ផ្អែកលើការធ្វើសវនកម្មថាមពលលើអគារនៅឆ្នាំ២០២០ បានផ្តល់មូលដ្ឋានទិន្នន័យអំពីប្រពលភាពប្រើប្រាស់ថាមពល (ប.ប.ថ.) សម្រាប់អគារធម្មតាគិតជាគីឡូវ៉ាត់ម៉ោងក្នុងមួយម៉ែត្រការ៉េក្នុងមួយឆ្នាំដូចខាងក្រោម៖

| ប្រភេទអគារ | ប្រពលភាពប្រើប្រាស់ថាមពល (ប.ប.ថ.) (គីឡូវ៉ាត់ម៉ោង/ម២. ឆ្នាំ) |
|---|---|
| ការិយាល័យ | ២១៧ |
| អគារសម្រាប់ការលក់រាយ និងផ្សារ | ៣១២ |
| សណ្ឋាគារ | ១២៦ |
| មន្ទីរពេទ្យ | ១៥៣ |
| សាលារៀន | ៨៤ |
| ឃ្លាំង | ១១៤,៨ |
| ស្ថាប័នសាធារណៈ | ២១៧ |

កាលានុវត្តភាពនៃប្រសិទ្ធភាពថាមពលនៅក្នុងវិស័យនេះ ផ្តោតសំខាន់លើទីតាំងប្រើប្រាស់ថាមពលអគ្គិសនី ដែលភាគច្រើនក្នុងវិស័យពាណិជ្ជកម្ម និងអគារផ្សេងទៀតប៉ុណ្ណោះ និងអនុវត្តលើការប្រើអគ្គិសនីក្នុងការផ្តល់ផាសុកភាព ការបំភ្លឺ ប្រព័ន្ធផ្គត់ផ្គង់ទឹក ជណ្តើរយន្ត និងកន្លែងដែលមានបន្ទុកប្រើប្រាស់ថាមពលអគ្គិសនីច្រើន អាស្រ័យទៅតាមប្រភេទអគារនីមួយៗ។

ដើម្បីដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធជាមួយការប្រើប្រាស់ថាមពលនៃវិស័យអគារ ទាំងអគារលំនៅឋាន អគារពាណិជ្ជកម្ម និងអគារផ្សេងទៀត សសរស្តម្ភយុទ្ធសាស្ត្រដែលបានកំណត់ក្នុងផ្នែកទី៥ត្រូវបានប្រើប្រាស់ជាមូលដ្ឋានដើម្បីបង្កើត និងកំណត់អាទិភាព យុទ្ធសាស្ត្រ និងវិធានការគោលនយោបាយ ពាក់ព័ន្ធនឹងប្រសិទ្ធភាពថាមពល ដូចខាងក្រោមនេះ៖

១. រៀបចំបង្កើតកម្មវិធីបទដ្ឋាន និងការបិទស្លាកសញ្ញា តាមរយៈការបង្កើតបទប្បញ្ញត្តិស្តីពី "***បទដ្ឋានគុណផលការប្រើប្រាស់ថាមពលអប្បបរមា***" (ប.គ.ថ.អ.) សម្រាប់ឧបករណ៍ និងបរិក្ខារអគ្គិសនី ជាពិសេសម៉ាស៊ីនត្រជាក់ ទូទឹកកក កង្ហារ អំពូលភ្លើង ម៉ាស៊ីនបោកគក់ ទូរទស្សន៍ ម៉ាស៊ីនត្រជាក់ធំៗ ម៉ូទ័រអគ្គិសនី កុំប្រេស័រខ្យល់ ចង្ក្រានអគ្គិសនី កំសៀវទឹកអគ្គិសនី ។ល។ ដោយ៖

ក. ដាក់ចេញនូវ អនុក្រឹត្យស្តីពីការគ្រប់គ្រង និងលើកកម្ពស់ប្រសិទ្ធភាពថាមពលនៃបរិក្ខារប្រើប្រាស់អគ្គិសនី ដែលនឹងកំណត់អំពីនីតិវិធីទូទៅសម្រាប់បញ្ញត្តិលើ "***បទដ្ឋាននិងការបិទស្លាកសញ្ញា***" សម្រាប់ឧបករណ៍ ឬបរិក្ខារប្រើប្រាស់អគ្គិសនី។ បទប្បញ្ញត្តិបច្ចេកទេសសម្រាប់អនុវត្ត "***បទដ្ឋាននិងការបិទស្លាកសញ្ញា***" លើឧបករណ៍ និងបរិក្ខារអគ្គិសនី ត្រូវធ្វើឡើងតាមរយៈ ប្រកាសរបស់ស្ថាប័នបង្គោល និងស្ថាប័នដៃគូ ដែលនឹងកំណត់អំពីប.គ.ថ.អ. សេចក្តីណែនាំសម្រាប់ការធ្វើតេស្ត និងវិធីសាស្ត្រវាយតម្លៃប្រសិទ្ធភាពថាមពល។ល។ សម្រាប់ឧបករណ៍ ឬបរិក្ខារប្រើប្រាស់អគ្គិសនីនីមួយៗ។

ខ. ជ្រើសរើសបទដ្ឋានធ្វើតេស្តអន្តរជាតិ និងស្តង់ដារជាតិសមស្រប សម្រាប់ឧបករណ៍ ឬ បរិក្ខារប្រើប្រាស់ថាមពលអគ្គិសនី ដោយអនុលោមតាមបទដ្ឋានធ្វើតេស្តដែលអនុវត្តក្នុងបណ្តាប្រទេសក្នុងតំបន់អាស៊ាន ឬតាមបទដ្ឋានធ្វើតេស្តរបស់ប្រទេសនាំចូល ប្រសិនបើមានលក្ខខណ្ឌតម្រូវ។

២. រៀបចំ"***វិធានថាមពលសម្រាប់អគារ***" (វ.ថ.អ.) សម្រាប់អគារលំនៅឋាន អគារពាណិជ្ជកម្ម និងអគារផ្សេងទៀត រួមទាំងពិធីសារស្តីពី វ.រ.ផ. សម្រាប់ការប្រើប្រាស់ថាមពល ដូចខាងក្រោម៖

ក. ត្រូវរៀបចំបំពេញបន្ថែមលើបទប្បញ្ញត្តិបច្ចេកទេសសំណង់ គោលការណ៍ណែនាំអំពីអគារបៃតង និងប្រព័ន្ធចំណាត់ថ្នាក់អគារបៃតង។

ខ. រៀបចំវិធានគ្រប់គ្រងបទប្បញ្ញត្តិ ការសិក្សាគម្រោងប្លង់ និងកិច្ចប្រតិបត្តិការនៃអគារក្នុងគោលបំណង ពង្រឹងការអនុវត្តសកម្មភាពប្រើប្រាស់ថាមពលក្នុងអគារ តាមរយៈការកំណត់លក្ខខណ្ឌតម្រូវ និង/ឬ ការ ដាក់កំហិតឱ្យអគារថ្មី និងអគារមានស្រាប់អនុវត្ត។ វិធាននេះ ត្រូវដាក់ចេញនូវការកំណត់ដូចខាងក្រោម៖ ទី១) កំណត់លក្ខណៈនៃការងារសិក្សាគម្រោងប្លង់ដោយគិតគូរពីប្រសិទ្ធភាពថាមពល ដូចជាការកំណត់ ឱ្យប្រើសម្ភារៈសំណង់សម្រាប់សាងសង់ "*ស្រោមអគារ*" ដោយផ្អែកលើប៉ារ៉ាម៉ែត្រ កម្ដៅ និងប៉ារ៉ាម៉ែត្រ ពាក់ព័ន្ធផ្សេងទៀត ការកំណត់លក្ខណៈការងារសិក្សាគម្រោង ប្លង់ដោយអកម្មជាមួយថាមពល (**ឧទាហរណ៍** បច្ចេកទេសធ្វើឱ្យត្រជាក់ដោយអកម្មជាមួយថាមពល និងបច្ចេកវិទ្យាបញ្ចេញកាបូនទាប ផ្សេងទៀតដោយគិតគូរទៅលើទម្លាប់នៃការសាងសង់ដែលកំពុងដំណើរការ សម្ភារៈ និងបច្ចេកវិទ្យា សំណង់ដែលមាននៅកម្ពុជា។ ទី២)កំណត់កម្រិតអតិបរមាដែលអនុញ្ញាតសម្រាប់ស្រោមអគារក្នុងការ ចម្លងកម្តៅ និងកម្រិតនៃអាំងតង់ស៊ីតេថាមពលអតិបរមាសម្រាប់អគារពាណិជ្ជកម្ម និងអគារផ្សេងទៀត និងលំនៅឋានផ្សេងៗ និងទី៣) បង្កើតស្លាកសញ្ញាសម្រាប់អគារពាណិជ្ជកម្ម និងអគារផ្សេងទៀត និង លំនៅឋាន ប្រើថាមពលក្រោមកម្រិតអាំងតង់ស៊ីតេអតិបរមា ដែលបានកំណត់សម្រាប់ប្រភេទនីមួយៗ របស់អគារ។ វិធានថាមពលសម្រាប់អគារក៏ត្រូវសមស្របជាមួយបទដ្ឋាននិងគោលការណ៍ណែនាំរបស់ អាស៊ានផងដែរ។

គ. រៀបចំកម្មវិធីជំរុញ និងអភិវឌ្ឍមូលដ្ឋានផលិតកម្មនិងខ្សែច្រវាក់តម្លៃក្នុងស្រុកសម្រាប់សម្ភារៈ សំណង់ ដែលមានប្រសិទ្ធភាពសមស្របសម្រាប់ការងារសិក្សាគម្រោងប្លង់ស្រោមអគារដែលមាន ប្រសិទ្ធភាពថាមពល ដូចដែលបានកំណត់នៅក្នុងវិធានថាមពលសម្រាប់អគារ។

ឃ. រៀបចំដាក់ចេញអនុក្រឹត្យកំណត់អំពីនីតិវិធីទូទៅសម្រាប់ការបញ្ញត្តិអគារលំនៅឋាន អគារ ពាណិជ្ជកម្ម និងអគារផ្សេងទៀត។

៣. រៀបចំបង្កើត និងដាក់ឱ្យអនុវត្តគោលការណ៍ណែនាំអំពីអគារបៃតង ដោយរាប់បញ្ចូលទាំងយន្តការផ្តល់ វិញ្ញាបនបត្រផងដែរ។ គោលការណ៍ណែនាំទាំងនេះ នឹងត្រូវដាក់បញ្ចូលទៅក្នុងវិធានថាមពល សម្រាប់អគារផងដែរ។

៤. សិក្សា និងពិនិត្យលទ្ធភាពក្នុងការផ្តល់ការលើកទឹកចិត្តផ្នែកសារពើពន្ធ និងហិរញ្ញវត្ថុ ដោយពិគ្រោះ យោបល់ជាមួយ ក.ស.ហ.វ. ដើម្បីលើកទឹកចិត្តដល់ការទទួលយកឧបករណ៍ ឬបរិក្ខារប្រសិទ្ធភាព ថាមពល និងការអនុម័តវិធានការដើម្បីបង្កើនប្រសិទ្ធភាពថាមពលសម្រាប់អគារ ដូចជា៖

ក. បច្ចេកវិទ្យាធ្វើឱ្យត្រជាក់ និងក្តៅដោយអកម្មជាមួយថាមពល។

៤. សម្ភារៈសម្រាប់ការងារសិក្សាគម្រោងប្លង់សំណង់ស្រោមអគារដែលមានប្រសិទ្ធភាពថាមពល។ រាជរដ្ឋាភិបាលកម្ពុជា នឹងស្វែងរកបន្ថែមទៀតអំពីលទ្ធភាពនៃការផ្គត់ផ្គង់ជាសាធារណៈនូវឧបករណ៍ ឬបរិក្ខារប្រសិទ្ធភាពថាមពលសម្ភារៈសំណង់ដែលមានប្រសិទ្ធភាព និងបច្ចេកវិទ្យាធ្វើឱ្យត្រជាក់និងក្តៅដោយអកម្មជាមួយថាមពល។

៥. ផ្តល់ការបណ្តុះបណ្តាលដល់ស្ថាបត្យករ អ្នកវិជ្ជាជីវៈ និងអ្នកប្រកបរបរក្នុងវិស័យសំណង់ អ្នកជំនាញក្នុងវិស័យសំណង់ និងអ្នកប្រកបអាជីវកម្មក្នុងវិស័យសំណង់ ក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពលដល់បុគ្គលិកនៃក្រសួងស្ថាប័នពាក់ព័ន្ធ (បញ្ញត្តិករថាមពលសម្រាប់អគារ) ក៏ដូចជា ភាគីពាក់ព័ន្ធដទៃទៀត ស្តីពីការអនុវត្តប្រសិទ្ធភាពថាមពលនៅក្នុងអគារ។

៦. យុទ្ធសាស្ត្រដែលបានលើកឡើងនៅក្នុងចំណុច ៦.១.១ នៅត្រង់ចំណុច ១ ចំណុច ២ ចំណុច ៣ និងចំណុច ៦ សម្រាប់វិស័យឧស្សាហកម្ម ក៏ត្រូវអនុវត្តចំពោះវិស័យអគារនេះផងដែរ។

### ៦.១.៣. វិស័យសេវាសាធារណៈ

ដោយសារតែនគរូបនីយកម្មរបស់ប្រទេសកម្ពុជាកំពុងតែរីកចំរើនកាន់តែខ្លាំង សេវាសាធារណៈបានដើរតួនាទីកាន់តែសំខាន់ក្នុងការបំពេញតម្រូវការរបស់ពលរដ្ឋ។ ក្នុងឆ្នាំ២០២០ ក្នុងចំណោមសេចក្តីត្រូវការថាមពលអគ្គិសនីសរុបនៅកម្ពុជាមាន ២,២% ត្រូវបានប្រើប្រាស់ដោយវិស័យសេវាសាធារណៈរបស់រាជរដ្ឋាភិបាល រួមមានការប្រើប្រាស់ថាមពលដោយការបំភ្លឺផ្លូវ និងការបូមទឹកកខ្វក់របស់ទីក្រុង។

ដើម្បីកាត់បន្ថយកំណើនតម្រូវការថាមពលក្នុងវិស័យនេះ ការអនុវត្តវិធានប្រសិទ្ធភាពថាមពលលើការប្រើប្រាស់ថាមពលអគ្គិសនីសម្រាប់ការបំភ្លឺផ្លូវ និងការបូមទឹកកខ្វក់ ដើរតួនាទីដ៏សំខាន់។ ចំពោះការបំភ្លឺផ្លូវ ឧបសគ្គធំៗក្នុងការធ្វើឱ្យប្រសើរឡើងនូវការប្រើថាមពល រួមមានការប្រើប្រាស់អំពូលធម្មតា ដោយមិនប្រើប្រព័ន្ធបញ្ជាឆ្លាតវៃ និងការប្រើប្រាស់នីតិវិធីដោយដៃសម្រាប់ប្រតិបត្តិការ និងការថែទាំ។ ស្រដៀងគ្នាដែរ ចំពោះការបូមទឹកកខ្វក់ ការប្រើប្រាស់ម៉ាស៊ីនម៉ាស៊ូតដើម្បីដំណើរការការបូមទឹក នាំឱ្យមានប្រតិបត្តិការមិនមានប្រសិទ្ធភាព។ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ សសរស្តម្ភយុទ្ធសាស្ត្រដែលបានកំណត់ក្នុងផ្នែកទី៥ ត្រូវបានប្រើជាមូលដ្ឋានដើម្បីបង្កើត និងផ្តល់អាទិភាពដល់យុទ្ធសាស្ត្រ និងវិធានការគោលនយោបាយប្រសិទ្ធភាពថាមពល សម្រាប់វិស័យសេវាសាធារណៈដូចខាងក្រោម៖

១. ការបំភ្លឺផ្លូវ៖

ក. បង្កើត វិធានស្តីពីការបំភ្លឺ និងសម្របសម្រួល បទដ្ឋានការបំភ្លឺរបស់កម្ពុជា ឱ្យស្របគ្នាជាមួយ បទដ្ឋានការបំភ្លឺអន្តរជាតិ រួមទាំងបទដ្ឋានរបស់អាស៊ានផងដែរ។

ខ. បញ្ចូលគម្រោងប្រសិទ្ធភាពថាមពលនៃការបំភ្លឺផ្លូវ ទៅក្នុងផែនការទីក្រុងឆ្លាតវៃ។

គ. បង្កើតពិធីសារ វ.វ.ផ. សម្រាប់ការបំភ្លឺផ្លូវដែលមានប្រសិទ្ធភាពថាមពល។

ឃ. ផ្លាស់ប្តូរអំពូលភ្លើងធម្មតាជំនួសដោយអំពូលអិលអ៊ីឌី ដែលមានប្រសិទ្ធភាពខ្ពស់ ការពង្រីក វិសាលភាពនៃការបំភ្លឺផ្លូវទៅកាន់តំបន់ថ្មីៗ និងការធ្វើទំនើបកម្មប្រព័ន្ធបញ្ជាសម្រាប់ការបំភ្លឺ សាធារណៈដោយប្រើឧបករណ៍បញ្ជាឆ្លាតវៃ។

ង. បង្កើត គោលការណ៍ណែនាំ សម្រាប់ការដំណើរការនិងការថែទាំការបំភ្លឺសាធារណៈដែលឆ្លាតវៃ និងមានប្រសិទ្ធភាពថាមពល។

ច. បណ្តុះបណ្តាលបុគ្គលិកថ្នាក់ខេត្ត និងក្រុមហ៊ុនដំណើរការ និងថែទាំដើម្បីគ្រប់គ្រងការបំភ្លឺឆ្លាតវៃ។

២. ការបូមទឹកកខ្វក់៖

ក. ជំនួសម៉ាស៊ីនផលិតអគ្គិសនីប្រើម៉ាស៊ូតដែលដំណើរការសម្រាប់ការបូមទឹកកខ្វក់នៅទីក្រុង មកប្រើ ប្រព័ន្ធដែលមានប្រសិទ្ធភាពជាងមុន។

ខ. បង្កើតគោលការណ៍ណែនាំសម្រាប់ការដំណើរការ និងការថែទាំ។

គ. បណ្តុះបណ្តាលបុគ្គលិកលើការដំណើរការ និងការថែទាំប្រព័ន្ធបូមទឹកកខ្វក់។

### ៦.១.៤. វិស័យដឹកជញ្ជូន

ជាមួយនឹងកំណើនសេដ្ឋកិច្ចរឹងមាំ និងការកើនឡើងជាលំដាប់នៃប្រាក់ចំណូលរបស់ប្រជាពលរដ្ឋម្នាក់ៗ ក្នុងមួយទសវត្សរ៍ចុងក្រោយនេះ ចំនួនយានយន្តសម្រាប់ដឹកជញ្ជូនតាមផ្លូវគោកបាន និងកំពុងកើនឡើងយ៉ាង ឆាប់រហ័សនៅក្នុងប្រទេសកម្ពុជា ដោយអត្រាកំណើនប្រចាំឆ្នាំចាប់ពី ៧-៨% ឡើងទៅ។ គិតត្រឹមឆ្នាំ២០២០ មាន យានយន្តជាង ៥.៨៥០.៤២៧ គ្រឿង ត្រូវបានចុះបញ្ជីនៅក្នុងប្រទេសកម្ពុជា ក្នុងនោះមានម៉ូតូចំនួន ៤.៩៧៤.៤៨៦ គ្រឿង ឬ ស្មើនឹង៨៥% នៃចំនួនយានយន្តសរុបដែលបានចុះបញ្ជី។ រថយន្តធុនស្រាល មាន ចំនួន ៦១៥.១១៣ គ្រឿង និងរថយន្តធុនធ្ងន់ មានចំនួន ២៦០.៨០៨ គ្រឿង។ ចំនួនរថយន្តដែលមានអាយុកាល ប្រើប្រាស់លើសពី ១០ឆ្នាំ មានរហូតដល់ ៤៤,៣% នៃរថយន្តសរុប។ ភាគច្រើននៃយានយន្តដែលត្រូវបានប្រើ សម្រាប់ការដឹកជញ្ជូនតាមផ្លូវគោក គឺជាយានយន្តដែលគេប្រើប្រាស់ម្តងរួចហើយដែលមានប្រសិទ្ធភាពនៃការ

ប្រើប្រេងឥន្ធនៈទាប និងមានការបញ្ចេញឧស្ម័នច្រើន បណ្តាលឱ្យតំបន់ទីក្រុងជួបប្រទះនូវបរិមាណនៃការបញ្ចេញ និងការបំពុលបរិយាកាសកាន់តែខ្ពស់ ជាពិសេសក្នុងកំឡុងពេលចរាចរណ៍មមាញឹក។

កម្ពុជា ពឹងផ្អែកស្ទើរតែទាំងស្រុងលើការនាំចូលប្រេងឥន្ធនៈ ដើម្បីឆ្លើយតបនឹងតម្រូវការសម្រាប់ការដឹកជញ្ជូន។ ក្នុងឆ្នាំ២០១៩ វិស័យដឹកជញ្ជូនប្រើប្រាស់ថាមពល ២៨% នៃការប្រើប្រាស់ថាមពលសរុបនៅកម្ពុជា។ បើគិតពីសមាមាត្រដ៏ច្រើននៃការប្រើប្រាស់ប្រេងឥន្ធនៈក្នុងការដឹកជញ្ជូន មានសក្តានុពលច្រើនសម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅក្នុងវិស័យនេះ តាមរយៈការផ្លាស់ប្តូរមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន ទៅប្រើសេវាដឹកជញ្ជូនសាធារណៈ និងការផ្លាស់ប្តូរពីការប្រើយានយន្តដែលដើរដោយឥន្ធនៈ ទៅប្រើយានយន្តអគ្គិសនីដែលជាជម្រើសបៃតង។ ជម្រើសបៃតងនេះនាំមកនូវផលប្រយោជន៍រួមជាច្រើន ដូចជា ការបង្កើនប្រសិទ្ធភាពថាមពល ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការកែលម្អគុណភាពខ្យល់ និងការកាត់បន្ថយសំឡេងរំខាន។

ដើម្បីដោះស្រាយបញ្ហាប្រឈមតាមវិស័យដែលបានលើកឡើងខាងលើ យុទ្ធសាស្ត្រ និងវិធានការគោលនយោបាយប្រសិទ្ធភាពថាមពលសម្រាប់វិស័យដឹកជញ្ជូនមានដូចខាងក្រោម៖

១. ការដាក់ចេញបទប្បញ្ញត្តិស្តីពីការកំណត់បទដ្ឋាននៃប្រសិទ្ធភាពប្រើប្រេងឥន្ធនៈសម្រាប់យានយន្តក្នុងការដឹកជញ្ជូនតាមផ្លូវគោកដោយមានគោលបំណងកាត់បន្ថយការបំពុលបរិស្ថាន និងកាត់បន្ថយតម្រូវការផលិតផលប្រេងឥន្ធនៈដែលនាំចូល។

២. កម្មវិធីបណ្តុះបណ្តាលអំពីការដឹកជញ្ជូនប្រកបដោយចីរភាព។

៣. ការលើកកម្ពស់បច្ចេកវិទ្យាស្អាត ដូចជា យានយន្តអគ្គិសនីក្នុងផ្នែកយានយន្ត តាមរយៈយុទ្ធនាការលើកកម្ពស់ការយល់ដឹង។

## ៦.២. គោលដៅតាមវិស័យ

គោលដៅប្រសិទ្ធភាពថាមពលតាមវិស័យត្រូវបានកំណត់ដោយផ្អែកលើគំរូវិភាគ ដែលត្រូវបានបង្កើតឡើងដើម្បីប៉ាន់ប្រមាណការសន្សំថាមពលបានពីការអនុវត្តផែនការសកម្មភាពប្រសិទ្ធភាពថាមពលសម្រាប់វិស័យនៃការប្រើប្រាស់ថាមពលចុងក្រោយពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣០។ គំរូវិភាគនេះ ធ្វើឡើងដោយគិតគូរលើសេណារីយ៉ូខាងក្រោម៖

១. សេណារីយ៉ូធុរកិច្ចធម្មតា៖ ដោយមិនគិតពីការបង្កើនប្រសិទ្ធភាពថាមពល។

២. សេណារីយ៉ូបង្កើនប្រសិទ្ធភាពថាមពល៖ ជាមួយនឹងការអនុវត្តវិធានការប្រសិទ្ធភាពថាមពលក្នុងកម្រិតមហិច្ឆតាខ្ពស់ល្មម។
៣. សេណារីយ៉ូសុទិដ្ឋិនិយម៖ ជាមួយនឹងការអនុវត្តវិធានការប្រសិទ្ធភាពថាមពលក្នុងកម្រិតមហិច្ឆតាខ្ពស់ខ្លាំង។

គោលដៅបង្កើនប្រសិទ្ធភាពថាមពលតាមវិស័យដែលបានកំណត់នៅក្នុងគោលនយោបាយនេះ គឺផ្អែកលើការកាត់បន្ថយសក្តានុពលនៃការប្រើប្រាស់ថាមពល ក្នុង"សេណារីយ៉ូបង្កើនប្រសិទ្ធភាពថាមពល" ដែលជាលទ្ធផលនៃការអនុវត្តផែនការប្រសិទ្ធភាពថាមពលដែលនឹងមិនកើតឡើងក្នុង"សេណារីយ៉ូធុរកិច្ចធម្មតា" ទេ។ គោលដៅទាំងនេះ ត្រូវបានកំណត់តាមរយៈគំរូវិភាគផ្អែកលើប្រភពទិន្នន័យបឋមនិងទិន្នន័យទុតិយតា បទពិសោធន៍សាកល្បងក្នុងតំបន់ ឧត្តមានុវត្តន៍អន្តរជាតិលើការអនុវត្តផែនការប្រសិទ្ធភាពថាមពល ធាតុចូលពីអ្នកជំនាញ និងការពិគ្រោះយោបល់ជាមួយស្ថាប័នរដ្ឋាភិបាល។ គោលដៅបង្កើនប្រសិទ្ធភាពថាមពលតាមវិស័យនៃការប្រើប្រាស់ថាមពលមានបង្ហាញជូនដូចខាងក្រោម។

### ៦.២.១. វិស័យឧស្សាហកម្មកម្មន្តសាល

គោលដៅបង្កើនប្រសិទ្ធភាពថាមពលក្នុងវិស័យឧស្សាហកម្ម គឺផ្តោះទៅរកការសម្រេចឱ្យបានការសន្សំសំចៃថាមពលនៅក្នុងអនុវិស័យមួយចំនួន ដូចជា សម្លៀកបំពាក់ រោងម៉ាស៊ីនកិនស្រូវ ភេសជ្ជៈ ផលិតកម្មឥដ្ឋ ផលិតកម្មស្បែកជើង ផលិតកម្មស៊ីម៉ងត៍ ផលិតកម្មកៅស៊ូ និងផ្សេងៗទៀត។ អនុវិស័យផ្សេងៗទៀតនេះនឹងត្រូវបានជ្រើសរើសដោយផ្អែកលើការចូលរួមចំណែករបស់អនុវិស័យនេះ ក្នុងផលិតផលក្នុងស្រុកសរុប ការប្រើប្រាស់ថាមពល ចំណែកនៃការនាំចេញ និងវិស័យអាទិភាពសម្រាប់ការអភិវឌ្ឍ។ សំណុំបច្ចេកវិទ្យាប្រសិទ្ធភាពថាមពលទាំងសម្រាប់វិស័យ និងសម្រាប់ចម្រុះវិស័យ មានរាប់បញ្ចូលក្នុងវិធានការអនុវត្តគោលដៅបង្កើនប្រសិទ្ធភាពថាមពលក្នុងវិស័យឧស្សាហកម្មនេះ ដោយគិតគូរពីសក្តានុពលនៃការសន្សំសំចៃថាមពល ការពង្រីកការអនុវត្តបាន និងតម្រូវការវិនិយោគដើម្បីសម្រេចគោលដៅដែលបានស្នើឡើង។

*គោលដៅបង្កើនប្រសិទ្ធភាពថាមពលក្នុងវិស័យឧស្សាហកម្ម គឺ ២០% នៅឆ្នាំ២០៣០ មានន័យថានឹងកាត់បន្ថយកំណើនតម្រូវការថាមពលក្នុងវិស័យឧស្សាហកម្មពី ៣៨.៦០០ GWh តាមកំណើនតម្រូវការថាមពលក្នុង "សេណារីយ៉ូធុរកិច្ចធម្មតា" មកត្រឹមតែ ៣០.៨៨០ GWh តាម "សេណារីយ៉ូបង្កើនប្រសិទ្ធភាពថាមពល"។*

### ៦.២.២. វិស័យអគារលំនៅឋាន

គោលដៅបង្កើនប្រសិទ្ធភាពថាមពលក្នុងវិស័យអគារលំនៅឋាននៃគោលនយោបាយនេះ អនុម័តយកការអនុវត្តផែនការសកម្មភាព ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការប្រើប្រាស់ថាមពលនៃឧបករណ៍បរិក្ខារប្រើប្រាស់អគ្គិសនីនានា និងឧបករណ៍សម្រាប់ការប្រើប្រាស់ថាមពលចុងក្រោយនានារួមមានភ្លើងបំភ្លឺ ម៉ាស៊ីនត្រជាក់ ទូទឹកកក ម៉ាស៊ីនបោកគក់ កង្ហារ ម៉ូទ័របូមទឹក និងឧបករណ៍ចម្អិនអាហារ។

*គោលដៅបង្កើនប្រសិទ្ធភាពថាមពលក្នុងការប្រើប្រាស់ថាមពលតាមសម្រាប់វិស័យអគារលំនៅឋាន គឺ ៣៤% នៅឆ្នាំ២០៣០ មានន័យថានឹងកាត់បន្ថយកំណើនតម្រូវការថាមពលក្នុងវិស័យអគារលំនៅឋានពី ១៧.៩៨១ GWh តាមកំណើនតម្រូវការថាមពលក្នុង "សេណារីយ៉ូធុរកិច្ចធម្មតា" មកត្រឹមតែ ១១.៨២៦ GWh នៅក្នុង "សេណារីយ៉ូបង្កើនប្រសិទ្ធភាពថាមពល"។*

### ៦.២.៣. វិស័យអគារពាណិជ្ជកម្ម និងអគារផ្សេងទៀត

គោលដៅបង្កើនប្រសិទ្ធភាពថាមពលសម្រាប់វិស័យអគារពាណិជ្ជកម្ម និងអគារផ្សេងទៀត អនុម័តយកការអនុវត្តផែនការសកម្មភាព ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការប្រើប្រាស់ថាមពលសម្រាប់ម៉ាស៊ីនត្រជាក់ និងប្រព័ន្ធភ្លើងបំភ្លឺដែលជាការចូលរួមចំណែកធំបំផុតចំពោះតម្រូវការប្រើប្រាស់ថាមពលសរុប នៅក្នុងអគារទាំងនេះ។

*គោលដៅបង្កើនប្រសិទ្ធភាពថាមពលសម្រាប់វិស័យអគារពាណិជ្ជកម្ម និងអគារផ្សេងទៀត គឺ ២៥% នៅឆ្នាំ ២០៣០ មានន័យថានឹងកាត់បន្ថយកំណើនតម្រូវការថាមពលសម្រាប់វិស័យអគារពាណិជ្ជកម្ម និងអគារផ្សេងទៀត ពី ៨.៥៥២ GWh តាមកំណើនតម្រូវការថាមពលក្នុង "សេណារីយ៉ូធុរកិច្ចធម្មតា" មកត្រឹមតែ ៦ ៤៣១ GWh នៅក្នុង "សេណារីយ៉ូបង្កើនប្រសិទ្ធភាពថាមពល"។*

### ៦.២.៤. វិស័យសេវាសាធារណៈ

គោលដៅបង្កើនប្រសិទ្ធភាពថាមពលសម្រាប់វិស័យសេវាសាធារណៈ អនុម័តយកការអនុវត្តផែនការសកម្មភាពដើម្បីបង្កើនប្រសិទ្ធភាពថាមពលនៅក្នុងការប្រើប្រាស់ថាមពលនៃភ្លើងបំភ្លឺតាមដងផ្លូវ សួនច្បារ និងការធ្វើប្រព្រឹត្តកម្មនិងបូមទឹកកខ្វក់។ ទាក់ទងនឹងកម្មវិធីភ្លើងបំភ្លឺតាមដងផ្លូវនិងសួនច្បារ ការកំណត់គោលដៅបង្កើនប្រសិទ្ធភាពថាមពលសម្រាប់ភ្លើងបំភ្លឺតាមដងផ្លូវនិងសួនច្បារ បានគិតគូរពីការសន្សំសំចៃថាមពលដោយប្រើបច្ចេកវិទ្យាភ្លើងបំភ្លឺតាមដងផ្លូវនិងសួនច្បារ ដែលមានប្រសិទ្ធភាពថាមពលជាងមុន ដើម្បីជំនួស

អំពូលធម្មតាដែលមានស្រាប់។ ចំពោះការធ្វើប្រព្រឹត្តកម្មនិងបូមទឹកកខ្វក់ ការកំណត់គោលដៅតាមវិស័យបានពិចារណាអំពីការជំនួសម៉ាស៊ីនភ្លើងម៉ាស៊ូតដែលគ្មានប្រសិទ្ធភាព សម្រាប់ការធ្វើប្រព្រឹត្តកម្មនិងបូមទឹកដោយប្រើប្រព័ន្ធថាមពលដែលមានប្រសិទ្ធភាពជាងមុនវិញ។

*គោលដៅបង្កើនប្រសិទ្ធភាពថាមពលសម្រាប់វិស័យសេវាសាធារណៈ គឺ ២៩% នៅឆ្នាំ២០៣០ មានន័យថានឹងកាត់បន្ថយកំណើនតម្រូវការថាមពលសម្រាប់វិស័យសេវាសាធារណៈ ពី ៤២ GWh នៅក្នុង "សេណារីយ៉ូធុរកិច្ចធម្មតា" មកត្រឹមតែ ៣០ GWh នៅក្នុង "សេណារីយ៉ូបង្កើនប្រសិទ្ធភាពថាមពល"។*

### ៦.២.៥. វិស័យដឹកជញ្ជូន

គោលដៅបង្កើនប្រសិទ្ធភាពថាមពលសម្រាប់វិស័យដឹកជញ្ជូន គោលនយោបាយនេះបានពិចារណាយកការអនុវត្តផែនការសកម្មភាពប្រសិទ្ធភាពថាមពលចំនួនពីរប្រភេទ គឺការផ្លាស់ប្តូរបន្តិចម្តងៗ ពីយានយន្តប្រើម៉ាស៊ីនចំហេះក្នុង ទៅប្រើប្រាស់យានយន្តអគ្គិសនីវិញ និងការងាកមកប្រើប្រាស់ស្តង់ដារប្រសិទ្ធភាពឥន្ធនៈកាន់តែតឹងរឹងជាងមុនសម្រាប់យានយន្តប្រើម៉ាស៊ីនចំហេះក្នុង។ ការអនុវត្តផែនការសកម្មភាពប្រសិទ្ធភាពថាមពលទាំងនេះ ត្រូវអនុវត្តទៅលើប្រភេទយានយន្តដូចខាងក្រោម៖

១. ទោចក្រយាន ត្រីចក្រយាន យានយន្តចល័តខ្នាតតូច (កង់អគ្គិសនី)

២. យានយន្តទេសចរណ៍

៣. រថយន្តដឹកអ្នកដំណើរ

៤. រថយន្តសាធារណៈ

៥. តាក់ស៊ី និងរថយន្តក្រុង។

*គោលដៅបង្កើនប្រសិទ្ធភាពថាមពលសម្រាប់វិស័យដឹកជញ្ជូន គឺ ៥ % នៅឆ្នាំ២០៣០ មានន័យថានឹងកាត់បន្ថយកំណើនតម្រូវការថាមពលសម្រាប់វិស័យដឹកជញ្ជូន ពី ២៤.៦៦២ GWh នៅក្នុង "សេណារីយ៉ូធុរកិច្ចធម្មតា" មកត្រឹមតែ ២៣.៣៨៣ GWh នៅក្នុង "សេណារីយ៉ូបង្កើនប្រសិទ្ធភាពថាមពល"។*

## ៦.៣. វិធានការគោលនយោបាយតាមវិស័យនៃការប្រើប្រាស់ថាមពល

គោលនយោបាយនេះ ដាក់ចេញនូវវិធានការគោលនយោបាយសម្រាប់ការអនុវត្តការងារប្រសិទ្ធភាពថាមពល តាមវិស័យនៃការប្រើប្រាស់ថាមពលដែលកំណត់ក្នុងតារាងខាងក្រោម៖

| វិធានការគោលនយោបាយតាមវិស័យ | ឆ្នាំ | | | | | | | | | វិស័យ |
|---|---|---|---|---|---|---|---|---|---|---|
| | ២២ | ២៣ | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ | |
| បទដ្ឋាន និងការបិទស្លាកសញ្ញាសម្រាប់ឧបករណ៍ និង បរិក្ខារប្រើប្រាស់ថាមពល និងបទប្បញ្ញត្តិបទដ្ឋានគុណផលការប្រើប្រាស់ថាមពលអប្បបរមា | ■ | ■ | | | | | | | | ឧស្សាហកម្ម និង អគារ |
| ការអនុវត្តកម្មវិធីបណ្តុះបណ្តាល និងវិញ្ញាបនបត្រកម្មសវនករថាមពល | | ■ | | | | | | | | |
| ការបង្កើតកម្មវិធីគ្រប់គ្រងថាមពល | ■ | ■ | ■ | | | | | | | |
| រៀបចំ និងអនុវត្តសាកល្បងគោលការណ៍ណែនាំនិងវិញ្ញាបនបត្រកម្មអគារបៃតង | ■ | ■ | ■ | | | | | | | |
| បទប្បញ្ញត្តិផ្សេងៗដើម្បីអនុវត្តវិធានការចាំបាច់នានានៃកម្មវិធីគ្រប់គ្រងថាមពល | | ■ | ■ | | | | | | | |
| បទប្បញ្ញត្តិ និងស្ថាបនកម្មការរៀបចំវិធានថាមពលសម្រាប់អគារ | | ■ | ■ | | | | | | | |
| ប្រព័ន្ធតាមដាន រាយការណ៍ ផ្ទៀងផ្ទាត់សម្រាប់អ្នកប្រើប្រាស់ថាមពលមុខសញ្ញា | | ■ | ■ | ■ | ■ | | | | | |
| បង្កើតវិធានស្តីពីការបំភ្លឺ ការរៀបចំបទដ្ឋាននៃការបំភ្លឺសាធារណៈ | | | ■ | ■ | | | | | | សេវាសាធារណៈ |
| ដាក់បញ្ចូលគម្រោងប្រសិទ្ធភាពថាមពលទៅក្នុងសេវាសាធារណៈ និងផែនការទីក្រុងឆ្លាតវៃ | | | | ■ | ■ | | | | | |
| បទប្បញ្ញត្តិនានាសម្រាប់ជំរុញការប្រើប្រាស់យានយន្តអគ្គិសនី និងហេដ្ឋារចនាសម្ព័ន្ធបញ្ចូលថាមពលយានយន្តអគ្គិសនី | | | | | | ■ | | | | ដឹកជញ្ជូន |
| បទប្បញ្ញត្តិនានាសម្រាប់ប្រសិទ្ធភាពឥន្ធនៈនៅក្នុងវិស័យដឹកជញ្ជូន | | | | ■ | ■ | ■ | ■ | ■ | ■ | |
| ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព | | ■ | ■ | | | | | | | អន្តរវិស័យ |
| យុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីវិធានការប្រសិទ្ធភាពថាមពល | | ■ | ■ | | | | | | | |
| ការរៀបចំគម្រោងគាំទ្រដល់សកម្មភាពប្រសិទ្ធភាពថាមពលតាមវិស័យ | | ■ | ■ | ■ | ■ | ■ | | | | |

វិធានការគោលនយោបាយ និងផែនការសកម្មភាព មានចែងលម្អិតក្នុងឧបសម្ព័ន្ធ២។

# ៧- យន្តការសម្រាប់ដឹកនាំ សម្របសម្រួល និងអនុវត្ត

## ៧.១. រចនាសម្ព័ន្ធអភិបាលកិច្ច

ការអនុវត្តគោលនយោបាយនេះ ត្រូវការការដឹកនាំមួយខ្លាំងពីរាជរដ្ឋាភិបាល ដែលត្រូវគាំទ្រដោយយន្តការសម្របសម្រួលមួយដែលមានគោលបំណង និងតួនាទីសម្រាប់ស្ថាប័នពាក់ព័ន្ធច្បាស់លាស់។ ក្នុងន័យនេះ គោលនយោបាយនេះ ដាក់ចេញនូវយន្តការអភិបាលកិច្ច ដូចខាងក្រោម៖

១. កំណត់តួនាទី ភារកិច្ច និងការទទួលខុសត្រូវ សម្រាប់ស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

២. រៀបចំរចនាសម្ព័ន្ធ និងកិច្ចដំណើការស្ថាប័ន ដើម្បីធានាការសម្របសម្រួលរវាងស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តគោលនយោបាយនេះ។

៣. រៀបចំឧបករណ៍ផ្លូវច្បាប់ រដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ការអនុវត្តគោលនយោបាយនេះ។

លក្ខណៈពិសេសនៃក្របខណ្ឌអភិបាលកិច្ចនេះ មានបង្ហាញក្នុងរូបភាពខាងក្រោម៖




*រូបភាពទី២៖ រចនាសម្ព័ន្ធអភិបាលកិច្ចគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០*

គ.ស.ហ. មានភារកិច្ចដឹកនាំ ត្រួតពិនិត្យ តាមដាន សម្របសម្រួល និងផ្តល់ការតម្រង់ទិសជាគោលនយោបាយឱ្យ "**គណៈកម្មាធិការជាតិប្រសិទ្ធភាពថាមពល**" ទាក់ទងនឹងការអនុវត្តគោលនយោបាយ និងផែនការសកម្មភាពនៃគោលនយោបាយ។

ក្នុងក្របខណ្ឌអភិបាលកិច្ចនេះ រាជរដ្ឋាភិបាលនឹងបង្កើតគណៈកម្មាធិការជាតិមួយ ដែលដឹកនាំដោយក្រសួងរ៉ែ និងថាមពល និងមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ ដើម្បីគ្រប់គ្រងការអនុវត្តការងារប្រសិទ្ធភាពថាមពលនៅកម្ពុជាហៅថា"**គណៈកម្មាធិការជាតិប្រសិទ្ធភាពថាមពល**"។ គណៈកម្មាធិការនេះមានមុខងារជាអង្គភាពអភិបាលក្នុងការសម្របសម្រួលអនុវត្តសកម្មភាពប្រសិទ្ធភាពថាមពលនៅគ្រប់វិស័យដែលប្រើប្រាស់ថាមពល និងមានលេខាធិការដ្ឋានមួយជាសេនាធិការ។ គណៈកម្មាធិការជាតិនេះ ត្រូវរាយការណ៍ជូន គ.ស.ហ. និងអនុវត្តតាមការណែនាំរបស់ គ.ស.ហ.។ ដើម្បីបំពេញភារកិច្ចរបស់ខ្លួន គណៈកម្មាធិការជាតិប្រសិទ្ធភាពថាមពល ត្រូវមាន "***អនុគណៈកម្មាធិការប្រសិទ្ធភាពថាមពលតាមវិស័យ***" ដែលត្រូវបានបង្កើតឡើងដោយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីទទួលអនុវត្តការងារប្រសិទ្ធភាពថាមពល តាមវិស័យដែលក្រសួងស្ថាប័ននោះទទួលបន្ទុករៀងៗខ្លួន ដែលក្នុងនោះរួមមាន ក.ឧ.វ.ប.ន. សម្រាប់វិស័យឧស្សាហកម្ម ក.ដ.ន.ស. សម្រាប់វិស័យអគារ និង ក.ស.ដ. សម្រាប់វិស័យសេវាសាធារណៈនិងដឹកជញ្ជូន។

ក្របខណ្ឌអភិបាលកិច្ចនេះ ផ្តល់សិទ្ធិអំណាចពេញលេញដល់ក្រសួងរ៉ែ និង ថាមពល ដើម្បីបំពេញមុខងារជា "***ស្ថាប័នបង្គោល***" សម្រាប់ការអនុវត្តគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពលនេះ។ ក្នុងដែនសមត្ថកិច្ចនេះ ក្រសួងរ៉ែ និងថាមពល ដើរតួនាទីនាំមុខក្នុងការអភិវឌ្ឍប្រសិទ្ធភាពថាមពលនៅកម្ពុជា ហើយនឹងទទួលខុសត្រូវចំពោះការងារត្រួតពិនិត្យ សម្របសម្រួល និងអនុវត្តបទប្បញ្ញត្តិដែលមានចែងក្នុងគោលនយោបាយនេះ។ ការផ្តល់សិទ្ធិអំណាចខាងលើនេះ គឺដើម្បីអនុញ្ញាតឱ្យក្រសួងរ៉ែ និងថាមពល បំពេញការទទួលខុសត្រូវរបស់ខ្លួនក្នុងនាមជា "ស្ថាប័នបង្គោល"។

ក្របខណ្ឌអភិបាលកិច្ចនេះ ក៏រៀបចំឱ្យមាន"***ស្ថាប័នដៃគូ***" ដើម្បីកំណត់ឱ្យស្ថាប័នរាជរដ្ឋាភិបាលផ្សេងទៀតមានតួនាទីពង្រឹងនិងអនុវត្តការងារប្រសិទ្ធភាពថាមពលនៅកម្ពុជាតាមវិស័យរបស់ខ្លួន។ នៅថ្នាក់ជាតិក្រសួងស្ថាប័នដៃគូរួមមាន ក.ស.ហ.វ., ក.ឧ.វ.ប.ន., ក.ដ.ន.ស., ក.ស.ដ. ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អគ្គិសនីកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជា ក.អ.ក. និងក្រសួងបរិស្ថាន។ ការទទួលខុសត្រូវសំខាន់របស់ស្ថាប័នដៃគូ គឺបញ្ច្រាបការងារប្រសិទ្ធភាពថាមពលក្នុងដំណើរការរៀបចំផែនការការងាររបស់ខ្លួន និងចូលរួមការអនុវត្តការងារទាំងនេះតាមវិស័យរបស់ខ្លួន។

ក្នុងចំណោមស្ថាប័នដៃគូខាងលើ ក.ឧ.វ.ប.ន., ក.ដ.ន.ស. និង ក.ស.ដ. ត្រូវបានចាត់តាំងឱ្យទទួលខុសត្រូវ បន្ថែមក្នុងតួនាទីជាអ្នកដឹកនាំការងារប្រសិទ្ធភាពថាមពលនៅក្នុងវិស័យរបស់ខ្លួន។ ក.ឧ.វ.ប.ន. នឹងដឹកនាំការអភិវឌ្ឍប្រសិទ្ធភាពថាមពល នៅក្នុងវិស័យឧស្សាហកម្ម ក.ដ.ន.ស. នៅក្នុងវិស័យអគារ និង ក.ស.ដ. នៅក្នុងវិស័យសេវាសាធារណៈ និងដឹកជញ្ជូន។ ស្ថាប័នដៃគូទាំងនេះទទួលខុសត្រូវចំពោះការបង្កើតនិងការអនុវត្ត

**"ផែនការសកម្មភាពប្រសិទ្ធភាពថាមពលតាមវិស័យ" (ផ.ស.ប្រ.ថ.វ.)** ដែលត្រូវរៀបចំឡើងដោយសហការ និងទទួលការណែនាំបច្ចេកទេសពីស្ថាប័នបង្គោល។ **ផែនការសកម្មភាពប្រសិទ្ធភាពថាមពលតាមវិស័យ** ត្រូវមានបញ្ចូលវិធានការប្រសិទ្ធភាពថាមពលតាមវិស័យ ស្របតាមបទប្បញ្ញត្តិដែលកំណត់ក្នុងផ្នែកទី ៦ ការវាយតម្លៃសមិទ្ធិលទ្ធភាព ផែនការវិនិយោគលើប្រសិទ្ធភាពថាមពល និងផែនទីបង្ហាញផ្លូវការអនុវត្តលម្អិតសម្រាប់វិស័យនេះ។ **ផែនការសកម្មភាពប្រសិទ្ធភាពថាមពលតាមវិស័យ** នឹងត្រូវរៀបចំឡើងរៀងរាល់ ៥ឆ្នាំម្តង ដោយកំណត់យកកាលបរិច្ឆេទចាប់ផ្តើម និងកាលបរិច្ឆេទបញ្ចប់ ស្របជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ សេចក្តីណែនាំសម្រាប់ការរៀបចំ **ផែនការសកម្មភាពប្រសិទ្ធភាពថាមពលតាមវិស័យ** ត្រូវបង្កើតឡើងដោយស្ថាប័នបង្គោល។

នៅកម្រិតថ្នាក់ក្រោមជាតិ រដ្ឋបាលរាជធានី ខេត្តនីមួយៗត្រូវបញ្ចូលការពិចារណាអំពីប្រសិទ្ធភាពថាមពលទៅក្នុងផែនការទីក្រុងបៃតង ឬផែនការទីក្រុងចីរភាពរបស់ខ្លួន។ ក្របខណ្ឌអភិបាលកិច្ចដែលកំណត់ក្នុងគោលនយោបាយនេះ ផ្តល់អំណាចបន្ថែមដល់រដ្ឋបាលរាជធានី ខេត្ត ឱ្យទទួលខុសត្រូវលើការអនុវត្តការងារប្រសិទ្ធភាពថាមពល ដែលមានចែងលម្អិតនៅក្នុងផ្នែកទី៣ នៃផ្នែកទី៧។

ក្របខណ្ឌអភិបាលកិច្ចនេះ ក៏បង្កើតបទប្បញ្ញត្តិសម្រាប់ស្ថាប័នដៃគូដែលទទួលខុសត្រូវអនុវត្តការងារប្រសិទ្ធភាពថាមពលក្នុងដែនសមត្ថកិច្ចខ្លួន ដូចជា ក.ជ.ន.ស., ក.ស.ជ., ក.ឧ.វ.ប.ន. និងរដ្ឋបាលរាជធានី ខេត្ត ក្នុងការតែងតាំង "ការិយាល័យបង្គោលផ្នែកប្រសិទ្ធភាពថាមពល" របស់ស្ថាប័នខ្លួន ដើម្បីជាប្រភពធនធានមនុស្សសម្រាប់គាំទ្រដល់ការបំពេញអាណត្តិរបស់ខ្លួន ស្របតាមគោលនយោបាយនេះផងដែរ។ តួនាទីរបស់ "ការិយាល័យបង្គោលផ្នែកប្រសិទ្ធភាពថាមពល" តាមស្ថាប័នដៃគូខាងលើនេះ រួមមាន៖

១. គាំទ្រដល់ស្ថាប័នដៃគូក្នុងការរៀបចំផែនការសកម្មភាពប្រសិទ្ធភាពថាមពលក្នុងវិស័យរបស់ខ្លួន (សម្រាប់ ក.ជ.ន.ស., ក.ស.ជ. និង ក.ឧ.វ.ប.ន.)។

២. ធ្វើជាតំណាងក្រសួងស្ថាប័នដៃគូ ក្នុងការទំនាក់ទំនងជាមួយស្ថាប័នបង្គោល និងក្រសួងស្ថាប័នរាជរដ្ឋាភិបាល និងឯកជនផ្សេងទៀត ដើម្បីសម្របសម្រួលការអនុវត្តសកម្មភាពដែលទាក់ទងនឹងប្រសិទ្ធភាពថាមពល រួមទាំងការចាប់ផ្តើមគម្រោង ការវាយតម្លៃគម្រោង ការផ្តល់ហិរញ្ញប្បទាន ការអនុវត្ត ការវាស់វែង ការធ្វើរបាយការណ៍និងផ្ទៀងផ្ទាត់ និងការវាយតម្លៃគោលនយោបាយឬផែនការ។

៣. ជួយសម្រួលដល់ការពង្រឹងសមត្ថភាពរបស់បុគ្គលិកក្រសួង ស្ថាប័នដៃគូ លើការធ្វើផែនការ ការសម្របសម្រួល និងការវាយតម្លៃគម្រោងប្រសិទ្ធភាពថាមពល ក៏ដូចជាក្រុមអ្នកពាក់ព័ន្ធដទៃទៀតដែលបានកំណត់ដោយស្ថាប័នដៃគូរៀងៗខ្លួន។

## ៧.២. តួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នបង្គោល

ក្នុងនាមជាស្ថាប័នបង្គោល ក្រសួងរ៉ែ និងថាមពល ត្រូវបានផ្តល់ការទទួលខុសត្រូវលើការធ្វើផែនការ ការសម្របសម្រួល ការជំរុញ និងការចាត់ចែងវិធានការគោលនយោបាយប្រសិទ្ធភាពថាមពលនៅកម្ពុជា។ ស្ថាប័នបង្គោលត្រូវចាត់វិធានការទាំងអស់តាមការចាំបាច់ ដើម្បីសម្រេចចក្ខុវិស័យនិងគោលបំណងនៃគោលនយោបាយនេះ រួមទាំងការកំណត់បទដ្ឋាន និងបទប្បញ្ញត្តិបច្ចេកទេស នវានុវត្តន៍ ការផ្សព្វផ្សាយចំណេះដឹង និងការត្រួតពិនិត្យនិងវាយតម្លៃ។ **អគ្គនាយកដ្ឋានថាមពល** មានតួនាទីជាក្រុមការងារបង្គោលរបស់ក្រសួងរ៉ែ និងថាមពល សម្រាប់សកម្មភាពទាំងអស់ស្តីពីប្រសិទ្ធភាពថាមពល ក្នុងក្របខណ្ឌនៃគោលនយោបាយនេះ។ ក្រសួងរ៉ែ និងថាមពល ត្រូវទទួលខុសត្រូវចំពោះសកម្មភាពដូចខាងក្រោមនេះ៖

**១. ការសម្របសម្រួល និងការណែនាំ**

ក. កំណត់គោលដៅរួម និងគោលដៅជាក់លាក់សម្រាប់ការអនុវត្តការងារប្រសិទ្ធភាពថាមពល និងធ្វើបច្ចុប្បន្នភាព តាមរយៈការធ្វើវិសោធនកម្មគោលនយោបាយ។

ខ. ផ្តល់ការណែនាំបច្ចេកទេសដល់ស្ថាប័នដៃគូ តាមការចាំបាច់ លើគ្រប់ទិដ្ឋភាពដែលទាក់ទងនឹងការផ្តើមគំនិត ការអភិវឌ្ឍ និងការអនុវត្តគម្រោងប្រសិទ្ធភាពថាមពល។

គ. អនុវត្តក្របខណ្ឌត្រួតពិនិត្យ និងវាយតម្លៃនៃការអនុវត្តគោលនយោបាយ ដូចមានចែងក្នុងផ្នែកទី៨។

ឃ. ដើរតួជាអ្នកសម្របសម្រួល នៅកម្រិតថ្នាក់ជាតិ សម្រាប់ការងារជំនួយបច្ចេកទេសទាំងអស់ដែលគាំទ្រដោយទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ ទាក់ទងនឹងការងារប្រសិទ្ធភាពថាមពល។

**២. ការកំណត់បទដ្ឋាន និងបទប្បញ្ញត្តិបច្ចេកទេស**

ក. ធ្វើការជាមួយស្ថាប័នដៃគូដើម្បីកំណត់អត្តសញ្ញាណ"អ្នកប្រើប្រាស់ថាមពលមុខសញ្ញា"ដោយផ្អែកលើកម្រិតការប្រើប្រាស់ថាមពលដែលបានកំណត់យកនៅក្នុងវិស័យប្រើប្រាស់ចុងក្រោយ ដូចមានចែងក្នុងផ្នែកទី៦។

ខ. ធ្វើការជាមួយស្ថាប័នដៃគូដើម្បីបង្កើតបទដ្ឋានគុណផលការប្រើប្រាស់ថាមពល រួមទាំងរៀបចំការធ្វើតេស្ត សម្រាប់វិស័យ អនុវិស័យ បរិក្ខារ និងឧបករណ៍ប្រើប្រាស់ នៃអ្នកប្រើប្រាស់ថាមពលចុងក្រោយ តាមរយៈដំណើរការពិគ្រោះយោបល់ដូចមានចែងក្នុងផ្នែកទី៦។

គ. ធ្វើការជាមួយស្ថាប័នដៃគូដើម្បីបង្កើត វិធីសាស្ត្រ មធ្យោបាយ និងនីតិវិធី សម្រាប់ត្រួតពិនិត្យភាពអនុលោមតាមបទដ្ឋានទាំងនេះ។

**៣. ការអភិវឌ្ឍនិងការផ្សព្វផ្សាយចំណេះដឹង**

ក. ធ្វើយុទ្ធនាការទូទាំងប្រទេស ពង្រឹងការយល់ដឹងជាសាធារណៈអំពីអត្ថប្រយោជន៍នៃប្រសិទ្ធភាព ថាមពលតាមរយៈពហុឧបករណ៍ទំនាក់ទំនង ដោយសហការជាមួយស្ថាប័នដៃគូ ក្រសួងមហាផ្ទៃ ក្រសួងព័ត៌មាន និងក្រសួងអប់រំ យុវជន និងកីឡា។

ខ. លើកកម្ពស់ការស្រាវជ្រាវនិងការអភិវឌ្ឍ និងការបង្កើតគម្រោងសាកល្បង សម្រាប់បច្ចេកវិទ្យា ប្រសិទ្ធភាពថាមពលថ្មីៗ និងកំពុងរីកចម្រើន ដោយសហការជាមួយស្ថាប័នដៃគូ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នអភិវឌ្ឍន៍អន្តរជាតិ និងវិស័យសិក្សាធិការ។

គ. បង្កើតឃ្លាំងចំណេះដឹងពាក់ព័ន្ធនឹងប្រសិទ្ធភាពថាមពល ក្នុងទម្រង់ជាគេហទំព័របើកចំហដែលជា ប្រភពផ្តល់ចំណេះដឹង ទិន្នន័យព័ត៌មានប្រភេទផ្សេងៗដូចជាឯកសារគោលនយោបាយ និង បទប្បញ្ញត្តិប្រសិទ្ធភាពថាមពលនានា ផែនការសកម្មភាពប្រសិទ្ធភាពថាមពលតាមវិស័យ ទិន្នន័យ ស្ថិតិថាមពល ព្រឹត្តិបត្រសិក្សាប្រសិទ្ធភាពថាមពល។ល។

ឃ. គាំទ្រ និងសម្របសម្រួលការផ្ទេរបច្ចេកវិទ្យា ប្រសិទ្ធភាពថាមពលនៅក្នុងវិស័យឧស្សាហកម្ម។

ង. សហការជាមួយស្ថាប័នបង្គោល រៀបចំលិខិតបទដ្ឋានបច្ចេកទេស និងស្តង់ដារបច្ចេកទេស សម្រាប់ការអនុវត្តការងារប្រសិទ្ធភាពថាមពល ក្នុងវិស័យឧស្សាហកម្ម។

**៤.ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ**

ក្រសួងរ៉ែ និងថាមពល ត្រូវបង្កើត "**ក្របខណ្ឌវាស់វែងគុណផល**"មួយ ដើម្បីពិនិត្យឡើងវិញនូវ ប្រសិទ្ធភាពនិងផលប៉ះពាល់ឬឥទ្ធិពល នៃគោលនយោបាយនេះ និងផែនការសកម្មភាពប្រសិទ្ធភាពថាមពល តាមវិស័យ មួយឆ្នាំម្តង ដោយសហការជាមួយស្ថាប័នដៃគូតាមវិស័យ ដោយផ្អែកលើក្របខណ្ឌធ្វើរបាយការណ៍ ជាតិសម្រាប់ការតាមដាននិងវាយតម្លៃដែលកំណត់នៅក្នុងផ្នែកទី៨។ លទ្ធផលនៃការពិនិត្យឡើងវិញនេះ នឹង ត្រូវដាក់បញ្ចូលនៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងរ៉ែ និងថាមពល ដើម្បីបង្កើននូវតម្លាភាព និងបង្កើននូវការ យល់ដឹងអំពីប្រសិទ្ធភាពថាមពល។

## ៧.៣. តួនាទីនិងការទទួលខុសត្រូវរបស់ស្ថាប័នដៃគូ

ការទទួលខុសត្រូវសំខាន់របស់ស្ថាប័នដៃគូនៅក្នុងវិសាលភាពនៃគោលនយោបាយនេះ គឺដើម្បីជួយសម្រួល ដល់ការបង្កើតបរិយាកាសអំណោយផលសម្រាប់ការអភិវឌ្ឍការងារប្រសិទ្ធភាពថាមពលនៅកម្ពុជា។ តួនាទីនិង ការទទួលខុសត្រូវរបស់ស្ថាប័នដៃគូទាំងអស់រួមមាន៖

១. ផ្ដល់នូវការពិចារណាដោយយកចិត្តទុកដាក់ទៅលើការងារប្រសិទ្ធភាពថាមពលនៅពេលរៀបចំ គោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីវិនិយោគក្នុងវិស័យរបស់ខ្លួន។

២. ប្រមូលទិន្នន័យប្រសិទ្ធភាពថាមពលសម្រាប់កំណត់សូចនាករដោយឡែកចំពោះផ្នែកទទួលខុសត្រូវរបស់ខ្លួន និងរាយការណ៍ទៅស្ថាប័នបង្គោលដើម្បីតាមដាននិងវាយតម្លៃ។

៣.បញ្ចូលគោលការណ៍ "លទ្ធកម្មបៃតង" ទៅក្នុងដំណើរការលទ្ធកម្មសាធារណៈ។

មុខងារតាមដាននិងវាយតម្លៃរបស់ស្ថាប័នដៃគូ (ក.ឧ.វ.ប.ន., ក.ដ.ន.ស. និង ក.ស.ដ. ) រួមមានដូចខាងក្រោម៖

១. គាំទ្រការអនុវត្តក្របខណ្ឌគ្រប់គ្រងគុណផលអនុវត្តន៍គោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ដូចមានចែងលម្អិតក្នុងផ្នែកទី៨ តាមរយៈការផ្ដល់ទិន្នន័យពាក់ព័ន្ធនឹងសូចនាករគុណផលគន្លឹះនានា។

២. គាំទ្រការអនុវត្តការតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល  ដូចមានចែងលម្អិតក្នុងផ្នែកទី៨ តាមរយៈការផ្ដល់របាយការណ៍ប្រចាំឆ្នាំស្តីពីគុណផលនៃការអនុវត្តកម្មវិធី ឬសកម្មភាពពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយនេះ។

តួនាទី និងការទទួលខុសត្រូវជាក់លាក់របស់ក្រសួង ស្ថាប័នដៃគូនីមួយៗ នឹងមានជូននៅផ្នែកបន្ទាប់។

## ៧.៣.១. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

តួនាទី  និងការទទួលខុសត្រូវរបស់  ក.ស.ហ.វ.  នៅក្នុងវិសាលភាពនៃគោលនយោបាយនេះ  មានដូចខាងក្រោម៖

១. ក្នុងនាមជាដៃគូអនុវត្ត ផ្ដល់យោបល់ដល់ស្ថាប័នបង្គោលអំពីបញ្ហាទាក់ទងនឹងការធ្វើផែនការ និងរៀបចំថវិកានៃកម្មវិធីប្រសិទ្ធភាពថាមពល។

២. ពិគ្រោះយោបល់ជាមួយស្ថាប័នបង្គោល និងស្ថាប័នដៃគូ រៀបចំរចនាឧបករណ៍ហិរញ្ញវត្ថុ និងសារពើពន្ធដើម្បីលើកទឹកចិត្តដល់ការទទួលយកការងារប្រសិទ្ធភាពថាមពល។

៣. ផ្ដល់យោបល់ និង ធ្វើការជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីកំណត់យន្តការសមស្របសម្រាប់ការអនុវត្តក្នុងវិស័យធនាគារ សំដៅជំរុញការផ្ដល់ឥណទានបៃតង ដែលគាំទ្រដល់គម្រោងប្រសិទ្ធភាពថាមពល។ ជាងនេះទៅទៀត ក.ស.ហ.វ. ក៏អាចប្រើប្រាស់យន្តការធនាគារសហគ្រាសធុនតូច និង

មធ្យមកម្ពុជា ម.ក និងសាជីវកម្មធានាឥណទានកម្ពុជា ដើម្បីជំរុញ ផ្តល់ និងធានាឥណទានបៃតងនៃគម្រោងប្រសិទ្ធភាពថាមពលផងដែរ។

៤. ដើរតួនាទីឈានមុខគេក្នុងការបង្កើតសេចក្តីណែនាំ និងនីតិវិធីសម្រាប់ការធ្វើឱ្យ "កាន់តែបៃតង"នូវប្រព័ន្ធលទ្ធកម្មសាធារណៈដោយដាក់បញ្ចូលបទប្បញ្ញត្តិសម្រាប់លើកទឹកចិត្តដល់ឧបករណ៍ដែលមានប្រសិទ្ធភាពថាមពលកាន់តែខ្ពស់។

៥. សហការផ្តល់ទិន្នន័យស្ថិតិនាំចូលនូវឧបករណ៍ គ្រឿងបរិក្ខារអគ្គិសនី ជូនស្ថាប័នកំពូល ដើម្បីប្រើប្រាស់ជាមូលដ្ឋាន ដើម្បីពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពថាមពល។ ទម្រង់និងទិន្នន័យស្ថិតិនាំចូល នឹងត្រូវកំណត់នៅក្នុងបទប្បញ្ញត្តិដាច់ដោយឡែក។

ដោយឡែក តួនាទី និងការទទួលខុសត្រូវរបស់ ក.ស.ហ.វ. ចំពោះការតាមដាន និងវាយតម្លៃ រួមមានដូចខាងក្រោម៖

១. យកលទ្ធផលតាមដាន និងវាយតម្លៃគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល (សូចនាករ និងគោលដៅ) មករៀបចំផែនការថវិកា។

២. ដាក់បញ្ចូលលទ្ធផលនៃផែនការតាមដាន និងផែនការវាយតម្លៃគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពលប្រចាំឆ្នាំ ទៅក្នុងការវាយតម្លៃលើការផ្តល់ជូនថវិកា។

### ៧.៣.២. ក្រសួងឧស្សាហកម្ម បច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍

ក្នុងនាមជាស្ថាប័នដៃគូទទួលខុសត្រូវចំពោះការសម្រេចគោលដៅប្រសិទ្ធភាពថាមពលក្នុងវិស័យឧស្សាហកម្មនៃគោលនយោបាយនេះ តួនាទីនិងការទទួលខុសត្រូវរបស់ ក.ឧ.ប.វ.ន. មានដូចខាងក្រោម៖

១. ផ្តល់ការណែនាំ ទិន្នន័យ និងធនធានចាំបាច់ដល់មន្ត្រីក្រុមការងារបង្គោលរបស់ខ្លួន ដើម្បីរៀបចំផែនការសកម្មភាពប្រសិទ្ធភាពថាមពលសម្រាប់វិស័យឧស្សាហកម្មឱ្យស្របតាមគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០។

២. សហការជាមួយស្ថាប័នបង្គោល រៀបចំកំណត់កម្រិតប្រើប្រាស់ថាមពលអប្បបរមា និងកំណត់ "អ្នកប្រើប្រាស់ថាមពលមុខសញ្ញា" សម្រាប់វិស័យឧស្សាហកម្ម។

៣. សហការជាមួយស្ថាប័នបង្គោល បង្កើតយន្តការសម្រាប់ធ្វើសវនកម្មថាមពលជាទៀងទាត់លើ "អ្នកប្រើប្រាស់ថាមពលមុខសញ្ញា" នៅក្នុងវិស័យឧស្សាហកម្ម។

៤. ផ្តួចផ្តើមរៀបចំសំណើគម្រោងប្រសិទ្ធភាពថាមពលក្នុងវិស័យឧស្សាហកម្ម។

៥. តាមរយៈវិទ្យាស្ថានស្តង់ដារកម្ពុជា កំណត់អត្តសញ្ញាណឧបករណ៍និងបរិក្ខារប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម ដែលត្រូវរៀបចំបង្កើតជាបទប្បញ្ញត្តិស្តីពីបទដ្ឋាន និងការបិទស្លាកសញ្ញា និងរៀបចំធ្វើតេស្តឧបករណ៍ និងបរិក្ខារសម្រាប់ការទទួលបានការបិទស្លាកសញ្ញា។

### ៧.៣.៣. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

ក្នុងនាមជាស្ថាប័នដៃគូទទួលខុសត្រូវចំពោះការសម្រេចគោលដៅប្រសិទ្ធភាពថាមពលក្នុងវិស័យអគារនៃគោលនយោបាយនេះ តួនាទីនិងការទទួលខុសត្រូវរបស់ ក.ដ.ន.ស. មានដូចខាងក្រោម៖

១. សហការជាមួយស្ថាប័នបង្គោល ដើម្បីកំណត់ "អ្នកប្រើប្រាស់ថាមពលមុខសញ្ញា" សម្រាប់វិស័យអគារ។

២. សហការជាមួយស្ថាប័នបង្គោល បង្កើតយន្តការសម្រាប់ធ្វើសវនកម្មជាទៀងទាត់លើការប្រើប្រាស់ថាមពលរបស់ "អ្នកប្រើប្រាស់ថាមពលមុខសញ្ញា" ក្នុងវិស័យអគារ។

៣. ដោយសហការជាមួយស្ថាប័នបង្គោល ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងវិទ្យាស្ថានស្តង់ដារកម្ពុជា រៀបចំបង្កើតវិធានថាមពលសម្រាប់អគារនៅកម្ពុជា សម្រាប់ការងាររៀបចំគ្រប់គ្រងការសាងសង់អគារថ្មី និងការគ្រប់គ្រងអគារថ្មី និងការជួសជុល ឬ ការកែសណ្ឋានអគារដែលមានស្រាប់ និងរៀបចំប្រព័ន្ធត្រួតពិនិត្យនិងពង្រឹងការអនុវត្ត។ វិធានថាមពលសម្រាប់អគារនេះ ត្រូវមានសង្គតិភាពជាមួយនឹង "ច្បាប់ស្តីពីសំណង់"។

៤. កំណត់អត្តសញ្ញាណ និងអភិវឌ្ឍកាលានុវត្តភាពគម្រោង ដោយផ្តោតលើសក្តានុពលនៃការធ្វើឱ្យសម្រេចបានការចំណេញពីប្រសិទ្ធភាពថាមពល ទាំងក្នុងផ្នែកសាងសង់អគារ ផ្នែកកែលម្អអគារ និងទាំងក្នុងផ្នែករៀបចំផែនការនគរូបនីយកម្មរាជធានីទីក្រុង និងទីប្រជុំជន។

### ៧.៣.៤. ក្រសួងសាធារណការ និងដឹកជញ្ជូន

ក្នុងនាមជាស្ថាប័នដៃគូ ទទួលខុសត្រូវចំពោះការសម្រេចគោលដៅប្រសិទ្ធភាពថាមពលក្នុងវិស័យដឹកជញ្ជូន និងសេវាសាធារណៈ តួនាទី និងការទទួលខុសត្រូវរបស់ ក.ស.ដ. មានដូចខាងក្រោម៖

១. សហការជាមួយស្ថាប័នបង្គោល បង្កើតយន្តការសម្រាប់ធ្វើសវនកម្មជាប្រចាំលើការប្រើប្រាស់ថាមពលរបស់អ្នកប្រើប្រាស់ថាមពលនៅក្នុងវិស័យសេវាសាធារណៈ។

២. កំណត់អត្តសញ្ញាណ និងអភិវឌ្ឍគម្រោងប្រសិទ្ធភាពថាមពលក្នុងវិស័យសេវាសាធារណៈនិងដឹកជញ្ជូន។
៣. សហការជាមួយស្ថាប័នបង្គោល ដើម្បីកំណត់តំបន់ឬទីតាំងដំឡើងស្ថានីយបញ្ចូលថាមពលសម្រាប់យានជំនិះប្រើប្រាស់ថាមពលអគ្គិសនី។

### ៧.៣.៥. ក្រសួងបរិស្ថាន

ក្នុងនាមជាស្ថាប័នដៃគូក្នុងការងារប្រសិទ្ធភាពថាមពល ក្នុងក្របខណ្ឌគោលនយោបាយនេះ ក្រសួងបរិស្ថានមានមុខងារនិងភារកិច្ចដូចខាងក្រោម៖

១. ធ្វើការជាមួយស្ថាប័នបង្គោលនិងស្ថាប័នដៃគូដទៃទៀត ដើម្បីធានាបាននូវការបន្សុីគ្នារវាងផែនការសកម្មភាពប្រសិទ្ធភាពថាមពលតាមវិស័យ ជាមួយនឹងផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពប្រែប្រួលអាកាសធាតុនិងឯកសារពាក់ព័ន្ធ។
២. ធ្វើការជាមួយស្ថាប័នបង្គោល និងស្ថាប័នដៃគូដទៃទៀត តាមការចាំបាច់ ដើម្បីរៀបចំប្រព័ន្ធតាមដាន ធ្វើរបាយការណ៍ និងផ្ទៀងផ្ទាត់សម្រាប់ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលត្រូវគ្នានឹងប្រព័ន្ធតាមដាននិងវាយតម្លៃ ដើម្បីតាមដានវឌ្ឍនភាពស្តីពីប្រសិទ្ធភាពថាមពលដូចមានចែងក្នុងផ្នែកទី៨។
៣. សម្របសម្រួលគណនេយ្យអំពីការកាត់បន្ថយការបញ្ចេញឧស្ម័នពីគម្រោងប្រសិទ្ធភាពថាមពល ក្នុងសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ជាតិ។
៤. លើកកម្ពស់ការយល់ដឹងអំពីប្រសិទ្ធភាពថាមពល ដោយដាក់បញ្ចូលជាផ្នែកមួយនៃកម្មវិធីអប់រំបរិស្ថាននៅក្នុងប្រទេសកម្ពុជា។
៥. រាយការណ៍អំពីវឌ្ឍនភាពការងារប្រសិទ្ធភាពថាមពលនៅក្នុងប្រទេសកម្ពុជា ជូនដល់អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ជាផ្នែកមួយនៃការប្តេជ្ញាចិត្តក្នុងការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុរបស់កម្ពុជា។
៦. គាំទ្រការទទួលបានការគាំទ្រមូលនិធិពីមូលនិធិអាកាសធាតុនិងមូលនិធិបរិស្ថានអន្តរជាតិ សម្រាប់គម្រោងប្រសិទ្ធភាពថាមពល។

### ៧.៣.៦. ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

ក្នុងនាមជាស្ថាប័នដៃគូក្នុងការងារប្រសិទ្ធភាពថាមពលក្នុងក្របខណ្ឌគោលនយោបាយនេះ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) ផ្តល់ការគាំទ្រដល់ស្ថាប័នបង្គោល ក្នុងការសម្រេចបាននូវគោលបំណងអន្តរវិស័យនៃគោលនយោបាយនេះ ទាក់ទងទៅនឹងការអភិវឌ្ឍដោយចីរភាព។ ក.ជ.អ.ច.ទទួលខុសត្រូវធានាឱ្យមានការបន្សុីគ្នារវាងគោលដៅនៃគោលនយោបាយនេះ ជាមួយនឹងសកម្មភាពប្រសិទ្ធភាពថាមពលនៃការចូលរួមរបស់ជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ក.ជ.អ.ច. មានមុខងារ និងភារកិច្ចដូចខាងក្រោម៖

១. សហការជាមួយស្ថាប័នបង្គោល និងស្ថាប័នដៃគូដទៃទៀត ដើម្បីធានាភាពបន្សុីគ្នារវាងផែនការសកម្មភាពប្រសិទ្ធភាពថាមពលតាមវិស័យ និងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុពាក់ព័ន្ធ។
២. សហការជាមួយស្ថាប័នបង្គោល និងស្ថាប័នដៃគូដទៃទៀត តាមការចាំបាច់ ដើម្បីបង្កើតប្រព័ន្ធត្រួតពិនិត្យ រាយការណ៍ និងផ្ទៀងផ្ទាត់ សម្រាប់ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលស្របតាមគោលការណ៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃស្តីពីប្រសិទ្ធភាពថាមពល ដូចមានចែងក្នុងផ្នែកទី៨។
៣. លើកកម្ពស់ការយល់ដឹងអំពីប្រសិទ្ធភាពថាមពល ដោយដាក់ជាផ្នែកមួយនៃកម្មវិធីអប់រំបរិស្ថាននៅកម្ពុជា។
៤. រាយការណ៍អំពីវឌ្ឍនភាពការងារប្រសិទ្ធភាពថាមពលនៅក្នុងប្រទេសកម្ពុជា ជូនដល់អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ជាផ្នែកមួយនៃការប្តេជ្ញាចិត្តក្នុងការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុរបស់កម្ពុជា។
៥. គាំទ្រការទទួលបានការគាំទ្រមូលនិធិពីមូលនិធិអាកាសធាតុនិងមូលនិធិបរិស្ថានអន្តរជាតិសម្រាប់គម្រោងប្រសិទ្ធភាពថាមពល។

### ៧.៣.៧. អគ្គិសនីកម្ពុជា

ក្នុងនាមជាស្ថាប័នដៃគូក្នុងការងារប្រសិទ្ធភាពថាមពលក្នុងក្របខណ្ឌគោលនយោបាយនេះ អគ្គិសនីកម្ពុជាមានតួនាទី និងការទទួលខុសត្រូវដូចខាងក្រោម៖

១. ស្វែងរកកាលានុវត្តភាព និងជួយសម្រួលការអនុវត្តគំរូអាជីវកម្មថ្មីដែលផ្តោតលើសក្តានុពលប្រសិទ្ធភាពថាមពល តាមរយៈការគ្រប់គ្រងលើផ្នែកតម្រូវការថាមពល។

២. ផ្តល់ការគាំទ្រដល់ស្ថាប័នបង្គោល និងស្ថាប័នដៃគូដទៃទៀតក្នុងការកំណត់អត្តសញ្ញាណ "អ្នកប្រើប្រាស់ថាមពលមុខសញ្ញា" ដោយតាមដាននិងរាយការណ៍អំពីទិន្នន័យប្រើប្រាស់អគ្គិសនីរបស់អ្នកប្រើតាមវិស័យនៃការប្រើប្រាស់អគ្គិសនីនីមួយៗ។
៣. ស្វែងរកគំនិតបង្កើតយន្តការ និងវិធីសាស្ត្រដើម្បីលើកទឹកចិត្តអ្នកប្រើប្រាស់អគ្គិសនីឱ្យប្តូរទៅប្រើប្រាស់ឧបករណ៍ដែលកាន់តែមានប្រសិទ្ធភាពថាមពល ។
៤. ធ្វើការជាមួយសហគ្រាសអគ្គិសនីជនបទដើម្បីបង្កើតយន្តការ និងវិធីសាស្ត្រជំរុញលើកទឹកចិត្តដល់គ្រួសារនៅជនបទឱ្យផ្លាស់ប្តូរពីការប្រើឧបករណ៍គ្មានប្រសិទ្ធភាព មកប្រើឧបករណ៍ប្រើប្រាស់ដែលមានប្រសិទ្ធភាពវិញ។

## ៧.៣.៨. អាជ្ញាធរអគ្គិសនីកម្ពុជា

ក្នុងនាមជាស្ថាប័នដៃគូក្នុងការងារប្រសិទ្ធភាពថាមពលក្នុងក្របខណ្ឌគោលនយោបាយនេះ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវទទួលបន្ទុកធ្វើការជាមួយស្ថាប័នបង្គោល និងស្ថាប័នដៃគូដទៃទៀត ដើម្បីកែលម្អបរិយាកាសអំណោយផលសម្រាប់អនុវត្តវិធានការប្រសិទ្ធភាពថាមពលនៅកម្ពុជា តាមរយៈការដាក់ចេញនូវវិធានការគាំទ្រ និងការសម្របសម្រួលដំណើរការពិគ្រោះយោបល់។

## ៧.៣.៩. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ក្នុងនាមជាស្ថាប័នដៃគូក្នុងការងារប្រសិទ្ធភាពថាមពល ក្នុងក្របខណ្ឌគោលនយោបាយនេះ តួនាទីនិងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រួមមាន៖
១. លើកទឹកចិត្តការវិនិយោគគម្រោងប្រសិទ្ធភាពថាមពលតាមរយៈគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។
២. លើកកម្ពស់ និងស្វែងរកកាលានុវត្តភាពលើការងារប្រសិទ្ធភាពថាមពលជាផ្នែកមួយនៃយុទ្ធសាស្ត្រសម្រាប់ទាក់ទាញនិងជំរុញវិនិយោគដើម្បីក្លាយទៅជាគំរូនៃឧស្សាហកម្ម៤.០។
៣. លើកកម្ពស់ការប្រកួតប្រជែងក្នុងការបំពេញគុណផលការងារប្រសិទ្ធភាពថាមពលរបស់ឧស្សាហកម្មដែលមានទិសដៅនាំចេញ ជាមួយឧស្សាហកម្មក្នុងតំបន់អាស៊ាន។

### ៧.៣.១០. ក្រសួងផែនការ

ក្រសួងផែនការ មានតួនាទីគាំទ្រស្ថាប័នដៃគូក្នុងការតាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្តគោលនយោបាយនេះ ព្រមទាំងមានតួនាទី និងការទទួលខុសត្រូវដោយឡែកដូចខាងក្រោម៖

១. គាំទ្រស្ថាប័នបង្គោល ដើម្បីធានាឱ្យបានថាការតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយនេះ ធ្វើឡើងស្របតាមគោលការណ៍ណែនាំរបស់ក្រសួងផែនការ

២. គាំទ្រស្ថាប័នបង្គោល និងស្ថាប័នដៃគូក្នុងការរៀបចំឯកសារគាំទ្រ និងក្របខណ្ឌពាក់ព័ន្ធនឹងក្របខណ្ឌគ្រប់គ្រងគុណផល ព្រមទាំងការងារតាមដាន និងវាយតម្លៃគោលនយោបាយនេះ ដូចមានចែងក្នុងផ្នែកទី៨។

៣. គាំទ្រស្ថាប័នបង្គោល និងស្ថាប័នដៃគូក្នុងការបំពេញមុខងារតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពលរបស់ខ្លួន តាមរយៈការផ្តល់ការបណ្តុះបណ្តាល ការកសាងសមត្ថភាព និងការគាំទ្របច្ចេកទេស។

## ៧.៤. តួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលរាជធានីខេត្ត

នាពេលបច្ចុប្បន្ននេះ មន្ទីររបស់ក្រសួងពាក់ព័ន្ធតាមបណ្តាខេត្ត កំពុងបំពេញមុខងារសំខាន់ៗជាច្រើនដែលពាក់ព័ន្ធនឹងការរួមចំណែកជំរុញរបៀបវារៈប្រសិទ្ធភាពថាមពលនៅកម្ពុជា។ បច្ចុប្បន្នមន្ទីររបស់ក្រសួងពាក់ព័ន្ធនៅតាមរាជធានីខេត្ត បានទទួលខុសត្រូវលើបញ្ហាមួយចំនួនពាក់ព័ន្ធនឹងគោលនយោបាយនេះរួចហើយ ជាពិសេសការប្រមូល និងរាយការណ៍ទិន្នន័យសម្រាប់ការអនុវត្តគោលនយោបាយ និងផែនការថ្នាក់រាជធានីខេត្ត និងការចេញអាជ្ញាបណ្ណ និងបទប្បញ្ញត្តិមួយចំនួន។

ដោយអនុលោមតាមគោលការណ៍វិមជ្ឈការការទទួលខុសត្រូវ ក្នុងក្របខណ្ឌយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ គោលនយោបាយនេះកំណត់ការទទួលខុសត្រូវបន្ថែមលើការងារប្រសិទ្ធភាពថាមពលដល់រដ្ឋបាលរាជធានីខេត្ត ដោយរៀបចំធ្វើឱ្យមានលក្ខណៈជាផ្លូវការតាមរយៈឧបករណ៍ផ្លូវច្បាប់សមស្រប ដូចខាងក្រោម៖

១. តែងតាំងយ៉ាងហោចណាស់ការិយាល័យបង្គោលមួយ ដើម្បីសម្របសម្រួលសកម្មភាពប្រសិទ្ធភាពថាមពលនៅថ្នាក់ខេត្ត។

២. បង្កើតនិងអភិវឌ្ឍគម្រោងប្រសិទ្ធភាពថាមពល។

៣. អនុម័តគម្រោងវិនិយោគលើប្រសិទ្ធភាពថាមពល តាមកម្រិតថវិកាដែលកំណត់ដោយ ក.ស.ហ.វ.។

នៅថ្នាក់រាជធានីខេត្ត ត្រូវបង្កើតការិយាល័យបង្គោលសម្រាប់ការងារប្រសិទ្ធភាពថាមពលដើម្បីគាំទ្រដល់ការសម្រេចនូវចក្ខុវិស័យ និងគោលបំណងនៃគោលនយោបាយនេះ។ តួនាទី និងការទទួលខុសត្រូវរបស់ការិយាល័យបង្គោលនេះ មានដូចខាងក្រោម៖

១. កសាងសមត្ថភាពរបស់មន្ទីរតាមខេត្តនៃ"ស្ថាប័នដៃគូ"ទាក់ទងនឹងប្រសិទ្ធភាពថាមពលលើវិស័យ អគារ ឧស្សាហកម្ម សេវាសាធារណៈ និងដឹកជញ្ជូន។

២. បំពេញមុខងារក្នុងនាមរដ្ឋបាលខេត្ត ជាមួយស្ថាប័នរាជរដ្ឋាភិបាល និងវិស័យឯកជនដទៃទៀត លើបញ្ហាដែលទាក់ទងនឹងការកំណត់ខាងលើការរៀបចំ និងការអនុវត្តគម្រោងប្រសិទ្ធភាពថាមពល។

ដោយសារតួនាទីរបស់ក្រសួងរ៉ែ និងថាមពល ជាស្ថាប័នបង្គោលនៃគោលនយោបាយនេះ ដូច្នេះកំណត់តួនាទី និងការទទួលខុសត្រូវរបស់មន្ទីររ៉ែ និងថាមពល តាមបណ្តារាជធានី ខេត្ត ដូចខាងក្រោម៖

១. អនុវត្តគម្រោងប្រសិទ្ធភាពថាមពលដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

២. សហការជាមួយមន្ទីរនៃស្ថាប័នដៃគូ សម្រាប់ការតាមដានទិន្នន័យការប្រើប្រាស់ថាមពលនៅតាមវិស័យនានា នៅក្នុងរាជធានីខេត្ត។

៣. សហការជាមួយស្ថាប័នដៃគូនៅថ្នាក់រាជធានីខេត្ត និងអគ្គិសនីកម្ពុជា ដើម្បីកំណត់"អ្នកប្រើប្រាស់ថាមពលមុខសញ្ញា"។

៤. ត្រួតពិនិត្យការប្រើប្រាស់ថាមពលប្រចាំឆ្នាំរបស់ "អ្នកប្រើប្រាស់ថាមពលមុខសញ្ញា" ដើម្បីធានាភាពអនុលោមតាមបទដ្ឋានគុណផលការប្រើប្រាស់ថាមពលដែលបានបង្កើតឡើង។

៥. ដោយសហការជាមួយមន្ទីរដទៃទៀត ប្រមូលទិន្នន័យពាក់ព័ន្ធដើម្បីរាយការណ៍ទៅស្ថាប័នបង្គោលសម្រាប់ការរៀបចំស្ថិតិថាមពលថ្នាក់ជាតិ។

៦. ជួយគាំទ្រដល់មន្ទីរដែលជាសេនាធិការរបស់ស្ថាប័នដៃគូក្នុងការផ្តល់វគ្គបណ្តុះបណ្តាលស្តីពីប្រសិទ្ធភាពថាមពល។

៧. លើកទឹកចិត្តអ្នកប្រើប្រាស់ថាមពលឱ្យចេះសន្សំសំចៃថាមពលដោយរៀបចំយុទ្ធនាការ និងសិក្ខាសាលាពង្រឹងនិងពង្រីកការយល់ដឹងនៅថ្នាក់រាជធានីខេត្ត។

## ៧.៥. ក្របខណ្ឌគតិយុត្តិ រដ្ឋបាល និងហិរញ្ញវត្ថុ

ដើម្បីឈានទៅសម្រេចគោលបំណងកំណត់ដោយគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ទាមទារឱ្យរាជរដ្ឋាភិបាលត្រូវដោះស្រាយបញ្ហាមួយចំនួនដែលមិនមែនជាបញ្ហាថាមពល ដូចជាការដោះស្រាយរបាំងទីផ្សារ

ការធ្វើវិភាជចំណាយរបស់រាជរដ្ឋាភិបាលមកឱ្យការងារប្រសិទ្ធភាពថាមពល គាំទ្រការអភិវឌ្ឍប្រកបដោយសមធម៌ និងយុត្តិធម៌ និងដាក់ចេញបញ្ញត្តិគាំទ្រដល់ក្រុមងាយរងគ្រោះ។ សម្រាប់គោលបំណងនេះ ស្ថាប័នបង្គោលត្រូវមានអំណាចក្នុងការប្រើឧបករណ៍ដូចខាងក្រោម ក្នុងការអនុវត្តការទទួលខុសត្រូវរបស់ខ្លួន។

### ៧.៥.១. ការពង្រឹងក្របខណ្ឌគតិយុត្ត

ក្នុងការអនុវត្តការទទួលខុសត្រូវរបស់ខ្លួនក្នុងក្របខណ្ឌគោលនយោបាយនេះ ស្ថាប័នបង្គោល និង ស្ថាប័នដៃគូមានសិទ្ធិចេញនូវលិខិតបទដ្ឋានគតិយុត្តមួយចំនួន ដើម្បីជួយសម្រេចគោលបំណងរបស់គោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០ ដូចជា៖

១. ប្រកាស។

២. បទបញ្ជា ឬសេចក្តីសម្រេច។

៣. សារាចរ ឬសេចក្តីណែនាំ។

### ៧.៥.២. ក្របខណ្ឌរដ្ឋបាល

ស្ថាប័នបង្គោលអាចប្រើយន្តការរដ្ឋបាល ដើម្បីបង្កើតប្រព័ន្ធអភិបាលកិច្ចក្នុងការអនុវត្តគោលនយោបាយនេះ។ យន្តការរដ្ឋបាលនេះ អាចដាក់ឱ្យដំណើរការតាមរយៈប្រកាស ឬសេចក្តីសម្រេចដែលក្នុងនោះ អាចមាន៖

១. **ការបង្កើត*គណៈកម្មាធិការជំនាញប្រសិទ្ធភាពថាមពល*៖** ស្ថាប័នបង្គោលមានសិទ្ធិចេញប្រកាស ឬសេចក្តីសម្រេចបង្កើតគណៈកម្មាធិការជំនាញ ដើម្បីគ្រប់គ្រងការងារប្រសិទ្ធភាពថាមពលណាដែលចាត់ទុកថាមានសារៈសំខាន់ ដោយផ្ទេរសិទ្ធិអំណាចរបស់ខ្លួនចែងក្នុងគោលនយោបាយនេះទៅឱ្យគណៈកម្មាធិការជំនាញនោះគ្រប់គ្រង។ ស្ថាប័នបង្គោល មានសិទ្ធិកំណត់ថាការងារប្រសិទ្ធភាពថាមពលណាជាការងារដែលមានសារៈសំខាន់។ សិទ្ធិអំណាច សមាសភាព គុណវុឌ្ឍិរបស់សមាជិកនិងប្រធាន របៀបដំណើរការ នីតិវិធី និងកម្មវិធីប្រជុំរបស់គណៈកម្មាធិការត្រូវមានចែងលម្អិតនៅក្នុងប្រកាស ឬសេចក្តីសម្រេច។

២. **ការបង្កើតយន្តការផ្តល់រង្វាន់ ឬពិន័យ៖** តាមរយៈប្រកាស ឬសេចក្តីសម្រេចរបស់ខ្លួន ស្ថាប័នបង្គោលអាចដាក់ចេញនូវយន្តការផ្តល់រង្វាន់ ឬពិន័យដល់បុគ្គលឬអង្គភាពនៅក្នុងវិស័យប្រើប្រាស់ថាមពលចុងក្រោយសម្រាប់ភាពអនុលោម ឬភាពមិនអនុលោមតាមបញ្ញត្តិនៃគោលនយោបាយនេះ។ នីតិវិធីសម្រាប់គ្រប់គ្រងការផ្តល់រង្វាន់ឬពិន័យ ទំហំនៃការផ្តល់រង្វាន់និងពិន័យ និងនីតិវិធីនៃបណ្តឹងសាទុក្ខជំទាស់ទៅនឹងការផាកពិន័យត្រូវចែងលម្អិតក្នុងប្រកាស ឬសេចក្តីសម្រេចនោះ។

៣. **ការលើកលែងបទប្បញ្ញត្តិ៖** ស្ថាប័នបង្គោលអាចដាក់ចេញការលើកលែងបទប្បញ្ញត្តិ ដើម្បីអនុញ្ញាតឱ្យអ្នកច្នៃប្រតិដ្ឋអាចសាកល្បងផលិតផល សេវាកម្ម និងគំរូអាជីវកម្មថ្មី ដោយមិនចាំបាច់អនុវត្តបទប្បញ្ញត្តិមួយចំនួន។ សម្រាប់គោលបំណងនេះ ស្ថាប័នបង្គោលអាចបើកឱ្យមានការផ្តល់គំនិតទាក់ទងនឹងប្រសិទ្ធភាពថាមពល ពីអ្នកច្នៃប្រតិដ្ឋក្នុងទម្រង់ជាសំណើ។ ការសាកល្បងនេះ អាចធ្វើឡើងក្នុងរយៈពេលមួយកំណត់ និងក្នុងទំហំមួយតូចដែលមានគោលបំណងសិក្សាឱ្យបានច្បាស់លាស់ក្នុងការសាកល្បងភាពស្ថិតស្ថេរនៃគំរូនោះ។

៤. **លទ្ធកម្មសាធារណៈ៖** ដោយមានការព្រមព្រៀងពី ក.ស.ហ.វ. ស្ថាប័នបង្គោលអាចចេញបទបញ្ជាដើម្បីផ្តល់អាណត្តិការងារជាក់លាក់សម្រាប់ការធ្វើលទ្ធកម្មសាធារណៈបែតងគ្របដណ្តប់លើវិស័យប្រើប្រាស់ថាមពលចុងក្រោយដោយផ្នែក ឬដោយពេញលេញ។ ផលប៉ះពាល់នៃអាណត្តិការងារនេះទៅលើការប្រកួតប្រជែងថ្លៃ ប្រតិបត្តិការរបស់រាជរដ្ឋាភិបាល និងនវានុវត្តន៍ត្រូវលើកយកមកពិចារណាឱ្យបានត្រឹមត្រូវសម្រាប់កំណត់វិសាលភាពនៃអាណត្តិការងារនេះ។

៥. **ការតែងតាំងជាកាតព្វកិច្ចនូវភ្នាក់ងារធ្វើការផ្ទៀងផ្ទាត់ឯករាជ លើការសន្សំសំចៃថាមពលសម្រាប់កិច្ចសន្យាអនុវត្តនៃការផ្តល់សេវាថាមពល៖** សម្រាប់ *"កិច្ចសន្យាអនុវត្តនៃការផ្តល់សេវាថាមពល" (ក.អ.ស.ថ.)*ដែលការអនុវត្តកិច្ចសន្យាជាក់ស្តែងនោះ ធ្វើឱ្យការចំណាយលើសកម្រិតចំនួនថវិកាដែលបានកំណត់ដោយស្ថាប័នបង្គោលជាបន្តបន្ទាប់ ស្ថាប័នបង្គោលអាចដាក់កំហិតឱ្យភាគីក្នុងកិច្ចសន្យាតែងតាំងភ្នាក់ងារផ្ទៀងផ្ទាត់ឯករាជ្យដើម្បីផ្ទៀងផ្ទាត់លទ្ធផលនៃការសន្សំសំចៃថាមពល និងថ្លៃចំណាយ។ ស្ថាប័នបង្គោលត្រូវបង្កើតបញ្ជីសម្រាំងឈ្មោះភ្នាក់ងារផ្ទៀងផ្ទាត់ឯករាជមួយ សម្រាប់ជាឯកសារគោលឱ្យស្ថាប័នបង្គោលយកមកប្រើក្នុងការតែងតាំងអ្នកផ្ទៀងផ្ទាត់ឯករាជ្យដើម្បីបំពេញកិច្ចផ្ទៀងផ្ទាត់ការអនុវត្តកិច្ចសន្យាខាងលើ។ ការចំណាយទៅលើការតែងតាំងភ្នាក់ងារនេះ អាចត្រូវផ្តល់ដោយភាគីកិច្ចសន្យា ឬ អាចទទួលបានបដិភាគថវិកាមួយផ្នែកដោយស្ថាប័នបង្គោល អាស្រ័យទៅតាមករណីនីមួយៗ។

### ៧.៥.៣. ឧបករណ៍ហិរញ្ញវត្ថុ

ស្ថាប័នបង្គោល និង ស្ថាប័នដៃគូ មានអំណាចប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុ ដូចខាងក្រោម ដើម្បីគាំទ្រហិរញ្ញវត្ថុសម្រាប់ការងារប្រសិទ្ធភាពថាមពល៖

១. **ការលើកទឹកចិត្តផ្នែកសារពើពន្ធ និងមិនមែនសារពើពន្ធ៖** ស្ថាប័នបង្គោល និងស្ថាប័នដៃគូ អាចស្នើសុំបង្កើតការលើកទឹកចិត្តផ្នែកសារពើពន្ធ ទៅអគ្គនាយកដ្ឋានពន្ធដារនៃ ក.ស.ហ.វ. ដើម្បីសិក្សា និងផ្តល់

យោបល់គតិយុត្តិដែលពាក់ព័ន្ធនឹងការអនុវត្តការងារប្រសិទ្ធភាពថាមពល។ ទន្ទឹមនេះ បទប្បញ្ញត្តិនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ចាប់ពីមាត្រា២៤ ដល់មាត្រ២៨ ដែលបានប្រកាសដាក់ឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ បានបញ្ជាក់ថា ការវិនិយោគក្នុងវិស័យថាមពលបៃតង និងបច្ចេកវិទ្យាបៃតង ដែលរួមចំណែកដល់ការបន្សាំ និងការកាត់បន្ថយប្រែប្រួលអាកាសធាតុ ត្រូវចាត់ទុកជាវិស័យ និងសកម្មភាពវិនិយោគត្រូវបានលើកទឹកចិត្ត ដោយរួមទាំងការលើកទឹកចិត្តផ្នែកពន្ធដារមានដូចជា ការអនុគ្រោះពន្ធលើប្រាក់ចំណូលពី៣ឆ្នាំទៅ៩ឆ្នាំ ការអនុគ្រោះអាករលើតម្លៃបន្ថែមលើការនាំចូល និងអត្រារំលស់ពិសេសជាដើម។ បន្ថែមពីលើនេះ ស្ថាប័នបង្គោល និងស្ថាប័នដៃគូ អាចស្នើសុំបង្កើតការលើកទឹកចិត្តផ្នែកសារពើពន្ធ និងមិនមែនសារពើពន្ធទៅ ក.ស.ហ.វ.។ ការលើកទឹកចិត្តផ្នែកសារពើពន្ធ និងមិនមែនសារពើពន្ធ សម្រាប់ការពិចារណាបន្ថែមរបស់រាជរដ្ឋាភិបាលរួមមាន៖

ក. គម្រោងធានាលើប្រាក់កម្ចីដែលបានផ្តល់ជូនតាមរយៈស្ថាប័នហិរញ្ញវត្ថុដោយឡែក។

ខ. ការកាត់បន្ថយពន្ធ ឬការលើកលែងពន្ធបន្ថែមសម្រាប់ឧបករណ៍ និងបរិក្ខារប្រសិទ្ធភាពថាមពល ឬសម្រាប់ធុរកិច្ចដែលមានលក្ខណៈជាការអភិវឌ្ឍដោយចីរភាព។

គ. ការបង្កើតឧបករណ៍ថ្លៃកាបូន (ឧ. ពន្ធកាបូន ឬការអនុញ្ញាតឱ្យធ្វើពាណិជ្ជកម្មលើ ការបញ្ចេញឧស្ម័ន)។

ឃ.ការយកថ្លៃឈ្នួល ឬការយកពន្ធដើម្បីផ្តល់ហិរញ្ញវត្ថុដល់សកម្មភាពបន្ថែមរបស់រាជរដ្ឋាភិបាលក្នុងការការពារបរិស្ថាន។

ង. ការផ្តល់ឥណទានបៃតង ក្រោមគម្រោងប្រសិទ្ធភាពថាមពល ពីស្ថាប័នហិរញ្ញវត្ថុ។

២. **មូលនិធិសម្រាប់ប្រសិទ្ធភាពថាមពល៖** ស្ថាប័នបង្គោល និងស្ថាប័នដៃគូអាចបង្កើតមូលនិធិ ដើម្បីប្រមូលហិរញ្ញវត្ថុពីប្រភពផ្សេងៗសម្រាប់ការវិនិយោគលើប្រសិទ្ធភាពថាមពលដែលដឹកនាំដោយរាជរដ្ឋាភិបាល។ រចនាសម្ព័ន្ធនៃមូលនិធិ (ឧទាហរណ៍ មូលនិធិទុនបង្វិលសាធារណៈ) ទម្រង់ហិរញ្ញប្បទាន (ឧទាហរណ៍ បំណុល ទ្រព្យបំណុល លិខិតធានា។ល។)អ្នកមានសិទ្ធិទទួលបានមូលនិធិ (ឧទាហរណ៍ស្ថាប័នសាធារណៈ ស្ថាប័នឯកជន ក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល។ល។) ត្រូវកំណត់ដោយស្ថាប័នបង្គោល និងស្ថាប័នដៃគូ ជាផ្នែកមួយនៃលិខិតបទដ្ឋានគតិយុត្តដោយឡែក។ យោងតាមយុទ្ធសាស្ត្រគៀរគរចំណូលរាជរដ្ឋាភិបាលកម្ពុជា ពុំមានគម្រោងបង្កើតប្រភេទពន្ធថ្មីនោះឡើយ ដោយរួមទាំងការយកពន្ធលើការ

បំពុលបរិស្ថាន ការបង្កើតឧបករណ៍ថ្លៃកាបូន (ឧ.ពន្ធកាបូន ឬការអនុញ្ញាតឱ្យធ្វើពាណិជ្ជកម្មលើការបញ្ចេញឧស្ម័ន ឬការដាក់បន្ទុកពន្ធបន្ថែមដល់សហគ្រាសដែលមានផលប៉ះពាល់ដល់បរិស្ថានផងដែរ)។

៣. **ឧបករណ៍ហិរញ្ញវត្ថុច្នៃប្រតិដ្ឋផ្សេងទៀត៖** ស្ថាប័នបង្គោល និងស្ថាប័នដៃគូអាចពិចារណាប្រើប្រាស់ ឬស្វែងរកឧបករណ៍ហិរញ្ញប្បទានច្នៃប្រតិដ្ឋជាច្រើនផ្សេងទៀត សម្រាប់គម្រោងប្រសិទ្ធភាពថាមពល។ ឧបករណ៍ទាំងនេះ រួមបញ្ចូលឧបករណ៍ដូចខាងក្រោម៖

ក. **ឧបករណ៍ហិរញ្ញវត្ថុកាបូន៖** អាចជួយប្រមូលធនធានហិរញ្ញវត្ថុដើម្បីផ្តល់ហិរញ្ញប្បទានដល់គម្រោង ឬកម្មវិធីដែលនាំឱ្យមានការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលអាចវាស់វែងបាន។ គម្រោងប្រសិទ្ធភាពថាមពល អាចមានសិទ្ធិទទួលបានឱកាសហិរញ្ញវត្ថុកាបូនទាំងតាមរយៈឧបករណ៍ដែលមានស្រាប់ (ឧទាហរណ៍យន្តការឥណទានរួម ឬបទដ្ឋានស្ម័គ្រចិត្ត) និងគំរូថ្មីដូចមានចែងក្នុងបរិបទមាត្រា៦ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស។

ខ. **សញ្ញាបណ្ណបៃតង៖** ជាប្រភេទនៃបណ្ណមូលបត្រដែលត្រូវបានប្រើដើម្បីផ្តល់ហិរញ្ញប្បទានដល់គម្រោងនានាដែលផ្តល់អត្ថប្រយោជន៍ជាវិជ្ជមានដល់បរិស្ថាន ដែលអាចរាប់បញ្ចូលទាំងគម្រោងប្រសិទ្ធភាពថាមពល។ ការចេញបណ្ណមូលបត្របៃតងបានកើនឡើងគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ នៅក្នុងបណ្តាប្រទេសសមាជិកអាស៊ានមួយចំនួន ដែលក្នុងនោះមាន ២/៣ នៃការចេញបណ្ណភាគហ៊ុននៅក្នុងតំបន់ ត្រូវបានប្រើប្រាស់ដើម្បីផ្តល់ហិរញ្ញប្បទានដល់គម្រោងប្រសិទ្ធភាពថាមពល និងថាមពលកកើតឡើងវិញ។ នេះគឺជាឧបករណ៍មួយដែលរាជរដ្ឋាភិបាលកម្ពុជាអាចពិចារណានាពេលអនាគតដើម្បីផ្តល់ហិរញ្ញប្បទានដល់គម្រោងប្រសិទ្ធភាពថាមពលក្នុងប្រទេសកម្ពុជា។

គ. **មូលនិធិអាកាសធាតុ និងថាមពលស្អាតអន្តរជាតិ៖** ហិរញ្ញប្បទានសម្រាប់គម្រោងប្រសិទ្ធភាពថាមពលអាចត្រូវបានផ្តល់ពីមូលនិធិអាកាសធាតុ និងមូលនិធិថាមពលស្អាតអន្តរជាតិ (ឧ. មូលនិធិអាកាសធាតុបៃតង) ក្នុងទម្រង់ជាដើមទុន កម្ចី ជំនួយ ឬរួមបញ្ចូលគ្នា។

ឃ. **ហិរញ្ញវត្ថុបញ្ចូលគ្នា៖** ហិរញ្ញវត្ថុបញ្ចូលគ្នា គឺជាបណ្តុំវិធីសាស្ត្រហិរញ្ញប្បទានរួមបញ្ចូលគ្នាមួយ ដែលជាទូទៅចាប់ផ្តើមពីការវិនិយោគពីអង្គភាពសាធារណៈ ឬសប្បុរសជនក្នុងអត្រាមួយដែលមានលក្ខណៈសម្បទានច្រើន បន្ទាប់មកទើបមានការវិនិយោគក្នុងអត្រាមួយដូចវិនិយោគឯកជន ឬពាណិជ្ជកម្មតាមអត្រាទីផ្សារ។ ការវិនិយោគថាមពល គឺជាលក្ខណៈទូទៅបំផុតមួយសម្រាប់ប្រតិបត្តិការហិរញ្ញវត្ថុ

ដែលបានបញ្ចូលគ្នា ហេតុដូច្នេះឱកាសសម្រាប់ការផ្តល់ហិរញ្ញប្បទានប្រសិទ្ធភាពថាមពលតាមរយៈឧបករណ៍ទាំងនេះ អាចលើកមកពិចារណាបន្ថែមទៀត នាពេលអនាគត។

ង. **ការកៀរគរហិរញ្ញវត្ថុដើម្បីជំរុញសកម្មភាពប្រសិទ្ធភាពថាមពលសម្រាប់វិស័យឯកជន៖** ស្ថាប័នបង្គោល និងស្ថាប័នដៃគូអាចកៀរគរហិរញ្ញវត្ថុផ្សេងទៀតក្រៅពីប្រភពខាងលើ ដើម្បីអនុវត្តសកម្មភាពជំរុញ និងលើកទឹកចិត្តសម្រាប់ការបញ្ចេញព័ត៌មាន ឬការធ្វើរបាយការណ៍សកម្មភាពប្រសិទ្ធភាពថាមពលដែលធ្វើដោយក្រុមហ៊ុនជាផ្នែកមួយនៃរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន។

# ៨- ការបង្កើតប្រព័ន្ធតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យ

## ៨.១. ក្របខណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយប្រសិទ្ធភាពថាមពល

ក្របខណ្ឌនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ សម្រាប់គោលនយោបាយនេះត្រូវបានបង្កើតជាយន្តការស្របតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងផែនការ ដើម្បីធ្វើឱ្យការរៀបចំ និងការអនុវត្តវិធានការគោលនយោបាយ ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។ ការតាមដាន គឺជាដំណើរការនៃការប្រមូល និងតាមពិនិត្យមើលទិន្នន័យ ដើម្បីវាយតម្លៃ ថាតើការអនុវត្តវិធានការគោលនយោបាយកំពុងដើរត្រូវទៅតាមគន្លងដែរឬទេ។ ចំណែកឯការវាយតម្លៃ សំដៅទៅលើការវិភាគទិន្នន័យដើម្បីកំណត់ដែន និងវិសាលភាព ដើម្បីឱ្យដឹងថាតើវិធានការដែលបានអនុវត្តរួចមកហើយនោះ អាចសម្រេចកម្មវត្ថុគោលនយោបាយបានដែរឬទេ។ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃតាមកាលកំណត់ នៅពេលអនុវត្តបានត្រឹមត្រូវ និងជាប់ជាប្រចាំនឹងរំពឹងថានឹងជួយកំណត់នូវចំណុចខ្វះខាតនៃវិធានការប្រសិទ្ធភាពថាមពលដែលបានអនុវត្តរួច ព្រមទាំងជួយចង្អុលបង្ហាញការណែនាំលើការផ្លាស់ប្តូរសម្រាប់យកមករៀបចំ កែលម្អវិធានការដែលត្រូវអនុវត្តបន្ត ប្រសិន បើមាន។

ស្ថាប័នបង្គោល ទទួលខុសត្រូវលើការដឹកនាំការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ លើការងារអនុវត្តគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០ ត្រូវដឹកនាំក្រុមការងារបច្ចេកទេសអន្តរក្រសួងស្តីពីប្រសិទ្ធភាពថាមពល និងស្ថាប័នបង្គោល ដើម្បីឆ្ពោះទៅសម្រេចបានគោលដៅនៃគោលនយោបាយនេះ

បាន។ ក្របខណ្ឌតាមដាន និងវាយតម្លៃរបស់គោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល មានធាតុផ្សំសំខាន់ៗចំនួនបី ដែលត្រូវបានបង្កើតឡើងដោយផ្អែកលើគោលការណ៍ណែនាំរបស់ក្រសួងផែនការ៖

១. ក្របខណ្ឌវាស់វែងគុណផលគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល។

២. គោលការណ៍តាមដានការអនុវត្តគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល។

៣. គោលការណ៍វាយតម្លៃការអនុវត្តគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល។

**ក្របខណ្ឌវាស់វែងគុណផលការអនុវត្តគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល** ផ្តល់ជូនស្ថាប័នបង្គោល នូវវិធានការច្បាស់លាស់សម្រាប់វាស់វែងការបំពេញគុណផល។ ក្របខណ្ឌនេះមានបញ្ជី "សូចនាករគុណផលគន្លឹះ" នៅកម្រិតកម្មវិធី ដើម្បីវាយតម្លៃវឌ្ឍនភាពការអនុវត្តគោលនយោបាយនេះ ហើយខ្លឹមសារលម្អិតមានចែងក្នុងផ្នែកទី៨នេះ។

វិធាននៃការតាមដានការអនុវត្តគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០ មានមុខងារជាក់លាក់ចំនួនបី៖

១. ការរៀបចំសៀវភៅណែនាំស្តីពីការតាមដាន ដែលក្នុងសៀវភៅនោះមានបញ្ជាក់ច្បាស់អំពីសូចនាករសម្រាប់វាស់គោលដៅ និងអំពីភាគីពាក់ព័ន្ធក្នុងការងារប្រមូលទិន្នន័យ និងរៀបចំរបាយការណ៍។

២. ផែនការតាមដាន និងថវិកាសម្រាប់អនុវត្តសកម្មភាពគោលនយោបាយនេះ នឹងមានបញ្ជាក់ស្ថាប័នដៃគូដែលទទួលខុសត្រូវ លក្ខខណ្ឌតម្រូវសម្រាប់ការកសាងសមត្ថភាព និងធនធានហិរញ្ញវត្ថុសម្រាប់សកម្មភាពតាមដាន។

៣. សន្លឹកកិច្ចការជាឯកសារយោងអំពីសូចនាករគុណផល សម្រាប់ចងក្រងសូចនាករគុណផលគន្លឹះ ដែលត្រូវបានបង្កើតឡើងស្របតាមក្របខណ្ឌវាស់វែងគុណផល។

ក្នុងការអនុវត្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ លើការងារអនុវត្តគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០ គ.ស.ហ. ទទួលខុសត្រូវជាស្ថាប័នសម្របសម្រួល និងតម្រង់ទិសជាគោលនយោបាយ ដើម្បីធានាថា លទ្ធផលនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការងារអនុវត្តគោលនយោបាយនេះដែលអនុវត្តដោយស្ថាប័នបង្គោល ពិតជាសម្រេចបានកម្មវត្ថុគោលនយោបាយ ស្របតាមក្របខណ្ឌ សូចនាករគុណផលដែលមានកំណត់ក្នុងគោលនយោបាយនេះ និងពិតជាអនុវត្តបានត្រឹមត្រូវ ស្របតាមគោលការណ៍តាមដាន និងវាយតម្លៃនៃគោលនយោបាយជាតិ។

ការតាមដានទៅលើការងារអនុវត្តគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២០-២០៣០ នឹងផ្អែកលើក្របខណ្ឌសូចនាករដែលត្រូវបានរៀបចំឡើងស្របតាមគោលគំនិតខ្សែច្រវាក់លទ្ធផលដែលជាគោលការណ៍មួយនៃ "ទ្រឹស្តីនៃការផ្លាស់ប្តូរ" ព្រមទាំងស្របតាមគោលការណ៍ណែនាំរបស់ក្រសួងផែនការ។ សូចនាករទាំងនោះ មានបង្ហាញជូនដូចខាងក្រោម៖

| ក្របខណ្ឌសូចនាករសម្រាប់គោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០ | | |
|---|---|---|
| ប្រភេទសូចនាករ | គោលបំណង | កាលកំណត់ |
| **ការផ្សព្វផ្សាយ គ.ជ.ប្រ.ថ.** | តាមដានវឌ្ឍនភាពនៃការអនុវត្តសកម្មភាពតាមបទប្បញ្ញត្តិ និងការប្រមូលនិងប្រើប្រាស់មូលនិធិ | ប្រចាំឆ្នាំ |
| **ការត្រៀមខ្លួនរបស់ស្ថាប័ន** | តាមដានវឌ្ឍនភាពនៃសមត្ថភាពរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តការងារប្រសិទ្ធភាពថាមពល | ប្រចាំឆ្នាំ |
| **លទ្ធផល** | ការវាយតម្លៃលទ្ធផលនៃវិធានការគោលនយោបាយប្រសិទ្ធភាពថាមពលតាមរយៈគម្រោង យន្តការទីផ្សារ។ល។ | ប្រចាំឆ្នាំ |
| **ផលប៉ះពាល់/ឥទ្ធិពល** | ការវាយតម្លៃវឌ្ឍនភាពឆ្ពោះទៅរកការសម្រេចបាននូវសេដ្ឋកិច្ចដែលមានលក្ខណៈប្រកួតប្រជែង មានភាពធន់ និងមានចីរភាពជាងមុន | ប្រចាំឆ្នាំ |

សូចនាករសម្រាប់តាមដានការអនុវត្តគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០ មានចែងលម្អិតក្នុងឧបសម្ព័ន្ធ ៣។

**គោលការណ៍វាយតម្លៃការអនុវត្តគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០** មានមុខងារជាក់លាក់ចំនួនពីរ៖

១. ការរៀបចំសៀវភៅណែនាំស្តីពីការវាយតម្លៃ ដែលក្នុងសៀវភៅនោះមានបញ្ជាក់ច្បាស់អំពីវិធីសាស្ត្រវាយតម្លៃ និងភាគីពាក់ព័ន្ធក្នុងការងារប្រមូលទិន្នន័យ និងធ្វើរបាយការណ៍។

២. ផែនការវាយតម្លៃ និងថវិកាសម្រាប់អនុវត្តសកម្មភាពគោលនយោបាយនេះ និងមានបញ្ជាក់ស្ថាប័នដៃគូដែលទទួលខុសត្រូវ លក្ខខណ្ឌតម្រូវសម្រាប់ការកសាងសមត្ថភាព និងធនធានហិរញ្ញវត្ថុសម្រាប់សកម្មភាពវាយតម្លៃ។

ខ្លឹមសារដែលមានបញ្ជាក់ក្នុងគោលការណ៍តាមដាន និងវាយតម្លៃគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០ នឹងមានលម្អិតបន្ថែមក្នុងឯកសារជំនួយសម្រាប់ការអនុវត្តគោលនយោបាយនេះ។

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃត្រូវធ្វើឡើងដោយប្រើវិធីសាស្ត្រពីរគឺ៖ ១) វិធីសាស្ត្រពីលើចុះក្រោម និង ២) វិធីសាស្ត្រពីក្រោមឡើងលើ អាស្រ័យលើភាពអាចរកបាន និងភាពងាយស្រួលក្នុងការប្រមូលទិន្នន័យពីប្រភពស្ថាប័នជាតិ និងអន្តរជាតិ ហើយវិធីសាស្ត្រទាំងពីរនេះអាចបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមកបាន។

វិធីសាស្ត្រពីលើចុះក្រោម វាស់វែងការសន្សំសំចៃសរុបនៅក្នុងវិស័យមួយ ឬនៅក្នុងសកម្មភាពសេដ្ឋកិច្ចមួយ ដោយប្រើស្ថិតិជាតិរួមបញ្ចូលគ្នា។ ផលប៉ះពាល់នៃប្រសិទ្ធភាពថាមពល អាចត្រូវបានប៉ាន់ស្មានដោយពិចារណាលើកត្តាប្រើប្រាស់ថាមពលសំខាន់ៗ ដូចជាកម្រិតសកម្មភាពសេដ្ឋកិច្ចតាមវិស័យ លក្ខខណ្ឌអាកាសធាតុ (ឧ. រដូវប្រាំងដែលមានកម្រិតសីតុណ្ហភាពចុះត្រជាក់ជាងធម្មតា អាចនាំឱ្យមានការប្រើប្រាស់ថាមពលនៅក្នុងអគារតិចជាងមុន ហើយការធ្លាក់ចុះបរិមាណថាមពលដែលប្រើប្រាស់បែបនេះ មិនអាចរាប់ថាជាផលនៃប្រសិទ្ធភាពថាមពលបានទេ) ។ល។ ចំណែកនៅក្នុងវិធីសាស្ត្រពីក្រោមឡើងលើវិញ ទិន្នន័យដែលបានមកពីសកម្មភាពអនុវត្តគម្រោងជាក់លាក់ណាមួយ ត្រូវយកមកដាក់បញ្ចូលរួមគ្នាដើម្បីប៉ាន់ស្មានសក្តានុពលវិធានការគោលនយោបាយប្រសិទ្ធភាពថាមពលក្នុងការកាត់បន្ថយបរិមាណថាមពលដែលប្រើប្រាស់។

វិធីសាស្ត្រពីលើចុះក្រោម និងវិធីសាស្ត្រពីក្រោមឡើងលើនេះ មិនមែនជាវិធីសាស្ត្រពីរដាច់ដោយឡែកពីគ្នាទេ តែជាវិធីសាស្ត្រដែលអាចយកមកប្រើរួមបញ្ចូលគ្នាបាន។

ផ្អែកលើប្រព័ន្ធនេះ គណៈកម្មាធិការគោលនយោបាយប្រសិទ្ធភាពថាមពល ត្រូវរៀបចំចេញជារបាយការណ៍ដាក់ជូនទៅ គ.ស.ហ. ដូចខាងក្រោម៖

- របាយការណ៍វាយតម្លៃនៃការប្រៀបធៀបលទ្ធផលសម្រេចបានទៅនឹងសូចនាករដែលបានកំណត់ក្នុងគោលដៅនៃគោលនយោបាយ ដោយត្រូវធ្វើពីរដងក្នុងរយៈពេលនៃគោលនយោបាយគឺលើកទីមួយរៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិ ដើម្បីពិនិត្យវាយតម្លៃ និងលើកជាអនុសាសន៍សម្រាប់កែសម្រួលគោលនយោបាយក្នុងករណីចាំបាច់ និងលើកទីពីររៀបចំរបាយការណ៍នៅឆ្នាំបញ្ចប់ ។

- របាយការណ៍វឌ្ឍនភាពដែលត្រូវធ្វើឡើងជារៀងរាល់ឆ្នាំ ជូន គ.ស.ហ. ដើម្បីមានវិធានការចាំបាច់ក្នុងការដោះស្រាយបញ្ហាប្រឈមចំពោះមុខ និងបន្តអនុវត្តគោលនយោបាយនេះឱ្យទទួលបានជោគជ័យនិង
- របាយការណ៍វាយតម្លៃលើការអនុវត្តសកម្មភាពអាទិភាពនីមួយៗ ដែលត្រូវបានកំណត់ក្នុងគោលនយោបាយ។

## ៨.២. គោលការណ៍គាំទ្រ

គោលការណ៍គាំទ្រក្របខណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ៖

១. **ការប្រើប្រាស់ប្រព័ន្ធ និងនីតិវិធីជាតិនានា៖** សូចនាករ និងនីតិវិធីតាមដាន នឹងពឹងផ្អែកលើទិន្នន័យដែលបានតាមដានដោយក្រសួង ស្ថាប័ន ពាក់ព័ន្ធនានា ទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន។ នីតិវិធីនេះ ក៏ស្របគ្នាជាមួយនឹងគោលការណ៍ណែនាំរបស់ក្រសួងផែនការសម្រាប់ប្រព័ន្ធតាមដាន និងវាយតម្លៃជាតិផងដែរ។ ក្របខណ្ឌនេះនឹងរៀបចំជាប្រព័ន្ធ និងផ្អែកលើគំនិតផ្តួចផ្តើមដែលមានស្រាប់ និងកំពុងបន្ត សម្រាប់ការតាមដាន និងរាយការណ៍អំពីការបង្កើនប្រសិទ្ធភាពថាមពល និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ ប្រព័ន្ធតាមដាន និងវាយតម្លៃនេះនឹងបង្កើតបានទិន្នន័យដែលត្រូវការសម្រាប់ធ្វើរបាយការណ៍ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ក្នុងប្រព័ន្ធតាមដានជាតិ (NMS) ដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន ហើយប្រព័ន្ធទាំងពីរនេះ ត្រូវធ្វើសមាហរណកម្មជាមួយគ្នាឱ្យដល់កម្រិតតាមដែលអាចធ្វើបាន។

២. **ការបញ្ជ្រាបការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពថាមពលក្នុងការរៀបចំផែនការអភិវឌ្ឍន៍ថ្នាក់ជាតិ តាមវិស័យ និងថ្នាក់ក្រោមជាតិ៖** ការកែលម្អប្រសិទ្ធភាពថាមពល អាចចូលរួមចំណែកដល់ការសម្រេចគោលដៅអភិវឌ្ឍន៍ជាតិ និងការប្តេជ្ញាចិត្តបរិស្ថានអន្តរជាតិ។ នីតិវិធី និងសូចនាករសម្រាប់តាមដានឥទ្ធិពលនៃការបង្កើនប្រសិទ្ធភាពថាមពល ត្រូវបានរៀបចំឡើងដើម្បីភ្ជាប់ជាមួយប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃជាតិ ដែលមានស្រាប់ ហើយនឹងបង្កើតជាឯកសារយោងសម្រាប់តាមដានប្រសិទ្ធភាពនៃអន្តរគមន៍គោលនយោបាយ និងយុទ្ធសាស្ត្រប្រសិទ្ធភាពថាមពលជាតិ និងតាមវិស័យនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិផងដែរ។

៣. **ការប្រើប្រាស់ប្រព័ន្ធរាយការណ៍ទីជីថល៖** ជាមួយនឹងការមកដល់នៃសេដ្ឋកិច្ចឌីជីថល និងស្ថាបត្យកម្ម ទិន្នន័យបើកចំហ វិស័យបច្ចេកវិទ្យាមានតួនាទីយ៉ាងសំខាន់ ក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ទាំងនៅកម្រិតប្រតិបត្តិការ និងនៅកម្រិតយុទ្ធសាស្ត្រ ត្រូវបានលើកទឹកចិត្ត ជាពិសេសសម្រាប់ក្រសួង ស្ថាប័នដៃគូទាំងអស់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ៩- សេចក្តីសន្និដ្ឋាន

ប្រសិទ្ធភាពថាមពល គឺជាអភិក្រមដ៏សំខាន់មួយដើម្បីគាំទ្រមហិច្ឆតារបស់កម្ពុជាក្នុងការអភិវឌ្ឍវិស័យថាមពលប្រកបដោយចីរភាព ភាពធន់ និងប្រកបដោយលក្ខណៈកាន់តែទំនើបជាងមុន។ នៅពេលសម្រេចបានការប្រើប្រាស់ថាមពលកាន់តែមានប្រសិទ្ធភាព ដែលទទួលបានជាផលពីការអនុវត្តការងារប្រសិទ្ធភាពថាមពលតាមរយៈគោលនយោបាយនេះ ប្រទេសកម្ពុជានឹងអាចកាត់បន្ថយបាននូវតម្រូវការថាមពល និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការផ្គត់ផ្គង់ និងការបញ្ជូនថាមពល និងអាចកាត់បន្ថយការពឹងផ្អែកលើថាមពលដែលនាំចូលពីក្រៅស្រុកបានផងដែរ។ បន្ថែមពីលើនេះ នៅពេលដែលការប្រើប្រាស់ថាមពលនៅក្នុងប្រទេសមានប្រសិទ្ធភាពជាងមុន តម្លៃសេវាថាមពលក៏នឹងមានកម្រិតទាប ឆ្លើយតបនឹងលទ្ធភាពប្រើប្រាស់សម្រាប់អ្នកប្រើប្រាស់ចុងក្រោយបានជាបន្តបន្ទាប់ផងដែរ។ ប្រសិទ្ធភាពថាមពល ក៏នឹងដើរតួនាទីយ៉ាងសំខាន់ផងដែរ ក្នុងការបំពេញតាមការប្តេជ្ញាចិត្តរបស់ប្រទេសកម្ពុជាក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ក្រោមកិច្ចព្រមព្រៀងទីក្រុងប៉ារីសដូចមានចែងក្នុង ច.ច.ជ. ផងដែរ។

ដោយមើលឃើញពីសារៈសំខាន់ និងភាពចាំបាច់នៃផលប៉ះពាល់ចេញពីការងារប្រសិទ្ធភាពថាមពលបែបនេះហើយទើបរាជរដ្ឋាភិបាលកម្ពុជា បានសម្រេចកំណត់យកគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០ ជាក្របខណ្ឌណែនាំដើម្បីគាំទ្រដល់ការពន្លឿនការងារប្រសិទ្ធភាពថាមពលនៅកម្ពុជា។ គោលនយោបាយនេះកំណត់អំពីចក្ខុវិស័យ គោលបំណង គោលដៅ និងកម្មវត្ថុ យ៉ាងច្បាស់លាស់ស្តីពីប្រសិទ្ធភាពថាមពល សម្រាប់ឆ្នាំ២០២២-២០៣០។ ដើម្បីជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាពគោលនយោបាយនេះ ក៏បានដាក់ចេញនូវវិធានការគោលនយោបាយជាក់លាក់ទាំងសម្រាប់ការអនុវត្តក្នុងក្របខណ្ឌគោលនយោបាយរួម ទាំងសម្រាប់ការអនុវត្តតាម វិស័យនៃការប្រើប្រាស់ថាមពលនីមួយៗ ព្រមទាំងបានកំណត់ក្របខណ្ឌសម្របសម្រួលរវាងភាគីពាក់ព័ន្ធ និងការតាមដានវឌ្ឍនភាពនៃការអនុវត្តថែមទៀតផង។ គោលនយោបាយនេះ គឺជាជំហានដំបូងនៃដំណើររបស់កម្ពុជា ឆ្ពោះទៅរកការសម្រេចឱ្យបាននូវការកសាង "សង្គមប្រសិទ្ធភាពថាមពល" មួយ ដែលនៅក្នុងនោះ ប្រជាពលរដ្ឋកម្ពុជានឹងមានថាមពលប្រើប្រាស់គ្រប់គ្រាន់ មានសន្តិសុខថាមពលកាន់តែប្រសើរ និងមានថ្លៃសេវាថាមពលកាន់តែសមរម្យ ដើម្បីបំពេញតម្រូវការប្រើប្រាស់របស់ខ្លួន ប្រកបដោយនិរន្តរភាព។

ក្រសួងរ៉ែ និងថាមពល រួមជាមួយក្រសួងពាក់ព័ន្ធ ដូចជា ក.ឧ.វ.ប.ន., ក.ដ.ន.ស. និង ក.ស.ជ. បានកំណត់ផែនការសកម្មភាពអាទិភាពដែលនឹងត្រូវផ្តល់ថវិកាអភិវឌ្ឍតាមវិស័យនីមួយៗ ហើយតាមរយៈយន្តការនេះ មូលនិធិអភិវឌ្ឍគម្រោងប្រសិទ្ធភាពថាមពលនឹងអាចត្រូវបានបែងចែកយ៉ាងមានប្រសិទ្ធភាព។ ថវិកានឹង

ត្រូវបានកៀរគរពីប្រភពផ្សេងៗគ្នាដូចជាថវិការាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ វិស័យឯកជន យន្តការទីផ្សារនានា ។ល។ ដើម្បីគាំទ្រ និងអនុវត្តកម្មវិធីដែលមានស្រាប់ និងផែនការដែលបានគ្រោងទុកសម្រាប់ការងារប្រសិទ្ធភាពថាមពល៕

# ឧបសម្ព័ន្ធ ១- សទ្ទានុក្រមគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០

| ពាក្យគន្លឹះជាភាសាខ្មែរ | ពាក្យគន្លឹះជាភាសាអង់គ្លេស | ពន្យល់ពាក្យ |
|---|---|---|
| កម្មវិធីគ្រប់គ្រងថាមពល | Energy management program | សំដៅដល់កម្មវិធីដែលកំណត់ដោយស្ថាប័នបង្គោល ដើម្បីគ្រប់គ្រងការប្រើប្រាស់ថាមពល របស់គ្រប់អ្នកប្រើប្រាស់ថាមពលមុខសញ្ញា។ |
| ការិយាល័យបង្គោលផ្នែកប្រសិទ្ធភាពថាមពល | Energy Efficiency Focal Office | សំដៅដល់ការិយាល័យនៅក្នុងស្ថាប័នបង្គោល ស្ថាប័នដៃគូ និងនៅតាមរាជធានីខេត្ត ដែលត្រូវបានរៀបចំឡើង ដើម្បីទទួលខុសត្រូវជាពិសេសលើការងារប្រសិទ្ធភាពថាមពល ទៅតាមវិសាលភាពនៃដែនសមត្ថកិច្ចរបស់ខ្លួន។ |
| កិច្ចសន្យាអនុវត្តនៃការផ្តល់សេវាថាមពល | Energy Service Performance contracts | សំដៅដល់កិច្ចសន្យាដែលបង្កើតឡើងរវាងក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល និងអតិថិជនរបស់ខ្លួនក្នុងគោលបំណងជានានូវការបំពេញការអនុវត្តនៃការផ្តល់សេវាថាមពលសម្រាប់សកម្មភាព ឬការអនុវត្តគម្រោង ឬកម្មវិធីប្រសិទ្ធភាពថាមពលណាមួយ។ |
| ក្រុមការងារបង្គោលសម្រាប់ការងារប្រសិទ្ធភាពថាមពល | Energy Efficiency Focal Office | សំដៅដល់ធនធានមនុស្សរាប់ទាំងបុគ្គលទូទៅ និងអ្នកជំនាញដែលបង្កើតឡើងនៅការិយាល័យប្រសិទ្ធភាពថាមពលរបស់ ក.ឧ.វ.ប.ន., ក.ជ.ន.ស., ក. ស. ជ. និងរដ្ឋបាលរាជធានី ខេត្តនានា ដែលបានទទួលការចាត់តាំងពីស្ថាប័នសាមីឱ្យទទួលភារៈលើការងារប្រសិទ្ធភាពថាមពលក្នុងដែនសមត្ថកិច្ចរបស់ស្ថាប័នខ្លួន។ |
| ក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល | Energy Service Companies | សំដៅដល់ក្រុមហ៊ុនពាណិជ្ជកម្ម ឬអង្គការរកប្រាក់ចំណេញដែលផ្តល់នូវដំណោះស្រាយបញ្ហាថាមពល រួមមានការអភិវឌ្ឍ ការងារសិក្សាគម្រោងប្លង់ និងការអនុវត្តគម្រោងសន្សំសំចៃថាមពល ការកែច្នៃ និងសេវាថាមពលផ្សេងទៀត។ |

| | | |
|---|---|---|
| **គីឡូតោនសមមូលប្រេង** | Kiloton of oil equivalent | សំដៅដល់ឯកតាថាមពលដែលបានកំណត់ជាបរិមាណថាមពលដែលបានបញ្ចេញដោយការដុតប្រេងឆៅមួយគីឡូតោន។ |
| **គុណផល** | Performance | សំដៅដល់គុណភាពបូកនឹងលទ្ធផលនៃសកម្មភាពអនុវត្តការងារ ឬដំណើរការបំពេញមុខងារ ឬកិច្ចការអ្វីមួយ។ ការបំពេញគុណផល ខុសគ្នាពីការអនុវត្តសកម្មភាព និងការបំពេញមុខងារធម្មតាទូទៅនៅត្រង់ការអនុវត្តសកម្មភាព និងការបំពេញមុខងារធម្មតាទូទៅ មាន  លក្ខណៈកំណត់ដោយអំពើធ្វើសកម្មភាពចំណែកការបំពេញគុណផល សំដៅយកទាំងសមត្ថភាពអនុវត្តសកម្មភាព ទាំងគុណភាពនៃការអនុវត្តសកម្មភាពនោះ។ |
| **តោនសមមូលកាបូនឌីអុកស៊ីត** | Ton of carbon dioxide equivalent | សំដៅដល់ខ្នាតរង្វាស់ដែលត្រូវបានប្រើ ដើម្បីប្រៀបធៀបការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីប្រភពផ្សេងៗទៅនឹងបរិមាណឧស្ម័នកាបូនឌីអុកស៊ីត។ |
| **ថាមពលប្តូរទៅជាការបម្រើសេវា** | Energy-as-a-service ( EaaS ) | សំដៅដល់គំរូធុរកិច្ចផ្នែកថាមពលមួយ ដែលអ្នកផ្តល់សេវា ( ដូចជា សហគ្រាសថាមពល ឬអ្នកផ្តល់សេវាដទៃទៀត ) ផ្តល់សេវាថាមពលផ្សេងៗ លើសពីការផ្គត់ផ្គង់ត្រឹមតែថាមពលអគ្គិសនី។ សេវាទាំងនេះ អាចរាប់បញ្ចូលទាំងការផ្តល់ប្រឹក្សាថាមពល ការដំឡើងឧបករណ៍ ឬសម្ភារៈថាមពលនានា ការផ្តល់ហិរញ្ញប្បទាន និងសេវាដំណោះស្រាយការគ្រប់គ្រងថាមពលនានាទៅដល់អ្នកប្រើប្រាស់ថាមពលអគ្គិសនីចុងក្រោយ។ |
| **បច្ចេកវិទ្យាធ្វើឱ្យត្រជាក់និងក្តៅដោយអកម្មជាមួយថាមពល** | Passive Cooling Techniques or Passive Building Design Strategies | សំដៅដល់វិធីសាស្ត្រការងារសិក្សាគម្រោងប្លង់អគារដែលផ្តោតលើការត្រួតពិនិត្យកម្តៅ និងការបន្សាយកម្តៅនៅក្នុងអគារ ដើម្បីធ្វើឱ្យផាសុកភាពកម្តៅក្នុងអគារមានភាពប្រសើរឡើង ដោយការប្រើប្រាស់ថាមពលទាប ឬគ្មានប្រើថាមពល។ បច្ចេកទេសត្រជាក់អកម្មមួយចំនួន រួមមាន ការប្រើខ្យល់ធម្មជាតិសម្រាប់ការត្រជាក់ ការការពារការចាំងចូល ពន្លឺព្រះអាទិត្យដោយផ្ទាល់ ប៉មខ្យល់ ឥទ្ធិពលទីធ្លា ផ្លូវរូងក្រោមដី ខ្យល់ត្រជាក់រំហួត ជញ្ជាំងអ៊ីសូឡង់ការពារកម្តៅ ការលាបពណ៌ ការប្រើបង្អួចទប់កម្តៅព្រះអាទិត្យ បញ្ចុះត្រជាក់ដោយប្រើកាំរស្មី។ល។ |

| | | |
|---|---|---|
| **បទដ្ឋានគុណផលការប្រើប្រាស់ថាមពល** | Energy performance standards | សំដៅដល់លក្ខខណ្ឌដែលកំណត់កម្រិតនៃការបំពេញគុណផលការប្រើប្រាស់ថាមពលរបស់ឧបករណ៍អគ្គិសនី ឧបករណ៍ភ្លើងបំភ្លឺ និងបរិក្ខារអគ្គិសនី ដែលត្រូវតែបំពេញតាម ឬអនុវត្តតាម ដើម្បីធានាឱ្យបានថាគោលដៅ គោលបំណង និងការងារប្រសិទ្ធភាពថាមពល សម្រេចបានប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។ |
| **បទដ្ឋានគុណផលការប្រើប្រាស់ថាមពលអប្បបរមា** | Minimum energy performance standards | សំដៅដល់លក្ខខណ្ឌដែលកំណត់កម្រិតតិចបំផុតនៃការបំពេញ គុណផលការប្រើប្រាស់ថាមពលរបស់ឧបករណ៍អគ្គិសនី ឧបករណ៍ភ្លើងបំភ្លឺ និងបរិក្ខារអគ្គិសនី ដែលត្រូវតែបំពេញតាម ឬឱ្យបានលើសពីកម្រិតលក្ខខណ្ឌកំណត់នេះ មុនពេលអនុញ្ញាតឱ្យចែកចាយ ឬប្រើប្រាស់សម្រាប់គោលបំណងពាណិជ្ជកម្មបាន។ |
| **បទដ្ឋាន & ការបិទស្លាកសញ្ញា** | Standard and Labelling | សំដៅដល់នីតិវិធីនិងបទប្បញ្ញត្តិស្តីពីថាមពលទាំងឡាយ ដែលកំណត់កម្រិតគុណផលការប្រើប្រាស់ថាមពលសម្រាប់ផលិតផល (ឧបករណ៍ ឬប្រដាប់ប្រដារដែលប្រើប្រាស់ថាមពល) ដោយប្រើស្លាកសញ្ញាប្រសិទ្ធភាពថាមពល ដើម្បីពិពណ៌នាអំពីកម្រិតគុណផលការប្រើប្រាស់ថាមពលរបស់ផលិតផល (ឧបករណ៍ឬប្រដាប់ប្រដា) (ជាទូទៅក្នុងរូបភាពជាប្រសិទ្ធភាព ឬថ្លៃចំណាយលើថាមពល) ដើម្បីផ្តល់ជូនអ្នកប្រើប្រាស់នូវទិន្នន័យចាំបាច់សម្រាប់ការសម្រេចចិត្តទិញ។ |
| **ប្រព័ន្ធសម្រាំង និងចាត់ថ្នាក់ក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល** | System for the empanelment and rating of ESCOs | សំដៅដល់ឯកសារគតិយុត្តដែលមានចែងលម្អិតអំពីគោលការណ៍ នីតិវិធី លក្ខខណ្ឌតម្រូវ លក្ខខណ្ឌវិនិច្ឆ័យ ដែលរៀបចំ និងចេញដោយក្រសួងរ៉ែ និងថាមពលសម្រាប់គ្រប់គ្រងការសម្រាំងក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល។ |
| **ផែនការសកម្មភាពប្រសិទ្ធភាពថាមពលតាមវិស័យ** | Sectoral Energy Efficiency Action Plans | សំដៅដល់ផែនការសកម្មភាពប្រសិទ្ធភាពថាមពលតាមវិស័យ គឺជាផែនការសកម្មមួយដែលរួមមានវិធានការប្រសិទ្ធភាពថាមពលតាមវិស័យ ការវាយតម្លៃសមិទ្ធិលទ្ធភាព តម្រូវការវិនិយោគ ដំណើរការ អនុវត្ត និងផលប្រយោជន៍រំពឹងទុក។ ផែនការសកម្មភាពប្រសិទ្ធភាពថាមពលតាមវិស័យត្រូវបង្កើតឡើងដោយស្ថាប័នដៃគូនៃវិស័យនោះ ដោយសហការជាមួយស្ថាប័នបង្គោល និងក្រុមការងារបង្គោលផ្នែកប្រសិទ្ធភាពថាមពល |

| | | |
|---|---|---|
| | | សម្រាប់វិស័យដូចខាងក្រោម ៖ ក) អគារ និងលំនៅឋាន (ក.ជ.ន.ស.) ខ) សេវាសាធារណៈ (ក. ស. ជ) គ) ឧស្សាហកម្ម (ក.ឧ.វ.ប.ន.) ឃ) វិស័យដឹកជញ្ជូន (ក.ស.ជ.)។ |
| **វិធានការប្រសិទ្ធភាពថាមពល** | Energy Efficiency Measures | សំដៅដល់វិធានការកាត់បន្ថយការប្រើប្រាស់ថាមពល ប៉ុន្តែនៅតែរក្សាបានទិន្នផលដូចគ្នា ឬប្រសើរជាងមុន។ គោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពលនេះ គ្របដណ្តប់តែលើវិធានការប្រសិទ្ធភាពថាមពលផ្នែកប្រើប្រាស់ថាមពលប៉ុណ្ណោះ។ |
| **វិធានថាមពលសម្រាប់អគារ** | Building Energy Code | សំដៅដល់ឧបករណ៍គតិយុត្តដែលបញ្ជាក់ពីស្តង់ដារប្រសិទ្ធភាពថាមពលអប្បបរមាសម្រាប់អគារលំនៅឋាន និងអគារពាណិជ្ជកម្ម និងអគារផ្សេងទៀត (រាប់យករាល់អគារទាំងអស់ក្រៅពីអគារលំនៅឋាន)។ វិធានថាមពលសម្រាប់អគារ តម្រូវឱ្យមានលក្ខណៈប្រសិទ្ធភាពថាមពលជាក់លាក់សម្រាប់បច្ចេកវិទ្យាសាងសង់ និងការងារសិក្សាគម្រោងប្លង់ផ្សេងទៀតសម្រាប់អគារ។ បច្ចេកវិទ្យានៃការកសាងនិងការងារសិក្សាគម្រោងប្លង់ ដែលអាចត្រូវបានរួមបញ្ចូលនៅក្នុងវិធានថាមពលសម្រាប់អគារ រួមមាន៖ ស្រោមអគារ ប្រព័ន្ធ (HVAC) កម្តៅ លំហូរខ្យល់ និងម៉ាស៊ីនត្រជាក់ ភ្លើងបំភ្លឺ និងប្រព័ន្ធកម្តៅទឹកជាដើម។ |
| **វិធានស្តីពីការបំភ្លឺ** | National Lighting Code | សំដៅដល់វិធានស្តីពីការបំភ្លឺ គឺជាឯកសារផ្លូវច្បាប់ដែលកំណត់នូវលក្ខខណ្ឌតម្រូវ សម្រាប់គ្រប់គ្រងការទទួលខុសត្រូវផ្នែកសង្គម ពាណិជ្ជកម្ម និងវិស្វកម្មរបស់អ្នកសិក្សាគម្រោងប្លង់ អ្នកផលិត និងអ្នកផ្គត់ផ្គង់ឧបករណ៍បំភ្លឺ។ វិធាននេះ ផ្តល់ការណែនាំស្តីពីការអនុវត្តវិស្វកម្មល្អសម្រាប់ការងារសិក្សាគម្រោងប្លង់ ការជ្រើសរើស ដំឡើង និងថែរក្សាប្រព័ន្ធភ្លើងបំភ្លឺសម្រាប់ផ្នែកក្នុងផ្ទះ និងក្រៅផ្ទះ។ វិធាននេះ មានចែងអំពីទិដ្ឋភាពទាក់ទងនឹងការគ្រប់គ្រងថាមពល និងប្រសិទ្ធភាពថាមពលក្នុងការដំឡើងភ្លើងបំភ្លឺ និងទិដ្ឋភាពសម្របសម្រួលដែលត្រូវយកមកពិចារណានៅពេលការងារសិក្សាគម្រោងប្លង់ប្រព័ន្ធភ្លើងបំភ្លឺផងដែរ។ |
| **វិស័យអគារ** | Building Sector | សំដៅដល់វិស័យអគាររាប់បញ្ចូលអគារលំនៅឋាន អគារពាណិជ្ជកម្ម និងអគារផ្សេងទៀត (រាប់យករាល់អគារទាំងអស់ក្រៅពីអគារលំនៅឋាន) ទាំងអស់។ អគារពាណិជ្ជកម្ម និងអគារផ្សេងទៀត រាប់បញ្ចូល |

| | | |
|---|---|---|
| | | ទាំងទីកន្លែងដែលមានសំណង់បិទបាំង សម្រាប់មនុស្សធ្វើសកម្មភាពនានា ដូចគ្នានឹងសកម្មភាពដែលធ្វើនៅក្នុងការិយាល័យ នៅតាមកន្លែងអប់រំ មន្ទីរពេទ្យ សណ្ឋាគារ តូបលក់រាយ ឃ្លាំង ឬកន្លែងសម្រាប់ទុកដាក់សម្ភារៈដែរ។ |
| **សេវាផ្គូផ្គងអ្នកវិនិយោគ** | Investor matchmaking services | សំដៅដល់ការផ្តល់ដំណោះស្រាយធុរកិច្ចមួយ ដែលតាមរយៈនេះអន្តរការីផ្តល់សេវាភ្ជាប់ទំនាក់ទំនងវិនិយោគិនដែលមានលទ្ធភាព និងបំណងវិនិយោគចំគ្នាជាមួយនឹងធុរជនដែលមានតម្រូវការវិនិយោគ។ សេវាកម្មផ្គូផ្គងវិនិយោគិនត្រូវភ្ជាប់និងផ្គូផ្គងវិនិយោគិនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ លើគ្រប់វិស័យទាំងអស់ដែលមានឱកាសវិនិយោគប្រសិទ្ធភាពថាមពល។ សេវាកម្មនេះ នឹងត្រូវបានផ្តល់ជូនតាមរយៈវេទិកាឌីជីថល។ វេទិកានេះ នឹងធ្វើជាមូលដ្ឋានទិន្នន័យដែលនឹងមានផ្តល់ព័ត៌មានជាក់លាក់អំពីគម្រោងប្រសិទ្ធភាពថាមពល ដូចជាតម្រូវការវិនិយោគ ភាពសក្តិសម ឥណទានរបស់គម្រោង ផលប៉ះពាល់ដែលរំពឹងទុក (លើបរិស្ថាន និងសង្គម) ការវិភាគហិរញ្ញវត្ថុ ឧបសគ្គហានិភ័យ និងក្របខណ្ឌគោលនយោបាយដែលពាក់ព័ន្ធនឹងគម្រោង។ ដោយប្រើទិន្នន័យនេះ វិនិយោគិនត្រូវបានគេរំពឹងថានឹងកំណត់សំណើវិនិយោគបានត្រឹមត្រូវ។ |
| **សេវាផ្តល់យោបល់លើកិច្ចការជំនួញ** | Transaction advisory services | សំដៅដល់ការផ្តល់ដំណោះស្រាយធុរកិច្ចមួយ ដែលតាមរយៈនេះអន្តរការី ផ្តល់ការប្រឹក្សាយោបល់ ការភ្ជាប់ទំនាក់ទំនង និងសេវាបន្ថែម ដល់អ្នកទទួលសេវារបស់ខ្លួន ឯកត្តជន វិនិយោគិន ក្រុមហ៊ុន ឬទីភ្នាក់ងារណាមួយ ក្នុងគោលបំណងឱ្យអ្នកទទួលសេវារបស់ខ្លួនសម្រេចបាននូវកម្មវត្ថុជំនួញរបស់ខ្លួន។ សេវាកម្មទាំងនេះពាក់ព័ន្ធនឹងការវាយតម្លៃផ្នែកបច្ចេកវិទ្យា ពាណិជ្ជកម្ម និងចំណាត់ថ្នាក់វិនិយោគសម្រាប់វិស័យថាមពលដើម្បីរៀបចំការសិក្សាលទ្ធភាព ការសិក្សាអំពីលក្ខណៈបច្ចេកទេស និងហិរញ្ញវត្ថុគម្រោង ការរៀបចំគម្រោងការគ្រប់គ្រងដំណើរការដេញថ្លៃ និងការជ្រើសរើសអ្នកដេញថ្លៃដើម្បីអនុវត្តគម្រោងប្រសិទ្ធភាពថាមពល។ |

| | | |
|---|---|---|
| **សេវាសាធារណៈ** | Public Services | សំដៅដល់សេវាផ្តល់ដោយរដ្ឋាភិបាលថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិដែលមានគោលបំណងបម្រើដល់សាធារណជន។ នៅក្នុងបរិបទនៃគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល សេវាសាធារណៈ គឺជាសេវាសាធារណៈណាដែលប្រើប្រាស់ថាមពល។ |
| **ស្ថាប័នដៃគូ** | Partner Agency | សំដៅដល់ស្ថាប័នរដ្ឋាភិបាល ស្ថាប័នបច្ចេកទេស រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានតួនាទីក្នុងការងារប្រសិទ្ធភាពថាមពល។ ស្ថាប័នទាំងនេះរួមមាន ក.ស.ហ.វ ក.ឧ.វ.ប.ន. ក.ជ.ន.ស. ក. ស. ជ ក.ជ.អ.ច. អគ្គិសនីកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងរដ្ឋបាលរាជធានី ខេត្ត។ ស្ថាប័នដៃគូ គឺជាស្ថាប័នដែលទទួលខុសត្រូវបំពេញភារកិច្ច និងអនុវត្តគោលនយោបាយនេះ តាមវិស័យ និងដែនសមត្ថកិច្ចរបស់ខ្លួន និងត្រូវមានតួនាទីបំពេញបន្ថែម និងសម្របសម្រួល ជាមួយស្ថាប័នបង្គោល ដើម្បីឱ្យការអនុវត្តគោលនយោបាយនេះ ទទួលបានជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់។ |
| **ស្ថាប័នបង្គោល** | Nodal Agency | សំដៅដល់ស្ថាប័នជាតិទទួលបន្ទុកសម្របសម្រួល អនុវត្ត និងត្រួតពិនិត្យការងារប្រសិទ្ធភាពថាមពលនៅកម្ពុជា។ ក្រសួងរ៉ែ និងថាមពល គឺជាស្ថាប័នបង្គោលសម្រាប់ការងារប្រសិទ្ធភាពថាមពល និងត្រូវធ្វើការឆ្ពោះទៅរកគោលដៅចម្បងនៃការកាត់បន្ថយអាំងតង់ស៊ីតេថាមពលនៃសេដ្ឋកិច្ចកម្ពុជាក្នុងក្របខណ្ឌរួមនៃគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល។ ស្ថាប័នបង្គោល គឺជាស្ថាប័នដែលទទួលខុសត្រូវផ្ទាល់ និងមានតួនាទីដឹកនាំអនុវត្ត និងធានាឱ្យការអនុវត្តគោលនយោបាយ បទប្បញ្ញត្តិនិងវិធានពាក់ព័ន្ធទាំងអស់ ដែលមានកំណត់ក្នុងគោលនយោបាយនេះ ទទួលបានជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់។ |
| **ស្រោមអគារ** | Building envelope | សំដៅដល់លំញែកផ្នែករូបវន្តរវាងបរិវេណខាងក្រៅ និងផ្ទៃខាងក្នុងនៃអគារ ដែលរាប់បញ្ចូលទាំងលក្ខណៈសំណង់និងរចនាប័ទ្មនៃអគារ ដែលមាននាទីកំណត់លក្ខខណ្ឌបរិយាកាសរបស់អគារ រួមមានភាពធន់នឹងខ្យល់ ទឹក កម្តៅ ពន្លឺ និងការផ្ទេរសំឡេងរំខាន។ |

| | | |
|---|---|---|
| **អាំងតង់ស៊ីតេប្រើប្រាស់ថាមពល** | Energy Use Intensity | សំដៅដល់ការប្រើប្រាស់ថាមពលប្រចាំឆ្នាំរបស់អគារគិតជាគីឡូវ៉ាត់ម៉ោង ធៀបនឹងផ្ទៃក្រឡាសរុបដែលគិតជាម៉ែត្រការ៉េ។ |
| **អ្នកប្រើប្រាស់ថាមពលមុខសញ្ញា** | Designated Energy Consumer | សំដៅដល់រាល់អ្នកប្រើប្រាស់ថាមពលទាំងអស់ រាប់ទាំងអ្នកប្រើប្រាស់ថាមពលប្រភេទឧស្សាហកម្ម អគារនិវាសនដ្ឋាន សេវាសាធារណៈ និងការដឹកជញ្ជូន ដែលបានប្រើប្រាស់ថាមពលលើសពីកម្រិតប្រើប្រាស់ថាមពលដែលបានកំណត់។ អ្នកប្រើប្រាស់ថាមពលមុខសញ្ញា គឺជាអគារនិងរោងចក្រឧស្សាហកម្មប្រើថាមពលច្រើនដែលស្ថាប័នដៃគូរួមជាមួយស្ថាប័នបង្គោលកំណត់ជាអ្នកប្រើប្រាស់មុខសញ្ញា តាមរយៈការកំណត់កម្រិតនៃចំនួនប្រើប្រាស់ថាមពល។ |
| **ឧបករណ៍ និងបរិក្ខារអគ្គិសនីមុខសញ្ញា** | Designated Electrical Appliances and Equipment | សំដៅដល់ឧបករណ៍និង/ឬបរិក្ខារទាំងឡាយ ដែលស្ថាប័នបង្គោលកំណត់ដាក់បញ្ចូលជាផ្នែកមួយនៃកម្មវិធី "បទដ្ឋាន&ការបិទស្លាកសញ្ញា" តាមរយៈប្រកាសរបស់ក្រសួងរ៉ែ និងថាមពល។ |

# ឧបសម្ព័ន្ធ ២- វិធានការគោលនយោបាយ និងផែនការសកម្មភាព

| វិស័យ | វិធានការ គោលនយោបាយ | ផែនការសកម្មភាព | ពេលវេលា អនុវត្ត | ស្ថាប័ន អនុវត្ត | ស្ថាប័នដៃគូ |
|---|---|---|---|---|---|
| ឧស្សាហកម្ម និង អគារ | ១.បង្កើតកម្មវិធីគ្រប់គ្រងថាមពលសម្រាប់ឧស្សាហកម្ម អគារ | ១.១. រៀបចំ និងដាក់ចេញអនុក្រឹត្យស្ដីពីកម្មវិធីគ្រប់គ្រងថាមពល | ២០២២-២០២៣ | ក.រ.ថ. ក.ឧ.វ.ប.ន. | ក.ឧ.វ.ប.ន. ក.ដ.ន.ស. ក.អ.ក. |
| | | ១.២. បង្កើតរចនាសម្ព័ន្ធរដ្ឋបាលគ្រប់គ្រងកម្មវិធីគ្រប់គ្រងថាមពល (កំណត់ការទទួលខុសត្រូវរបស់ស្ថាប័នពាក់ព័ន្ធ ផែនការវិភាជធនធាន និងយន្តការតាមដាន និងត្រួតពិនិត្យ) | ២០២៣ | | |
| | | ១.៣. ជ្រើសរើសបទដ្ឋានគ្រប់គ្រងថាមពលអន្តរជាតិសមស្រប ដើម្បីធ្វើជាមូលដ្ឋានអនុវត្ត សម្រាប់កម្មវិធីគ្រប់គ្រងថាមពល | ២០២៣ | | |
| | | ១.៤. កំណត់កម្រិតប្រើប្រាស់ថាមពល សម្រាប់ជ្រើសរើសឧស្សាហកម្ម និងអគារដែលត្រូវអនុវត្តកម្មវិធីគ្រប់គ្រងថាមពល | ២០២៣ | | |
| | | ១.៥. ពិគ្រោះយោបល់រវាងស្ថាប័នបង្គោលជាមួយរោងចក្រ សហគ្រាស ឧស្សាហកម្ម និងអគារ ដែលបានជ្រើសរើស | ២០២៣ | | |
| | | ១.៦. រៀបចំ បញ្ជីឈ្មោះឧស្សាហកម្មនិងអគារដែលត្រូវអនុវត្ត កម្មវិធីគ្រប់គ្រងថាមពល | ២០២៤ | | |
| | | ១.៧. បង្កើតយន្តការឱ្យឧស្សាហកម្មនិងអគារដែលបានជ្រើសរើសរាយការណ៍អំពីទិន្នន័យការប្រើប្រាស់ថាមពល | ២០២៤ | | |
| | | ១.៨. សម្រាំងក្រុមហ៊ុនសវនកម្មថាមពល | ២០២៤ | | |
| | | ១.៩. ពង្រឹងសមត្ថភាពបុគ្គលិករបស់ឧស្សាហកម្ម និងអគារពាក់ព័ន្ធលើការងារធ្វើរបាយការណ៍អំពីការប្រើប្រាស់ថាមពល | ២០២៤ | | |

| វិស័យ | វិធានការ<br>គោលនយោបាយ | ផែនការសកម្មភាព | ពេលវេលា<br>អនុវត្ត | ស្ថាប័ន<br>អនុវត្ត | ស្ថាប័នដៃគូ |
|---|---|---|---|---|---|
| ឧស្សាហកម្ម និង អគារ | ២.បង្កើតបទប្បញ្ញត្តិដើម្បីដាក់កំណត់ឱ្យឧស្សាហកម្ម និងអគារអនុវត្ត តាមបញ្ញត្តិនៃកម្មវិធីគ្រប់គ្រងថាមពល | ២.១. រៀបចំបទប្បញ្ញត្តិនានាសម្រាប់ អនុវត្តកម្មវិធីគ្រប់គ្រងថាមពលសម្រាប់វិស័យនីមួយៗ | ២០២៣ | ក.រ.ថ.<br>ក.ឧ.វ.ប.ន. | ក.ឧ.វ.ប.ន.<br>ក.ដ.ន.ស. |
| | | ២.២. ដាក់ចេញ និងផ្សព្វផ្សាយបទប្បញ្ញត្តិខាងលើជាសាធារណៈ | ២០២៣ | | |
| | ៣.បង្កើតប្រព័ន្ធសម្រាំង និងចាត់ថ្នាក់ក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល | ៣.១. រៀបចំ និងវាយតម្លៃឯកសារគតិយុត្ត គ្រប់គ្រងការសម្រាំងក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល | ២០២៣ | ក.រ.ថ. | ក.ឧ.វ.ប.ន.<br>ក.ដ.ន.ស. |
| | | ៣.២. ដាក់ចេញ និងផ្សព្វផ្សាយ នូវឯកសារគតិយុត្តខាងលើជាសាធារណៈ | ២០២៤ | | |
| | | ៣.៣. កំណត់ និងឯកភាពក្នុងចំណោមស្ថាប័នពាក់ព័ន្ធនូវលក្ខខណ្ឌវិនិច្ឆ័យសម្រាប់ការសម្រាំង និងចំណាត់ថ្នាក់ ក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល | ២០២៣ | | |
| | | ៣.៤. ឱ្យក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល ដាក់ពាក្យសុំផ្តល់សេវានេះ ស្ថាប័នពាក់ព័ន្ធធ្វើការវាយតម្លៃ និងសម្រេចផ្តល់សិទ្ធិឱ្យចូលរួម ស្របតាមលក្ខខណ្ឌវិនិច្ឆ័យដែលបានបង្កើត | ២០២៤ | | |
| | | ៣.៥. រៀបចំបញ្ជីទិន្នន័យ ក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពលដែលបានដាក់ពាក្យសុំផ្តល់សេវានេះ | ២០២៤ | | |
| | | ៣.៦. បញ្ចប់បញ្ជីឈ្មោះ ក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល ដែលមានសិទ្ធិចូលរួម | ២០២៤ | | |

| វិស័យ | វិធានការគោលនយោបាយ | ផែនការសកម្មភាព | ពេលវេលាអនុវត្ត | ស្ថាប័នអនុវត្ត | ស្ថាប័នដៃគូ |
|---|---|---|---|---|---|
| | | ៣.៧. ធ្វើការវាយតម្លៃនិងសម្រាំងយក ក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល និងផ្តល់ចំណាត់ថ្នាក់ | ២០២៤ | | |
| | | ៣.៨. ផ្សព្វផ្សាយអំពី ចំណាត់ថ្នាក់ ក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល ដោយផ្អែកលើការវាយតម្លៃឯករាជ្យតាមលក្ខខណ្ឌវិនិច្ឆ័យ | ២០២៤ | | |
| ឧស្សាហកម្ម និងអគារ | ៤.រៀបចំប្រព័ន្ធវ.រ.ផ. សម្រាប់ការវាស់វែង ការរាយការណ៍ និងការផ្ទៀងផ្ទាត់គម្រោងប្រសិទ្ធភាពថាមពលសម្រាប់ ឧស្សាហកម្ម និងអគារដែលអនុវត្តដោយ អ.ប.ថ.ម ជាផ្នែកមួយនៃកម្មវិធីគ្រប់គ្រងថាមពលរបស់ខ្លួន | ៤.១. រៀបចំបញ្ជីបច្ចេកវិទ្យាប្រសិទ្ធភាពថាមពល | ២០២៣-២០២៤ | ក.រ.ថ. | ក.ប.ស.<br>ក.ឧ.វ.ប.ន.<br>ក.ដ.ន.ស. |
| | | ៤.២. បង្កើតប្រព័ន្ធ វ.រ.ផ. ជាក់លាក់សម្រាប់បច្ចេកវិទ្យារបស់អ្នកប្រើប្រាស់ថាមពលមុខសញ្ញា (អ.ប.ថ.ម) | ២០២៥ | | |
| | | ៤.៣. បង្កើតប្រព័ន្ធ វ.រ.ផ. សម្រាប់ធ្វើការវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ការប្រើប្រាស់ថាមពល ដោយមានរួមបញ្ចូលរបាយការណ៍នៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សម្រាប់ការធ្វើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ | ២០២៦ | | |
| | ៥.រៀបចំបទដ្ឋាន&ការបិទស្លាកសញ្ញា សម្រាប់ឧបករណ៍បរិក្ខារ ចង្ក្រាន | ៥.១. រៀបចំ និងដាក់ចេញអនុក្រឹត្យ ដើម្បីបង្កើតរចនាសម្ព័ន្ធ រដ្ឋបាលសម្រាប់ការរៀបចំ បទដ្ឋាន&ការបិទស្លាកសញ្ញា និងដាក់ចេញនីតិវិធីទូទៅដើម្បីបញ្ញត្តិលើ "បទដ្ឋាន&ការបិទស្លាកសញ្ញា" សម្រាប់ឧបករណ៍ បរិក្ខារ ព្រម | ២០២២-២០២៣ | ក.រ.ថ. | វ.ស.ក.<br>អ.គ.វ.<br>អ.ឧ. |

| វិស័យ | វិធានការគោលនយោបាយ | ផែនការសកម្មភាព | ពេលវេលាអនុវត្ត | ស្ថាប័នអនុវត្ត | ស្ថាប័នដៃគូ |
|---|---|---|---|---|---|
| | ប្រើប្រាស់ក្នុងផ្ទះ បរិក្ខារប្រើប្រាស់ក្នុងអគារ និងឧស្សាហកម្ម និងរៀបចំបទប្បញ្ញត្តិដើម្បីដាក់ឱ្យអនុវត្ត"បទដ្ឋានប្រើប្រាស់ថាមពលអប្បបរមា"(ប.ប.ថ.អ.) | ទាំងកំណត់ប្រភេទនៃឧបករណ៍និងបរិក្ខារ ដែលត្រូវធ្វើ "បទដ្ឋាន&ការបិទស្លាកសញ្ញា"សម្រាប់វិស័យនីមួយៗ | | | អ.វ.ប.ន. |
| | | ៥.២. ធ្វើការវាយតម្លៃបច្ចេកទេសនិងទីផ្សារដើម្បីរៀបចំ "បទដ្ឋាន&ការបិទស្លាកសញ្ញា" សម្រាប់ឧបករណ៍ និងបរិក្ខារ | ២០២៣ | | |
| | | ៥.៣. បង្កើតនីតិវិធីទទួលស្គាល់ការធ្វើតេស្ត "បទដ្ឋាន&ការបិទស្លាកសញ្ញា" | ២០២២ -២០២៣ | | |
| | | ៥.៤. បង្កើតនីតិវិធីរដ្ឋបាលសម្រាប់ការវាយតម្លៃទទួលស្គាល់មន្ទីរពិសោធន៍ធ្វើតេស្ត "បទដ្ឋាន&ការបិទស្លាកសញ្ញា" នៅកម្ពុជា | ២០២២ -២០២៦ | | |
| | | ៥.៥. បង្កើតនិងកំណត់យកនីតិវិធីសម្រាប់មន្ទីរពិសោធន៍ធ្វើតេស្តគុណផលថាមពល ស្របតាមនីតិវិធីការធ្វើតេស្ត "បទដ្ឋាន&ការបិទស្លាកសញ្ញា" | ២០២៦ | | |
| | | ៥.៦. ចេញប្រកាសដាក់ឱ្យអនុវត្តបទដ្ឋានប្រើប្រាស់ថាមពល អប្បបរមា(ប.ប.ថ.អ.) សម្រាប់ឧបករណ៍និងបរិក្ខារដែលបានកំណត់ | ២០២៣ | | |
| | | ៥.៧. ទទួលស្គាល់មន្ទីរពិសោធន៍ ដែលត្រូវធ្វើតេស្ត ការប្រើប្រាស់ថាមពលនៃឧបករណ៍ឬបរិក្ខារប្រើប្រាស់នៅក្រោម "បទដ្ឋាន&ការបិទស្លាកសញ្ញា" | ២០២៤ | | |
| ឧស្សាហកម្ម និងអគារ | ៦.អនុវត្តកម្មវិធី | ៦.១. ចេញប្រកាស និងសេចក្តីណែនាំនានាសម្រាប់ការចេញវិញ្ញាបនបត្រ | ២០២៣ | ក.រ.ថ. | ក.ឧ.វ.ប.ន.<br>ក.ដ.ន.ស. |
| | | ៦.២. បង្កើតរចនាសម្ព័ន្ធរដ្ឋបាលសម្រាប់ការចេញវិញ្ញាបនបត្រឱ្យសវនករថាមពល | ២០២៣ | | |

| វិស័យ | វិធានការគោលនយោបាយ | ផែនការសកម្មភាព | ពេលវេលាអនុវត្ត | ស្ថាប័នអនុវត្ត | ស្ថាប័នដៃគូ |
|---|---|---|---|---|---|
| | បណ្តុះបណ្តាលសវនករថាមពល និងការផ្តល់វិញ្ញាបនប័ត្រ | ៦.៣. រៀបចំបង្កើតកម្មវិធីសិក្សា និងកំណត់វិទ្យាស្ថានដែលត្រូវធ្វើការបណ្តុះបណ្តាល | ២០២៣ | | |
| | | ៦.៤. បង្កើតកម្មវិធីបណ្តុះបណ្តាលសម្រាប់បណ្តុះបណ្តាលគ្រូបង្គោល និងបង្កើតកាលវិភាគសម្រាប់ការបណ្តុះបណ្តាល | ២០២៣ | | |
| | ៧.រៀបចំវិធានថាមពលសម្រាប់អគារ(វ.ថ.អ.) សម្រាប់អគារ លំនៅឋាន អគារពាណិជ្ជកម្ម និងអគារផ្សេងទៀត (អនុវត្តសម្រាប់តែអគារលំនៅឋាន អគារពាណិជ្ជកម្ម និងអគារផ្សេងទៀត) | ៧.១. បង្កើតរចនាសម្ព័ន្ធរដ្ឋបាលសម្រាប់រៀបចំ វ.ថ.អ. សម្រាប់អគារគ្រប់ប្រភេទនៅកម្ពុជា | ២០២៣ | ក.រ.ថ. និង ក.ដ.ន.ស. | ក.ដ.ន.ស. |
| | | ៧.២. ដាក់ចេញនីតិវិធីសម្រាប់បញ្ញត្តិប្រសិទ្ធភាពថាមពលក្នុងអគារ និងគិតពិចារណាអំពីលក្ខខណ្ឌវិនិច្ឆ័យសម្រាប់ វ.ថ.អ. រួម ទាំងប្រព័ន្ធ វ.វ.ផ. | ២០២៣ | | |
| | | ៧.៣. បញ្ចូល វ.ថ.អ. ជាមួយនឹងបទប្បញ្ញត្តិស្តីពីសំណង់អគារនៃប្រទេសកម្ពុជា | ២០២៣ | ក.ដ.ន.ស. | ក.រ.ថ. |
| | | ៧.៤. ចេញបញ្ញត្តិជាបន្តបន្ទាប់សម្រាប់ការអនុវត្ត វ.ថ.អ. | ២០២៣ | ក.រ.ថ. និង ក.ដ.ន.ស. | ក.ដ.ន.ស. |
| | ៨.រៀបចំដាក់ឱ្យអនុវត្ត វ.ថ.អ. (អនុវត្តសម្រាប់តែអគារលំនៅឋាន អគារពាណិជ្ជកម្ម និង អគារផ្សេងទៀត) | ៨.១. ចេញអនុក្រឹត្យ ឬប្រកាសដាក់ឱ្យអនុវត្ត វិធានថាមពលសម្រាប់អគារ | ២០២៤ | ក.រ.ថ. | ក.ដ.ន.ស. |

| វិស័យ | វិធានការ គោលនយោបាយ | ផែនការសកម្មភាព | ពេលវេលា អនុវត្ត | ស្ថាប័ន អនុវត្ត | ស្ថាប័នដៃគូ |
|---|---|---|---|---|---|
| | ៩.គោលការណ៍ណែនាំ និងវិញ្ញាបនបត្រកម្ម អគារបៃតង (អនុវត្តសម្រាប់តែអគារ) | ៩.១ រៀបចំ និងអនុវត្តសាកល្បង គោលការណ៍ណែនាំ និងវិញ្ញាបនបត្រកម្ម អគារបៃតង | ២០២២-២០២៣ | ក.ប.ស. និង ក.ជ.អ.ច. | ក.ជ.ន.ស. |
| | | ៩.២ រៀបចំជ្រើសបង្កើតស្ថាប័នទទួលខុសត្រូវលើការគ្រប់គ្រង និងដំណើរការ ប្រព័ន្ធវិញ្ញាបនបត្រកម្មអគារបៃតង | ២០២២ -២០២៣ | ក.ប.ស. និង ក. ជ.អ.ច. | ក.ជ.ន.ស. |
| សេវាសាធារណៈ | ១.បង្កើតវិធានស្តីពីការបំភ្លឺ ការរៀបចំបទដ្ឋាននៃការ បំភ្លឺសាធារណៈបន្ស៊ី គ្នា ជាមួយបទដ្ឋាននៃការ បំភ្លឺអន្តរជាតិ និងបង្កើត ប្រព័ន្ធវាស់វែង រាយ ការណ៍ និងផ្ទៀងផ្ទាត់ សម្រាប់ការបំភ្លឺ សាធារណៈ | ១.១. ធ្វើការសិក្សាវាយតម្លៃ រៀបចំ និងពិគ្រោះយោបល់អំពីវិធាននៃការបំភ្លឺ សាធារណៈកម្ពុជា | ២០២៤ | ក.ស.ជ. និង រដ្ឋបាល រាជ ធានីខេត្ត | ក.រ.ថ. ក.ស.ជ. |
| | | ១.២. បន្ស៊ីបទដ្ឋានការបំភ្លឺសាធារណៈ កម្ពុជា ជាមួយបទដ្ឋានការបំភ្លឺ សាធារណៈអន្តរជាតិ | ២០២៤ | | |
| | | ១.៣. រៀបចំ និងដាក់ចេញវិធានស្តីពីការបំភ្លឺសាធារណៈ | ២០២៥ | | |
| | | ១.៤. រៀបចំនិងកំណត់ប្រព័ន្ធវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ នៃបច្ចេកវិទ្យា ឬគម្រោងសម្រាប់ការបំភ្លឺ សាធារណៈ | ២០២៥ | | |
| | | ១.៥. បង្កើតប្រព័ន្ធវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ សម្រាប់ការប្រើប្រាស់ ថាមពល និងដាក់បញ្ចូលនូវបាយការណ៍បញ្ចេញឧស្ម័នផ្ទះកញ្ចក់សម្រាប់ ការធ្វើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ | ២០២៥ | | |
| | ២.ដាក់បញ្ចូលគម្រោង ប្រសិទ្ធភាពថាមពល | ២.១. ការបង្កើតចក្ខុវិស័យនៃទីក្រុងឆ្លាតវៃ និងកំណត់ក្រុងណាមួយធ្វើជាមុខ សញ្ញាដើម្បីប្រែក្លាយជា "ទីក្រុងឆ្លាតវៃ" | ២០២៥ | រដ្ឋបាល រាជ ធានីខេត្ត | ក.រ.ថ. ក.ស.ជ. |

| វិស័យ | វិធានការគោលនយោបាយ | ផែនការសកម្មភាព | ពេលវេលាអនុវត្ត | ស្ថាប័នអនុវត្ត | ស្ថាប័នដៃគូ |
|---|---|---|---|---|---|
| | ប្រព័ន្ធភ្លើងចរាចរណ៍ឆ្លាតវៃ និងប្រព័ន្ធប្រព្រឹត្តកម្មនិងបូមទឹកកខ្វក់ដើរដោយថាមពលព្រះអាទិត្យទៅក្នុងផែនការទីក្រុងឆ្លាតវៃ | ២.២. ធ្វើការសិក្សារៀបចំផែនការក្រុងឆ្លាតវៃសម្រាប់ក្រុងដែលបានកំណត់ខាងលើ | ២០២៥ | | |
| | | ២.៣. ដាក់បញ្ចូលគម្រោងបំភ្លឺសាធារណៈឆ្លាតវៃ គម្រោងប្រព័ន្ធគ្រប់គ្រងចរាចរណ៍ និងគម្រោងប្រើថាមពលព្រះអាទិត្យសម្រាប់ប្រព័ន្ធបូមទឹកកខ្វក់ទៅក្នុងផែនការទីក្រុងឆ្លាតវៃ | ២០២៦ | | |
| ដឹកជញ្ជូន | ១.បទប្បញ្ញត្តិសម្រាប់ប្រសិទ្ធភាពឥន្ធនៈ | ១.១ អនុម័តបទប្បញ្ញត្តិស្តីពីបទដ្ឋានប្រសិទ្ធភាពឥន្ធនៈសម្រាប់យានយន្តចំហេះខាងក្នុងដែលជាមធ្យោបាយ ដឹកជញ្ជូនតាមផ្លូវគោក | ២០២៥ | ក.ស.ជ. | ក.រ.ថ.<br>ក.ប.ស. |
| | | ១.២ ស្នើសុំគោលការណ៍បញ្ឈប់ប្រើប្រាស់យានយន្តប្រើម៉ាស៊ីនចំហេះក្នុង និងការលើកទឹកចិត្តនានា ដើម្បីជំរុញការបញ្ឈប់ការប្រើប្រាស់យានយន្តចាស់ៗ។ | ២០៣០ | ក.ស.ជ. | ក.រ.ថ.<br>ក.ប.ស. |
| | ២.រៀបចំបទប្បញ្ញត្តិដើម្បីលើកទឹកចិត្តការប្រើប្រាស់យានយន្តអគ្គិសនី "យ.អ." និងការបង្កើតហេដ្ឋារចនាសម្ព័ន្ធ | ២.១. រៀបចំសំណើវិសោធនកម្មលើច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធដើម្បីលើកទឹកចិត្តការប្រើប្រាស់ យ.អ. ទៅរាជរដ្ឋាភិបាល | ២០២៧<br>-<br>២០៣០ | ក.ស.ជ. | ក.រ.ថ.<br>ក.ប.ស. |
| | | ២.២. ធ្វើការសិក្សាវាយតម្លៃ ដើម្បីរៀបចំអនុសាសន៍សម្រាប់ការធ្វើវិសោធនកម្មច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធដែលកំណត់លើការរៀបចំទីកន្លែង និង | ២០២៧ | ក.ស.ជ. និង<br>ក.រ.ថ. | |

| វិស័យ | វិធានការគោលនយោបាយ | ផែនការសកម្មភាព | ពេលវេលាអនុវត្ត | ស្ថាប័នអនុវត្ត | ស្ថាប័នដៃគូ |
|---|---|---|---|---|---|
| | បញ្ចូលថាមពល សម្រាប់ យ.អ. | ទីចំណតយានយន្ត និងអគារ ដើម្បីបង្កើតបញ្ញត្តិគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធបញ្ចូលថាមពលសម្រាប់ "យ.អ." | | | |
| | | ២.៣. ធ្វើការសិក្សាវាយតម្លៃដើម្បីរៀបចំអនុសាសន៍លើរចនាសម្ព័ន្ធបញ្ជីថ្លៃលក់អគ្គិសនីសម្រាប់ហេដ្ឋារចនាសម្ព័ន្ធបញ្ចូលថាមពលសាធារណៈ និងតម្រូវការអាជ្ញាបណ្ណសម្រាប់អាជីវកម្មបញ្ចូលថាមពលសម្រាប់ យ.អ. | ២០២៧ | ក.រ.ថ. | |
| សម្រាប់គ្រប់វិស័យ នៃការប្រើប្រាស់ថាមពលទាំងអស់ | ១.រៀបចំគម្រោងគាំទ្រដល់សកម្មភាពប្រសិទ្ធភាពថាមពលតាមវិស័យនៃការប្រើប្រាស់ថាមពលអគ្គិសនី និងការប្រើប្រាស់ថាមពលប្រភេទផ្សេងទៀត។ | ១.១. បង្កើតរចនាសម្ព័ន្ធរដ្ឋបាលសម្រាប់ជួយរៀបចំគម្រោង | ២០២៣ | ក.រ.ថ. | ក.ឧ.វ.ប.ន.<br>ក.ដ.ន.ស.<br>ក.ស.ដ.<br>រដ្ឋបាលរាជធានី ខេត្ត |
| | | ១.២. បង្កើតការិយាល័យបង្គោលផ្នែកប្រសិទ្ធភាពថាមពលនៅតាមក្រសួងនិងស្ថាប័នពាក់ព័ន្ធ ដូចជា៖ ក.ឧ.វ.ប.ន., ក.ដ.ន.ស., ក.ស.ដ. និងនៅតាមរដ្ឋបាលរាជធានី ខេត្ត | ២០២៣ | ក្រសួង និងស្ថាបនពាក់ព័ន្ធ | |
| | | ១.៣. សិក្សាសមិទ្ធិលទ្ធភាពដើម្បីរៀបចំការអនុវត្តគម្រោង | ២០២៤ | ក.រ.ថ. និងក្រសួង ស្ថាបនពាក់ព័ន្ធ | |
| | | ១.៤. រៀបចំគម្រោងដែលផ្ដើមគំនិតដោយស្ថាប័នរាជរដ្ឋាភិបាលនីមួយៗ | ២០២៤ | ក្រសួង និងស្ថាបនពាក់ព័ន្ធ | |
| | | ១.៥. ផ្ដល់ថវិកាសម្រាប់ការអនុវត្តគម្រោង ឬធានាផ្ដល់តាមរយៈឧបករណ៍ហិរញ្ញប្បទានច្នៃប្រតិដ្ឋ | ២០២៥ | ក.រ.ថ. និងក្រសួង ស្ថាបនពាក់ព័ន្ធ | |

| វិស័យ | វិធានការ គោលនយោបាយ | ផែនការសកម្មភាព | ពេលវេលា អនុវត្ត | ស្ថាប័ន អនុវត្ត | ស្ថាប័នដៃគូ |
|---|---|---|---|---|---|
| | | ១.៦. អនុវត្ត និងសម្របសម្រួលគម្រោង | ២០២៦ | ក.រ.ថ. និង ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | |
| | | ១.៧. ពិនិត្យ និងវាយតម្លៃគម្រោង | ២០២៧ | ក.រ.ថ. និង ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | |
| សម្រាប់គ្រប់វិស័យនៃការប្រើប្រាស់ថាមពលទាំងអស់ | ២.យុទ្ធនាការបញ្ជ្រាបការយល់ដឹងអំពីវិធានការប្រសិទ្ធភាពថាមពល និងការប្រើប្រាស់ថាមពលប្រភេទផ្សេងទៀត។ | ២.១. កំណត់គោលដៅអ្នកដែលស្ថាប័នពាក់ព័ន្ធត្រូវធ្វើយុទ្ធនាការ បញ្ជ្រាបការយល់ដឹង ដូចជា៖ ក) បុគ្គលិកដំណើការនិងថែទាំ (O&M) នៃសហគ្រាសឧស្សាហកម្ម អគារ និងសេវាសាធារណៈ ខ)និវាសនជន គ)អ្នកប្រើប្រាស់យានយន្តសាធារណៈឬឯកជនសម្រាប់ការដឹកជញ្ជូន និងឃ) សមាគមឧស្សាហកម្ម | ២០២៥ | ក.រ.ថ. | ក.ម.ផ.<br>ក.ស.ហ.វ.<br>ក.អ.យ.ក.<br>ក.ដ.ន.ស.<br>ក.ឧ.វ.ប.ន.<br>ក.ស.ដ.<br>ក.ប.ស.<br>រដ្ឋបាលរាជធានី ខេត្ត |
| | | ២.២. វិធីសាស្ត្រសម្រាប់យុទ្ធនាការបញ្ជ្រាបការយល់ដឹង ដូចជា ក)ការផ្សព្វផ្សាយតាមបែបប្រពៃណី(រួមមានការផ្សាយពាណិជ្ជកម្ម អំពីប្រសិទ្ធភាពថាមពល និងយុទ្ធនាការបញ្ជ្រាបការយល់ដឹងតាមរយៈវិទ្យុ កាសែត ទូរទស្សន៍ ផ្ទាំងប៉ាណូឬបដានៅតាមទីសាធារណៈ។ល។ ខ)ការផ្សព្វផ្សាយតាមឌីជីថល( យុទ្ធនាការផ្សព្វផ្សាយតាមអ៊ិនធឺណែត ម៉ាស៊ីនស្រាវជ្រាវទីផ្សារឌីជីថល គេហទំព័រ ប្រព័ន្ធផ្សព្វផ្សាយតាមបណ្តាញសង្គម អ៊ីម៉ែលនិងកម្មវិធីទូរស័ព្ទចល័ត បោះពុម្ពផ្សាយសេចក្តីប្រកាសព័ត៌មាន | ២០២៥ | | |

| វិស័យ | វិធានការ គោលនយោបាយ | ផែនការសកម្មភាព | ពេលវេលាអនុវត្ត | ស្ថាប័នអនុវត្ត | ស្ថាប័នដៃគូ |
|---|---|---|---|---|---|
| | | ។ល។) និង គ) ការផ្សព្វផ្សាយតាមរយៈការរៀបចំជាអង្គប្រជុំ សិក្ខាសាលា និងវេទិកាផ្សេងៗ។ | | | |
| | | ២.៣. រៀបចំយុទ្ធសាស្ត្រសម្រាប់ការផ្សព្វផ្សាយ | ២០២៤ | | |
| | | ២.៤. ការរៀបចំកញ្ចប់ថវិកាសម្រាប់យុទ្ធនាការបញ្ជ្រាបការយល់ដឹងអំពីប្រសិទ្ធភាពថាមពល | ២០២៤ | | |
| | | ២.៥. ដាក់ចេញនូវយុទ្ធសាស្ត្របញ្ជ្រាបការយល់ដឹងអំពីវិធានការប្រសិទ្ធភាពថាមពល | ២០២៤ | | |
| សម្រាប់គ្រប់វិស័យនៃការប្រើប្រាស់ថាមពលទាំងអស់ | ៣.ការបណ្តុះបណ្តាល និងការពង្រឹងសមត្ថភាពផ្នែកប្រសិទ្ធភាពថាមពល | ៣.១. វាយតម្លៃសេចក្តីត្រូវការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពផ្នែកប្រសិទ្ធភាពថាមពលសម្រាប់ស្ថាប័ន  រាជរដ្ឋាភិបាល និងវិស័យឯកជន | ២០២៥ | ក.រ.ថ. | ទីភ្នាក់ងារដៃគូ |
| | | ៣.២. រៀបចំយុទ្ធសាស្ត្របណ្តុះបណ្តាល សម្រាប់ស្ថាប័នរាជរដ្ឋាភិបាលនិងវិស័យឯកជន | ២០២៤ | | |
| | | ៣.៣. កំណត់កម្មវិធីពង្រឹងសមត្ថភាព សម្រាប់ក្រុមហ៊ុនដំណើរការ និងថែទាំ (O&M)/ក្រុមហ៊ុនគ្រប់គ្រងទីតាំងប្រើប្រាស់ថាមពល អ្នកបច្ចេកទេសឯករាជ្យ បុគ្គលិកថែទាំបរិក្ខារក្នុងឧស្សាហកម្ម អំពីលក្ខខណ្ឌតម្រូវសម្រាប់អនុលោមភាព ការធ្វើផែនការ និងការអនុវត្តគម្រោងប្រសិទ្ធភាពថាមពល ការដំណើរ និងការថែទាំ(O&M) នៃបច្ចេកវិទ្យាប្រសិទ្ធភាពថាមពល និងការធ្វើរបាយការណ៍ទិន្នន័យនិងប្រព័ន្ធ វ.រ.ផ. នៃគម្រោងប្រសិទ្ធភាពថាមពលនៅក្នុងវិស័យឧស្សាហកម្ម និងសេវាសាធារណៈ | ២០២៥ | | |

| វិស័យ | វិធានការគោលនយោបាយ | ផែនការសកម្មភាព | ពេលវេលាអនុវត្ត | ស្ថាប័នអនុវត្ត | ស្ថាប័នដៃគូ |
|---|---|---|---|---|---|
| | | ៣.៤. កំណត់កម្មវិធីពង្រឹងសមត្ថភាព  សម្រាប់ស្ថាបត្យករ អ្នកសាងសង់ អ្នកអភិវឌ្ឍ និងក្រុមហ៊ុនអចលនទ្រព្យ លើការអនុវត្តការងារប្រសិទ្ធភាពថាមពលក្នុងអគារ រួមទាំងការរចនា និងការដំណើរការ | ២០២៤ | | |
| | | ៣.៥. រៀបចំថវិកាសម្រាប់ការបណ្តុះបណ្តាល។ | ២០២៤ | | |

# ឧបសម្ព័ន្ធ ៣- សូចនាករសម្រាប់តាមដានការអនុវត្តគោលនយោបាយជាតិស្ដីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០

| ១. ការអនុវត្ត និងការបញ្ជ្រាប គ.ជ.ប្រ.ថ. | | | | | | | |
|---|---|---|---|---|---|---|---|
| ល.រ. | សកម្មភាព | សូចនាករ | ទិន្នន័យគោល | គោលដៅ | ឆ្នាំសូចនាករ | ប្រភពនៃការផ្ទៀងផ្ទាត់ | ការទទួលខុសត្រូវសម្រាប់តាមដាន និងរាយការណ៍ |
| ១.១ | ការអនុម័តឯកសារនានារបស់គោលនយោបាយដែលបានកំណត់នៅក្នុង គ.ជ.ប្រ.ថ. | ចំនួនបទប្បញ្ញត្តិដែលត្រូវអនុម័ត | មិនមាន គោលនយោបាយ និង បទប្បញ្ញត្តិ ដោយឡែកពាក់ព័ន្ធនឹងប្រសិទ្ធភាពថាមពល នៅពេលអនុម័ត គ.ជ.ប្រ.ថ. | បទប្បញ្ញត្តិសម្រាប់កម្មវិធីគ្រប់គ្រងថាមពល (សម្រាប់ឧស្សាហកម្ម និង អគារ) | ២០២៣-២០២៤ | កម្រងអនុក្រឹត្យប្រកាស | ក.រ.ថ. រាយការណ៍ជាផ្នែកមួយនៃរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន |
| | | | | ការអនុម័ត និងផ្សព្វផ្សាយឯកសារច្បាប់ជាសាធារណៈ សម្រាប់សម្រាំង និងចាត់ថ្នាក់ ក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល | ២០២២-២០២៤ | | |
| | | | | បទដ្ឋាន&ការបិទស្លាកសញ្ញាសម្រាប់ឧបករណ៍ បរិក្ខាអគ្គិសនីតាមលំនៅឋាន អគារ និងឧស្សាហកម្ម និង បទប្បញ្ញត្តិដើម្បីអនុវត្តបទដ្ឋាន | ២០២២-២០៣០ | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | គុណផលការប្រើប្រាស់ថាមពលអប្បបរមា(ប.គ.ប.ថ.អ.) | | | |
| | | | | ការបង្កើតបទប្បញ្ញត្តិដើម្បីធ្វើការបញ្ជាក់ទទួលស្គាល់សវនករថាមពល | ២០២២-២០២៤ | | |
| | | | | ការបង្កើតបទប្បញ្ញត្តិស្តីពីវិធានថាមពលសម្រាប់អគារ (វ.ថ.អ.) | ២០២៣-២០២៤ | | |
| | | | | វិធានស្តីពីការបំភ្លឺសាធារណៈកម្ពុជា | ២០២៣-២០២៥ | | |
| | | | | បទប្បញ្ញត្តិដើម្បីលើកទឹកចិត្តការប្រើប្រាស់ និងការបង្កើតហេដ្ឋារចនា សម្ព័ន្ធបញ្ចូលថាមពលសម្រាប់យានយន្តអគ្គិសនី | ២០២៣-២០២៥ | | |
| | | | | ឯកសារគតិយុត្តបង្កើតគណៈកម្មាធិការជាតិប្រសិទ្ធភាពថាមពល | ២០២៣-២០២៥ | | |
| | | | | ឯកសារគតិយុត្តបន្ថែមសម្រាប់បង្កើតយន្តការផ្តល់រង្វាន់/ដាក់ | ២០២៣-២០២៥ | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | ពិន័យដែលត្រូវអនុវត្តដោយស្ថាប័នបង្គោល | | | |
| | | | | ឯកសារគតិយុត្តសម្រាប់ការតែងតាំងទីភ្នាក់ងារឯករាជធ្វើការផ្ទៀងផ្ទាត់ការសន្សំសំចៃថាមពលសម្រាប់កិច្ចសន្យាអនុវត្តការសន្សំសំចៃថាមពល | ២០២៣-២០២៥ | | |
| | | | | ឯកសារគតិយុត្តសម្រាប់លើកទឹកចិត្តផ្នែកសារពើពន្ធសម្រាប់គម្រោងប្រសិទ្ធភាពថាមពល | ២០២៣-២០២៥ | | |
| ១.២ | ការរៀបចំ ឬការកែតម្រូវផែនការសកម្មភាពប្រសិទ្ធភាពថាមពលតាមវិស័យ | ចំនួនផែនការសកម្មភាពប្រសិទ្ធភាពថាមពលតាមវិស័យដែលត្រូវរៀបចំ | មិនទាន់មានផែនការសកម្មភាពប្រសិទ្ធភាពថាមពលតាមវិស័យត្រូវបានអនុម័តនៅឡើយ | ផែនការសកម្មភាពប្រសិទ្ធភាពថាមពលតាមវិស័យ សម្រាប់ឧស្សាហកម្ម អគារ ដឹកជញ្ជូន និងសេវាសាធារណៈ | ២០២២-២០២៣ | របាយការណ៍ប្រចាំឆ្នាំ នៃក្រសួងពាក់ព័ន្ធ | ក្រសួងពាក់ព័ន្ធរាយការណ៍ទៅ ក.រ.ថ.៖ ឧស្សាហកម្ម (ក.ឧ.វ.ប.ន.) អគារ (ក.ដ.ន.ស.) ដឹកជញ្ជូន និងសេវាសាធារណៈ (ក.ស.ដ.) |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១.៣ | ការវិភាជថវិកា សម្រាប់អនុវត្ត គ.ជ.ប្រ.ថ. | ថវិកាវិភាជ សម្រាប់ គម្រោងប្រសិទ្ធភាព ថាមពលមានក្នុង ផែនការ យុទ្ធសាស្ត្រថវិកា (ផ.យ.ថ.) ដោយ ក.រ.ថ., ក.ឧ.វ.ប.ន., ក.ស.ជ. និង ក.ជ.ន.ស. | មិនទាន់មានជំនួយ ថវិកាសម្រាប់ ការងារ ប្រសិទ្ធភាពថាមពល នៅក្នុងផែនការ យុទ្ធសាស្ត្រថវិកានៅ ឡើយ | ថវិកាវិភាជសម្រាប់គម្រោងប្រសិទ្ធភាពថាមពល ក្នុងផែនការ យុទ្ធសាស្ត្រថវិកា | ប្រចាំឆ្នាំ | ពិនិត្យការ ចំណាយ សាធារណៈ ដោយប្រើ ឯកសារផែន ការ យុទ្ធសាស្ត្រ ថវិការបស់ ក្រសួងពាក់ព័ន្ធ | ក្រសួងពាក់ព័ន្ធ រាយការណ៍អំពីថវិកា សម្រាប់ការងារប្រសិទ្ធភាពថាមពល ទៅ ក.រ.ថ.។ |
| ១.៤ | ការផ្តល់ថវិកា សម្រាប់ការងារ ប្រសិទ្ធភាព ថាមពលក្នុង ក្របខណ្ឌ គ.ជ.ប្រ.ថ. | ចំនួនថវិកាដែលត្រូវ ផ្តល់ ធៀបនឹងចំនួន ថវិកាវិភាជ ក្នុង ផ. យ.ថ. របស់ ក.រ.ថ., ក.ឧ.វ.ប.ន., ក.ស.ជ. និង ក.ជ.ន.ស. | មិនទាន់មានការផ្តល់ ថវិកាចំណាយសម្រាប់ ការងារប្រសិទ្ធភាព ថាមពលក្នុង ផ.យ.ថ. នៅឡើយ | ថវិកាចំណាយសម្រាប់ការងារ ប្រសិទ្ធភាពថាមពលក្នុង ផ.យ.ថ. | ប្រចាំឆ្នាំ | របាយការណ៍ ប្រចាំឆ្នាំ របស់ ក្រសួងពាក់ព័ន្ធ | ក្រសួងពាក់ព័ន្ធ រាយការណ៍អំពីជំនួយ ថវិកា សម្រាប់ គម្រោងប្រសិទ្ធភាព ថាមពលទៅ ក.រ.ថ. |
| ២ | **ការត្រៀមខ្លួនរបស់ស្ថាប័ន** | | | | | | |

| ល.រ. | សកម្មភាព | សូចនាករ | ទិន្នន័យគោល | គោលដៅ | ឆ្នាំសូចនាករ | ប្រភពនៃការផ្ទៀងផ្ទាត់ | ការទទួលខុសត្រូវសម្រាប់តាមដាននិងរាយការណ៍ |
|---|---|---|---|---|---|---|---|
| ២.១ | ការបណ្តុះបណ្តាលនិងការកសាងសមត្ថភាពរបស់ស្ថាប័នដៃគូស្តីពីប្រសិទ្ធភាពថាមពល | ចំនួនសិក្ខាសាលាបណ្តុះបណ្តាលដែលត្រូវធ្វើ<br>ចំនួនអ្នកពាក់ព័ន្ធដែលត្រូវបាន បណ្តុះបណ្តាល<br>ចំនួនវគ្គបណ្តុះ បណ្តាលដែលត្រូវរៀបចំលើប្រធានបទប្រសិទ្ធភាពថាមពល | បានធ្វើសិក្ខាសាលាជាលក្ខណៈគម្រោងមួយៗ( មិនមែនជាការបណ្តុះបណ្តាលតាមយុទ្ធសាស្ត្រជាក់លាក់ទេ )<br>អ្នកពាក់ព័ន្ធបណ្តុះបណ្តាលតាមគម្រោងទូទៅប៉ុណ្ណោះមិនមានវគ្គបណ្តុះបណ្តាលដែលធ្វើសម្រាប់ប្រសិទ្ធភាពថាមពលនៅឡើយ | សិក្ខាសាលាបណ្តុះបណ្តាលស្តីពីប្រសិទ្ធភាពថាមពល<br><br>បណ្តុះបណ្តាលអំពីការងារប្រសិទ្ធភាពថាមពល ជូនភាគីពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងវិស័យឯកជន<br><br>បង្កើតវគ្គបណ្តុះបណ្តាលដែលត្រូវរៀបចំឡើងសម្រាប់បណ្តុះបណ្តាលការងារប្រសិទ្ធភាពថាមពល | ប្រចាំឆ្នាំ | របាយការណ៍តាមដានកម្មវិធី | ក្រសួងពាក់ព័ន្ធត្រូវរាយការណ៍ទៅ ក.រ.ថ.៖ឧស្សាហកម្ម (ក.ឧ.វ.ប.ន.) អគារ (ក.ដ.ន.ស.) ដឹកជញ្ជូន និងសេវាសាធារណៈ (ក.ស.ដ.) |
| ២.២ | ការដាក់ឱ្យប្រតិបត្តិប្រព័ន្ធរាយការណ៍អនឡាញសម្រាប់ | ចំនួន អ.ប.ថ.ម. ដែលត្រូវរាយការណ៍អំពីគុណផលការប្រើ | មិនទាន់មានការបង្កើតប្រព័ន្ធរាយការណ៍អនឡាញនៅឡើយ | បង្កើតប្រព័ន្ធរាយការណ៍អនឡាញសម្រាប់ អ.ប.ថ.ម. ធ្វើរបាយការណ៍អំពីគុណផលការប្រើប្រាស់ថាមពល | ២០២៣-២០២៥ | ទិន្នន័យពីប្រព័ន្ធអនឡាញ | ក.រ.ថ. ត្រូវ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ការរាយការណ៍អំពីគុណផលការប្រើប្រាស់ថាមពលដោយ អ.ប.ថ.ម. | ប្រាស់ថាមពលរបស់ពួកគេ | | | | | រាយការណ៍ជាផ្នែកនៃរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន |
| ២.៣ | ការដាក់ឱ្យប្រតិបត្តិឃ្លាំងចំណេះដឹងស្តីពីប្រសិទ្ធភាពថាមពលអនឡាញ | ចំនួនអ្នកចូលមើលគេហទំព័រ និងចំនួននៃការទាញយកឯកសារ | មិនទាន់បានបង្កើតឃ្លាំងចំណេះដឹងស្តីពីប្រសិទ្ធភាថាមពលតាមអនឡាញនៅឡើយ | បង្កើតគេហទំព័រឃ្លាំងចំណេះដឹងស្តីពីប្រសិទ្ធភាពថាមពល | ២០២៣-២០២៥ | កំណត់ត្រាចំនួនភ្ញៀវចូលមើលគេហទំព័រ | ក.រ.ថ. ត្រូវរាយការណ៍ជាផ្នែកនៃរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន |
| **៣** | **លទ្ធផល** | | | | | | |
| **ល.រ.** | **លទ្ធផលក្នុងរយៈពេលមធ្យម** | **សូចនាករ** | **ទិន្នន័យគោល** | **គោលដៅ** | **ឆ្នាំសូចនាករ** | **ប្រភពនៃការផ្ទៀងផ្ទាត់** | **ការទទួលខុសត្រូវសម្រាប់តាមដាន និងរាយការណ៍** |
| ៣.១ | គំរូអាជីវកម្មក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពលដែលមាន | ចំនួន ក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពលបានសម្រាំងនិងវាយតម្លៃនៅកម្ពុជា | មិនទាន់មាន ក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល ដែលបានសម្រាំងនិងវាយតម្លៃនៅឡើយ | ធ្វើការសម្រាំង និងវាយតម្លៃក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល សម្រាប់ធ្វើប្រតិបត្តិការនៅកម្ពុជា | ២០២៤-២០២៦ | របាយការណ៍ត្រួតពិនិត្យកម្មវិធីគ្រប់គ្រងថាមពល | ក.រ.ថ. ត្រូវរាយការណ៍ជាផ្នែកនៃរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ភាពច្នៃប្រតិដ្ឋត្រូវបានបង្កើតឡើង | ដាក់ចេញគំរូកិច្ចសន្យាផ្តល់សេវាគុណផលការប្រើប្រាស់ថាមពល | មិនទាន់មានគំរូកិច្ចសន្យាផ្តល់សេវាគុណផលការប្រើប្រាស់ថាមពលនៅឡើយ | រៀបចំសេចក្តីព្រាង និងផ្សព្វផ្សាយ គំរូកិច្ចសន្យាផ្តល់សេវាគុណផលការប្រើប្រាស់ថាមពល | | | |
| ៣.២ | សមត្ថភាពនៅថ្នាក់ជាតិដើម្បីធ្វើសវនកម្មថាមពលបានកើនឡើង | ចំនួនសវនករថាមពល ដែលបានបញ្ជាក់ទទួលស្គាល់ | មិនទាន់មានសវនករថាមពលណា បានបញ្ជាក់ទទួលស្គាល់នៅឡើយ | គោលដៅនឹងត្រូវកំណត់ក្នុងពេលដាក់លាក់ណាមួយ ផ្អែកលើច្បាប់គោល(បទប្បញ្ញត្តិសម្រាប់ការបញ្ជាក់វិញ្ញាបនបត្រសវនករថាមពល) | ២០២៤-២០២៦ | ការចុះបញ្ជីសវនករថាមពលដែលបានបញ្ជាក់ | ក.រ.ថ. រាយការណ៍ ជាផ្នែកមួយនៃរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន |
| ៣.៣ | បច្ចេកវិទ្យាប្រសិទ្ធភាពថាមពលថ្មី និងទើបតែមានត្រូវបានសាកល្បងបង្ហាញ | ចំនួនបច្ចេកវិទ្យាប្រសិទ្ធភាពថាមពលថ្មី និងទើបតែមានត្រូវបានធ្វើការសាកល្បងបង្ហាញ តាមរយៈគម្រោងគំរូ | មិនទាន់មានគម្រោងសាកល្បងណាមួយត្រូវបានអនុវត្តន៍បង្ហាញក្រោមគំរូបទប្បញ្ញត្តិ និងត្រួតពិនិត្យត្រឹមត្រូវ' នៅឡើយ | គម្រោងសាកល្បង ត្រូវបានអនុវត្តបង្ហាញ ក្រោមគំរូ "បទប្បញ្ញត្តិត្រួតពិនិត្យត្រឹមត្រូវ" (ក្នុងវដ្តនៃកម្មវិធីវិនិយោគសាធារណៈ) | ចាប់ផ្តើមពី ឆ្នាំ ២០២២ តទៅ | បញ្ជីនៃ គម្រោង ដោយ ស្ថាប័នបង្គោលដែលបានអនុញ្ញាត | ក្រសួងពាក់ព័ន្ធ រាយការណ៍ ទៅ ក.រ.ថ.៖ ឧស្សាហកម្ម (ក.ឧ.វ.ប.ន.) អគារ (ក.ដ.ន.ស.) ដឹកជញ្ជូន និងសេវាសាធារណៈ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | | | (ក.ស.ជ.) |
| ៣.៤ | គម្រោងប្រសិទ្ធភាពថាមពលត្រូវបានរៀបចំ | ចំនួនគម្រោងប្រសិទ្ធភាពថាមពលដែលបានរៀបចំ | មិនទាន់មានគម្រោងប្រសិទ្ធភាពថាមពលត្រូវបានរៀបចំឡើងនៅឡើយ | គម្រោងប្រសិទ្ធភាពថាមពលទាំងអស់ត្រូវបានរៀបចំនៅក្នុង ផ.ស.ប.ថ.វ. | ចាប់ផ្តើមពីឆ្នាំ ២០២៣ សម្រាប់រាល់ ផ.ស.ប.ថ.វ. | របាយការណ៍តាមដានកម្មវិធីនៃ ផ.ស.ប.ថ.វ របាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងពាក់ព័ន្ធ | ក្រសួងពាក់ព័ន្ធរាយការណ៍ទៅ ក.រ.ថ.៖ ឧស្សាហកម្ម (ក.ឧ.វ.ប.ន.) អគារ (ក.ជ.ន.ស.) ដឹកជញ្ជូន និងសេវាសាធារណៈ (ក.ស.ជ.) |
| ៣.៥ | គម្រោងប្រសិទ្ធភាពថាមពលត្រូវបានដាក់បញ្ចូលចូលក្នុងផែនការ(ជាតិ/ក្រោមជាតិ/តាមវិស័យ) | ចំនួនប្រើប្រាស់ថាមពលតាម វិស័យ (សម្រាប់ឧស្សាហកម្ម អគារ និងសេវាសាធារណៈ) ត្រូវបានរាយការណ៍ | មិនទាន់មានរបាយការណ៍ទិន្នន័យថាមពល តាមវិស័យនៅឡើយ | ទិន្នន័យថាមពលត្រូវបានធ្វើរបាយការណ៍តាមទម្រង់គំរូ តាមវិស័យប្រើប្រាស់ថាមពលនីមួយៗ | ចាប់ផ្តើមឆ្នាំ ២០២៣ លើមូលដ្ឋានប្រចាំឆ្នាំ | រក្សាទិន្នន័យមូលដ្ឋានដោយស្ថាប័នបង្គោល | ក្រសួងពាក់ព័ន្ធរាយការណ៍ទៅ ក.រ.ថ.៖ ឧស្សាហកម្ម (ក.ឧ.វ.ប.ន.) អគារ (ក.ជ.ន.ស.) ដឹកជញ្ជូន និងសេវាសាធារណៈ (ក.ស.ជ.) |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣.៦ | ហិរញ្ញប្បទាន ប្រសិទ្ធភាព ថាមពលត្រូវបាន កៀរគរតាមរយៈ ជំនួយអភិវឌ្ឍន៍ផ្លូវការ/ទីភ្នាក់ងារ អភិវឌ្ឍន៍អន្តរជាតិ | ១. បរិមាណថវិកា ត្រូវបានសន្សំ បម្រុងទុកឱ្យ ២. បរិមាណថវិកា ត្រូវបានផ្ដល់ឱ្យ | មិនទាន់មានថវិកា ហិរញ្ញប្បទានណា ត្រូវបានបម្រុងទុក ឬ បានផ្ដល់ឱ្យនៅឡើយ | ការចុះកិច្ចព្រមព្រៀងហិរញ្ញប្បទាន រវាងរាជរដ្ឋាភិបាលនិង ដៃគូអភិវឌ្ឍ និងការដកសាច់ប្រាក់ និង/ឬ ការផ្ដល់ហិរញ្ញប្បទានឥតសំណង ក្រោមទម្រង់ផ្សេងទៀត សម្រាប់ហិរញ្ញប្បទានគម្រោង វិនិយោគសាធារណៈក្នុងវិស័យថាមពល។ ការកៀរគរតាមរយៈភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP) ក៏ជាប្រភពហិរញ្ញប្បទានសក្ដានុពលមួយ ដែលរាជរដ្ឋាភិបាលអាចពិចារណាសម្រាប់គម្រោងប្រសិទ្ធភាពថាមពលដែរ។ | ចាប់ផ្ដើមឆ្នាំ ២០២៣ លើមូលដ្ឋានប្រចាំឆ្នាំ | បញ្ជីទិន្នន័យ ជំនួយអភិវឌ្ឍន៍ផ្លូវការកម្ពុជា របស់ ក.អ.ក. | ក.ស.ហ.វ រាយការណ៍ទិន្នន័យនីមួយៗទៅ ក.រ.ថ. |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣.៧ | ការវិនិយោគលើគម្រោងប្រសិទ្ធភាពថាមពលក្នុងតំបន់សេដ្ឋកិច្ចពិសេសត្រូវបានលើកកម្ពស់ | ចំនួនអនុញ្ញាតនៃសំណើគម្រោងប្រសិទ្ធភាពថាមពលក្រោមគម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ (QIP) | មិនទាន់មានផែនការគម្រោងប្រសិទ្ធភាពថាមពល ក្រោមគម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់នៅឡើយ | ផែនការគម្រោងប្រសិទ្ធភាពថាមពលកំណត់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមពេលវេលាជាក់ស្តែង | មិនមាន | កំណត់ត្រានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ក.អ.ក. រាយការណ៍ទិន្នន័យនីមួយៗទៅ ក.រ.ថ. |
| ៣.៨ | ការយល់ដឹងទៅលើវិធានការប្រសិទ្ធភាពថាមពលត្រូវបានលើកកម្ពស់ | ចំនួនយុទ្ធនាការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីប្រសិទ្ធភាពថាមពល | មិនទាន់មានការអនុវត្តយុទ្ធនាការណាមួយលើកកម្ពស់ការយល់ដឹងសាធារណៈក្រោម គ.ជ.ប្រ.ថ. នៅឡើយ | បង្កើតយុទ្ធនាការ លើកកម្ពស់ការយល់ដឹងសាធារណៈក្រោម គ.ជ.ប្រ.ថ. | តាមកម្មវិធីស្ថាប័នបង្គោល និងស្ថាប័នដៃគូ | របាយការណ៍ត្រួតពិនិត្យកម្មវិធី | ក.រ.ថ. រាយការណ៍ជាផ្នែកមួយនៃរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន |
| ៤ | ផលប៉ះពាល់/ឥទ្ធិពល | | | | | | |
| ល.រ. | លទ្ធផលក្នុងរយៈពេលវែង | សូចនាករ | ទិន្នន័យគោល | គោលដៅ | ឆ្នាំសូចនាករ | ប្រភពនៃការផ្ទៀងផ្ទាត់ | ការទទួលខុសត្រូវសម្រាប់តាមដាននិងរាយការណ៍ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤.១ | គុណផលនៃប្រសិទ្ធភាពថាមពលថ្នាក់ជាតិ និងតាមវិស័យត្រូវបានធ្វើឱ្យប្រសើរឡើង | ១. អាំងតង់ស៊ីតេថាមពលកម្រិតជាតិធៀបទៅនឹងគោលដៅ<br>២. អាំងតង់ស៊ីតេការបញ្ចេញឧស្ម័នផ្ទះកញ្ចក់កម្រិតជាតិធៀបទៅនឹងគោលដៅ<br>៣. អាំងតង់ស៊ីតេវិស័យថាមពល (ឧស្សាហកម្ម អគារ ការដឹកជញ្ជូន សេវាសាធារណៈ)<br>៤. អាំងតង់ស៊ីតេការបញ្ចេញឧស្ម័នផ្ទះកញ្ចក់តាមវិស័យ ធៀបទៅនឹងគោលដៅ។ | ដូចដែលបានកំណត់នៅក្នុង គំរូគណនារបស់ គ.ជ.ប្រ.ថ. | ដូចដែលបានកំណត់ដោយ គ.ជ.ប្រ.ថ. រៀងរាល់ឆ្នាំ ចាប់ពី ឆ្នាំ ២០២២ ទៅ ២០៣០ | មិនមាន | ទិន្នន័យរបស់ ក.រ.ថ. | ក.រ.ថ. រាយការណ៍ ជាផ្នែកនៃរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន |

**ក្រសួងរ៉ែ និងថាមពល**

លេខ១ មហាវិថីព្រះនរោត្តម ១២០២១១

ទូរស័ព្ទ៖ (៨៥៥) ២៣ ២១៩ ៥៧៤

គេហទំព័រ៖ www.mme.gov.kh

ទំព័រហ្វេសប៊ុក៖ Ministry of Mines and Energy Cambodia

បណ្តាញតេលេក្រាម៖ ក្រសួងរ៉ែ និងថាមពល-Ministry of Mines and Energy